ISSN 1560 9812

# ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា

## ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន

ឯកសារពិភាក្សាលេខ ២៤

គឹម សេតារា, ច័ន្ទ សុផល និង Sarthi Acharya

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឯកសារ
ពិភាក្សា
លេខ ២៤

# ដីធ្លី ជីវភាពជនបទ
# និងសន្តិសុខស្បៀងនៅកម្ពុជា

## ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន

**ឯកសារពិភាក្សាលេខ ២៤**

**គីម សេតារា, ច័ន្ទ សុផល និង**
**Sarthi Acharya**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**
**ខែធ្នូ ឆ្នាំ២០០២**

© រក្សាសិទ្ធិឆ្នាំ២០០២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗ ដូចជា អេឡិចត្រូនិក យន្តកម្ម ថតចម្លង... ។ល។ ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISSN 1560 9812

**ដីធ្លី ជីវភាពជនបទ និងសន្តិសុខសង្គមនៅកម្ពុជា: ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន**
**ឯកសារពិភាក្សាលេខ ២៤**
**ខែធ្នូ ឆ្នាំ២០០២**

*គីម សេតារា និង ច័ន្ទ សុផល និង Sarthi Acharya*

*ទស្សនៈទាំងឡាយនៅក្នុងឯកសារនេះ គឺជាគំនិតផ្ទាល់របស់អ្នកនិពន្ធ ។ ទស្សនៈទាំងនោះ មិនមែនជាទស្សនៈរបស់វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាទេ ។*

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា
ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា (ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា)
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១/៨៨១-៩១៦/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល: **cdri@camnet.com.kh website: http://www.cdri.org.kh**

បកប្រែដោយ: គីម សេតារា
កែសម្រួល និងរចនាដោយ: អ៊ុំ ចាន់ថា និងយូ សិទ្ធីរិទ្ធ
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ពជប៉ុន ផ្ទះលេខ៧៤ ផ្លូវលេខ៩៩ សង្កាត់ផ្សារដើមថ្កូវ រាជធានីភ្នំពេញ

# មាតិកា


សេចក្តីថ្លែងអំណរគុណ ..... i

បញ្ជីអក្សរកាត់ ..... iii

សេចក្តីសង្ខេប..... v

**ជំពូកទី ១ សេចក្តីផ្តើម** ..... ១

**ជំពូកទី ២ គំហើញនៃអង្កេតនៅតាមមូលដ្ឋាន** ..... ៥

២.១. លទ្ធភាពប្រើប្រាស់ដីកសិកម្ម..... ៦

២.២. ការប្រើប្រាស់ដី និងលទ្ធភាពមានផលដំណាំជាស្បៀង..... ៩

២.៣. សកម្មភាពមិនមែនកសិកម្ម..... ១៣

២.៤. ទំរង់ទីផ្សារ ..... ១៩

២.៥. ប្រជាជន ចំណាកស្រុក និងទីផ្សាពលកម្ម..... ២២

**ជំពូកទី ៣ សំយោគមួយពីការអង្កេតនៅមូលដ្ឋាន**..... ២៥

៣.១. បញ្ហាប្រជាសាស្ត្រ..... ២៥

៣.២. សំពាធនៃបរិស្ថាន និងការធ្លាក់ចុះនៃធនធានធម្មជាតិ..... ២៥

៣.៣. ការលេចចេញមានឡើងនូវវិសមភាពដី និងភាពគ្មានដីធ្លី ..... ២៥

៣.៤.ការពុះចែកដីតូចៗ..... ២៦

៣.៥. ការធ្វើយន្តកម្មយន្តកសិកម្ម និងការបែងចែកផលចំណេញ..... ២៦

៣.៦. ទំនើបកម្មកសិកម្ម..... ២៦

៣.៧. អសុក្រិតភាព និងការត្រួតត្រាទីផ្សារ..... ២៧

៣.៨. ជំរើសការងារ និងប្រាក់ចំណូល..... ២៧

**ជំពូកទី ៤ ជំរើសគោលនយោបាយ**..... ២៩

៤.១. ទំនើបកម្មកសិកម្ម ..... ២៩

៤.២. ដំណើរការទីផ្សារប្រកបដោយប្រសិទ្ធិភាព..... ៣០

៤.៣. សន្តិសុខនៃកម្មសិទ្ធិ ................ ៣០
៤.៤. ការគ្រប់គ្រងធនធានធម្មជាតិ ................ ៣១
៤.៥. ការធ្វើចំរុះកម្មមុខរបរ និងការកសាងធនធានមនុស្ស ................ ៣១
៤.៦. ការឱ្យមានតុល្យភាពទីផ្សារពលកម្ម ................ ៣១
**ជំពូកទី ៥ សេចក្តីសន្និដ្ឋាន** ................ ៣៣
**ឯកសារយោង** ................ ៣៥
**ឧបសម្ព័ន្ធសង្ខេបការសិក្សាលើភូមិនានា** ................ ៣៧
១. ភូមិក្រសាំង - អតិរេកស្រូវអង្ករ ភាពគ្មានដីធ្លីកំរិតខ្ពស់ និងពលកម្មចំណាកស្រុក ................ ៣៧
២. បាបោង - ភូមិមានអតិរេកស្រូវអង្ករ ................ ៤០
៣. ត្រពាំងប្រិយ - ភូមិអន់ថយដែលមានលក្ខណៈខ្វះខាតស្រូវ ................ ៤៣
៤. ព្រៃកក្មេង ជាភូមិនេសាទ និងភូមិកសិកម្ម ................ ៤៦
៥. ដងក្តារ ភូមិពឹងផ្អែកលើស្រូវ និងព្រៃឈើ ................ ៤៨
៦. កំពង់ត្នោត - ភូមិពឹងផ្អែកលើកសិកម្ម និង ការនេសាទតាមឆ្នេរសមុទ្រ ................ ៥១
**បញ្ជីឯកសារពិភាក្សារបស់ ១បសអ** ................ ៥៥

# សេចក្តីថ្លែងអំណរគុណ

ឯកសារនេះជាផ្នែកមួយនៃគំរោងស្រាវជ្រាវដ៏ធំស្តីពីជីវភាព និងសន្តិសុខស្បៀង ដែលរៀបចំឡើងដោយ វិបសអ ឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពី DFID ។ វាជាឯកសារទីពីរ នៅក្នុងកំរងអត្ថបទមានឯកសារពីរ ដែលត្រូវបានតាក់តែងនៅក្នុងគំរោងនេះ ។

អ្នកនិពន្ធសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះការចូលរួមរបស់អ្នកភូមិ និងប្រធានភូមិទាំងឡាយ ។ បើសិនជាគ្មានការចូលរួមពីអ្នកទាំងនេះទេ ការសិក្សាក៏មិនអាចធ្វើទៅបានដែរ ។

អ្នកនិពន្ធ ក៏សូមថ្លែងអំណរគុណផងដែរចំពោះលោក សូ សុវណ្ណារិទ្ធ និង ប៊ុន ដូរីណា ដែលបានចុះជួយស្រាវជ្រាវនៅតាមមូលដ្ឋាន និង Eva Mysliwiec, David Wharton, Bruce McKenney, និង Vikas Pandey, ចំពោះការជួយផ្តល់យោបល់ដ៏មានប្រយោជន៍ទាំងឡាយ ។

*ភ្នំពេញ, ខែសីហា ឆ្នាំ២០០២*

*គីម សេតារា, ច័ន្ទ សុផល, និង Sarthi Acharya*

*វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

# បញ្ជីអក្សរកាត់

| | |
|---|---|
| ACLEDA | សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចកម្ពុជា ហៅកាត់ថា *អេស៊ីលីដា* (Association of Cambodian Local Economic Development Agencies) |
| CDRI | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| DFID | នាយកដ្ឋានសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ □ ចក្រភពអង់គ្លេស (Department for International Development – UK) |
| GRET | ក្រុមស្រាវជ្រាវ និងផ្លាស់ប្តូរបច្ចេកទេសគ្នា (Groupe de Recherches et d' Échanges Technologiques) |
| GTZ | ទីភ្នាក់ងារអាល្លឺម៉ង់សំរាប់សហប្រតិបត្តិការបច្ចេកទេស (Deutsche Gesellschaft fuer Technische Zusammenarbeit) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា (Royal Government of Cambodia) |
| UNICEF | មូលនិធិសំរាប់កុមារនៃអង្គការសហប្រជាជាតិ (United Nations Children's Fund) |
| VDC | គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (Village Development Committee) |

# សេចក្តីសង្ខេប

ចាប់តាំងពីចុងទសវត្សរ៍១៩៩០ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ) បាននិងកំពុងធ្វើការសិក្សាដោយលំអិតពីទិដ្ឋភាពផ្សេងៗនៃជីវភាពជនបទ ដីធ្លី និងបរិស្ថាននៅប្រទេសកម្ពុជា ។ ការសិក្សាពីដំបូងៗត្រូវបានធ្វើឡើងក្នុងឆ្នាំ១៩៩៧-១៩៩៨ និងមានការសិក្សាបន្ថែមទៀតនៅឆ្នាំ២000-២00១ ។ ឯកសារស្រាវជ្រាវនេះ ជាផ្នែកមួយនៃគំរោងស្រាវជ្រាវដ៏ធំ ស្តីអំពីដីធ្លី និងសន្តិសុខស្បៀងដែលបានផ្តួចផ្តើមឡើងនៅដើមឆ្នាំ២00១ នឹងពិភាក្សាវែកញែកពីការ ផ្លាស់ប្តូរយុទ្ធសាស្ត្រដោះស្រាយជីវភាព ការប្រើប្រាស់ដី និងលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិនៅក្នុងជនបទកម្ពុជា ។ ឯកសារ នេះផ្តោតជាពិសេសលើសំណួរមួយចំនួនដូចខាងក្រោម :

ក. តើការបែងចែកដីកសិកម្ម មានលំនាំ និងសន្ទុះយ៉ាងដូចម្តេច?

ខ. តើការប្រើប្រាស់ដី មានលំនាំ និងកំលាំងយ៉ាងណា?

គ. តើអ្នកភូមិធ្វើសកម្មភាពក្រៅកសិកម្មអ្វីខ្លះ ជាបន្ថែម ឬជំនួសឱ្យសកម្មភាពកសិកម្ម និងជាចំនែកមួយនៃយុទ្ធសាស្ត្ររស់រានជីវិត ហើយវាមានប្រសិទ្ធិភាពប៉ុណ្ណាដែរក្នុងការដោះស្រាយជីវភាព?

ឃ. តើទីផ្សារនៅជនបទសំរាប់ដីធ្លី ផលិតផលកសិកម្ម និងឥណទានបានផុសឡើងតាមរបៀបណា?

ង. តើប្រជាសាស្ត្រ ចំណាកស្រុក និងទីផ្សារពលកម្ម មានលក្ខណៈយ៉ាងដូចម្តេច?

ការសិក្សាធ្វើឡើងនៅក្នុងភូមិចំនួនប្រាំមួយ ដែលតំណាងឱ្យតំបន់ធាតុអាកាស-កសិកម្មធំៗទាំងអស់នៅកម្ពុជា ត្រូវបានរៀបចំឡើងដោយប្រើប្រាស់វិធីសាស្ត្រនរវិទ្យា និងវិធីសាស្ត្របែបគុណភាពផ្សេងៗ និងដោយបានធ្វើសម្ភាសអ្នកភូមិជាច្រើនប្រភេទ ដូចជា អ្នកនេសាទ អ្នកបេះប្រមូលផលព្រៃឈើ ជនចំណាកស្រុក ក្រុមស្ត្រី ចាស់ទុំភូមិ អ្នកកាន់កាប់ដីធំ-តូច អ្នកជំនួញ អ្នកដឹកជញ្ជូន អ្នកចងការប្រាក់... ។ ឧបករណ៍ធ្វើអង្កេត គឺបញ្ជីសំណួរដែលមានរៀបចំពាក់កណ្តាល ។ ពត៌មានខ្លះទៀតប្រមូលបានពីប្រភពទី២ និងអង្កេតស្របគ្នាដែលធ្វើឡើងដោយប្រើបញ្ជីសំនួរមានលក្ខណៈរៀបចំពេញលេញ ហើយដែលផ្តល់លទ្ធផលដូចមានបោះពុម្ពផ្សាយដាច់ដោយឡែក ។

លទ្ធផលនៃការស្រាវជ្រាវនេះបង្ហាញថា ថ្វីត្បិតតែការបែងចែកដីកសិកម្មនៅចុងទសវត្សរ៍១៩៨0 បានស្មើភាពល្អគួរសមក៏ដោយ ក៏នៅក្នុងទសវត្សរ៍ចុងក្រោយនេះ គេបានពិនិត្យឃើញវិសមភាពកើតខ្ពស់ក្នុងការកាន់កាប់ដីធ្លី និងភាពគ្មានដីធ្លី ។ រឿងនេះមានមូលហេតុជាច្រើន ហើយមូលហេតុធំៗមានដូចតទៅ :

ក. ការលក់ដី ដែលកើតចេញពីចំណាយខ្ពស់ជាងចំណូល ដែលមានមូលហេតុចំបងជាការឡើងចុះខ្លាំង ឬការបាក់ស្រុតនៃថ្លៃលើទីផ្សារផលិតផលកសិកម្ម ។

ខ. ការពុះចែកដីធ្លីតូចៗ ដោយសារកំណើនប្រជាជនយ៉ាងលឿន និងការកសាងគ្រួសារថ្មី ហើយព្រំដែនដីមិនបានរីកធំលឿនទាន់កំណើនប្រជាជន ។

គ. តំរូវការដីធ្លី និងធនធានធម្មជាតិ ដ៏ច្រើនលើសលប់ពីខាងក្រៅវិស័យកសិកម្ម ។

ឃ. កសិករមួយចំនួនខ្វះខាតមធ្យោបាយ ដើម្បីបង្កើនប្រសិទ្ធិភាពក្នុងការប្រើប្រាស់ដី ។

ង. តំរូវការប្រាក់កាសជាបន្ទាន់ សំរាប់រ៉ាប់រងចំណាយលើជំងឺដង្កាត់ក្នុងគ្រួសារ ។

ទោះបីការកាប់ព្រៃឈើ និងការរានយកដីលិចទឹកពីព្រៃកោងកាង បានផ្តល់ដីបន្ថែមក៏ដោយ ក៏តំរូវការដី វាធំជាងការផ្គត់ផ្គង់ដីច្រើនណាស់ ។

នៅមូលដ្ឋានមួយចំនួន កសិករខ្លះប្រើប្រាស់ដីយ៉ាងខ្លាំង ដោយប្រើធាតុចូល (inputs) ទំនើប ដើម្បីបានទិន្នផល លើសពី ៣តោន/ហិកតា ។ អ្នកទាំងនេះភាគច្រើនជាកសិករធំៗ ។ ចំពោះកសិករតូចៗ គេទទួលផលប្រយោជន៍មិនបានពេញលេញពីការធ្វើកសិកម្មទេ ដោយសារជួបបញ្ហាផ្សេងៗដូចជា ដីតូចពេក គ្មានផលចំណេញខាងសេដ្ឋកិច្ច ប្រព័ន្ធធារាសាស្ត្រមិនគ្រប់គ្រាន់ សមាហរណកម្មទីផ្សារមានកំរិតទាប ឥណទានមានតំលៃខ្ពស់... ។ ការបង្កើនយន្តកម្មកសិកម្ម អាចជួយដល់កសិករតែមួយចំនួនតូច ដោយសារការបែងចែកផលចំណេញបានពីការប្រើម៉ាស៊ីនធំៗនៅក្នុងទីផ្សារមួយដែលមិនទាន់សុក្រិត្យល្អ គឺមិនមែនសុទ្ធតែមានលក្ខណៈអព្យាក្រឹតនោះទេ ។ ម្យ៉ាងទៀត ទីផ្សារដែលពាក់ព័ន្ធគ្នា និងអ្នករកស៊ីផ្តាច់មុខនៅតាមមូលដ្ឋាន ច្រើនតែត្រួតត្រាលើប្រព័ន្ធទិញលក់ធាតុចេញ និងផលិតផល នៅក្នុងវិស័យកសិកម្ម ដែលប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍របស់កសិករតូចៗ ។ ជាក់ស្តែង កសិករតូចៗ និងអ្នកគ្មានដី គឺបានទទួលផលចំណេញពីទំនើបភាវូបនីកម្មកសិកម្មក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ក្នុងកំរិតតិចជាងកសិករធុនធំខ្លាំងណាស់ ។ ហើយនៅក្នុងភូមិមួយចំនួន ដីមានគុណភាពអន់ កង្វះធាតុចូលទំនើប និងភាពដាច់ស្រយាល បានគួបផ្សំគ្នាធ្វើឱ្យទិន្នផលមានកំរិតទាប និងភាពក្រីក្រមានកំរិតខ្ពស់ជាទូទៅ ។

ប្រជាជនក៏បានប្រកបការងារមិនមែនកសិកម្មមួយចំនួនដែរ ជាពិសេសការប្រមូលភោគផលពីព្រៃឈើ និងការនេសាទដែលអាចជាសកម្មភាពតាមរដូវ និងពេញមួយឆ្នាំតែម្តង ហើយទោះបីការងារមិនមែនកសិកម្មផ្អែកលើធនធានធម្មជាតិ និងការងារមិនមែនកសិកម្ម ពុំសូវមានក៏ដោយ ក៏យ៉ាងហោចណាស់មានមួយភូមិដែរ ដែលប្រជាជនគេប្រកបរបរផលិតអំបិល ។ សកម្មភាពដែលផ្សារភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងធនធានធម្មជាតិ ឥឡូវនេះបានឈានទៅដល់កំរិតតិត្ថិភាព (saturation) ហើយ ។ ឧទាហរណ៍ ការនេសាទ និងធនធានព្រៃឈើ កំពុងជួបការតឹងតែងខ្លាំងណាស់ខាងអេកូឡូស៊ី ដោយសារការប្រើប្រាស់ធនធានគ្មានផែនការច្បាស់លាស់ គ្មានលក្ខណៈវិទ្យាសាស្ត្រ និងមានលក្ខណៈទាញយកផលច្រើនហួសហេតុ ។ ម្យ៉ាងទៀត ការធ្វើឯកជននីយកម្មនូវធនធានទ្រព្យរួមមួយចំនួន បានប៉ះពាល់ដល់ជំរើសការងាររបស់ជនក្រីក្រ ។ ការផលិតអំបិលនៅតាមភូមិ តាមឆ្នេរសមុទ្រ បានផ្តល់ការងារយ៉ាងទៀងទាត់ដល់ប្រជាជនជាច្រើន ប៉ុន្តែក្នុងពេលថ្មីៗនេះ ថ្លៃអំបិលត្រូវជាប់គាំង ដោយសារការបើកចំហរទីផ្សារចំពោះអំបិលនាំចូលមានតម្លៃទាប ហើយកត្តានេះបានធ្វើឱ្យប្រាក់ចំនូលរបស់ពលករកម្ពុជានៅតែមានកំរិតទាប ។

នៅក្នុងភូមិជាច្រើន សព្វថ្ងៃប្រជាជនប្រកាន់យកយុទ្ធសាស្ត្រដោះស្រាយផ្សេងៗដូចជា ធ្វើចំណាកស្រុកឆ្លងខេត្ត ឬក៏ឆ្លងប្រទេស, ធ្វើការយកប្រាក់កំរៃលើកសិដ្ឋានរបស់អ្នកដទៃ, ធ្វើការងារហត្ថកម្មគ្មានជំនាញ, និងប្រកបការងារតាមរដូវក្នុងផ្នែកមិនមែនកសិកម្ម (ដូចជា ការជួញដូរតូចតាច...) ជាដើម ។ សកម្មភាពទាំងនេះជួយបន្ធូរពេលនៃការចូលរួមធ្វើផលិតកម្ម ប៉ុន្តែវាមានឧបសគ្គខ្លះជាប់ជានិច្ច ។ ឧទាហរណ៍ការធ្វើដំណើរឆ្លងដែនទៅប្រទេសថៃ មានលក្ខណៈខុសច្បាប់ ហើយគ្រោះថ្នាក់ពីព្រោះទោះបីជាច្រើនទាក់រកការងារធ្វើបាន ដោយទទួលកំរៃពី ៨០-១០០បាតក្នុងមួយថ្ងៃ (ប្រហែល ២ដុល្លារ) ក៏ដោយក៏មានខ្លះត្រូវគេបោក និងត្រូវចាប់ខ្លួនបញ្ជូនមកស្រុកវិញ ។ ម្យ៉ាងទៀត កំរៃពលកម្មនៃការងារគ្មានជំនាញនៅតាមមូលដ្ឋានមានកំរិតទាប ប្រហែល ៣.០០០ ទៅ ៤.០០០រៀលក្នុងមួយថ្ងៃ ដែលមិនគ្រប់គ្រាន់សំរាប់ធានាសន្តិសុខស្បៀងឱ្យបានសមរម្យ

ទេ ។ មួយចំណែកទៀត នៅក្នុងទីក្រុង ការងារក៏ពុំមានគ្រប់គ្រាន់ដែរ (ដូចជា វិស័យជំនួញ, កាត់ដេរ...) ដូច្នេះប្រជាជនធ្វើចំណាកស្រុកចូលទីក្រុង គេពុំមានលទ្ធភាពរកប្រាក់កំរៃបានគ្រប់គ្រាន់ឡើយ ។ ការងារនៅក្រៅវិស័យកសិកម្ម ក៏មានតិច ដោយសារទីផ្សារមិនលូតលាស់ទៅមុខ (គឺមានការធ្លាក់ចុះសេដ្ឋកិច្ច និងបញ្ហាផ្សេងៗពាក់ព័ន្ធទៅនឹងភាពមិនទាន់អភិវឌ្ឍន៍ពេញលេញនៃរចនាសម្ព័ន្ធ) ។ ក្នុងរឿងនេះ កង្វះខាតធនធានមនុស្ស គឺជាឧបសគ្គចំបងមួយដល់ការខំរក្សាឱ្យមានជីវភាពសមស្រប ។

សន្តិសុខស្បៀងជាបញ្ហាមានលក្ខណៈវដ្ដរកាលក្នុងក៏រិតណាមួយ ប៉ុន្តែក្នុងភូមិមួយចំនួន សន្តិសុខស្បៀងជាបញ្ហាមួយមានលក្ខណៈរ៉ាំរ៉ៃ ។ ការគួបផ្សំគ្នានៃសម្ពាធប្រជាជនខ្លាំងហួសពេក, ធនធានមនុស្សទន់ខ្សោយ, លទ្ធភាពអាចចូលបំរើការងារបានមានកំរិតទាប, ការថយចុះនៃឱកាសរកការងារធ្វើបាន, សមាហរណកម្មទីផ្សារមិនអំណោយផល, និងកង្វះខាតហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងទីផ្សារ បានរួមចំណែកបង្កសន្តិសុខស្បៀង ។

ដោយផ្អែកលើបទពិសោធន៍នៃប្រទេសអាស៊ីផ្សេងៗទៀត ឯកសារនេះលើកឡើងនូវជំរើសគោលនយោបាយមួយចំនួនដែលសំដៅធ្វើឱ្យមានការផ្លាស់ប្តូរជាទូទៅនៅក្នុងសង្គម ជាជាងព្យាយាមសំរេចគោលដៅតាមវិស័យតូចៗដែលមានដូចតទៅ:

ក. ទំនើបភាវូបនីយកម្មកសិកម្ម និងការធ្វើចំរុះកម្មមុខដំណាំ (crop diversification)

ខ. ទីផ្សារផលិតផល និងកត្តាផលិតកម្ម ដែលមានប្រសិទ្ធិភាព និងមានលក្ខណៈប្រកួតប្រជែង

គ. សន្តិសុខនៃការកាន់កាប់ដី និងការគ្រប់គ្រងត្រួតត្រាលើការពុះចែកដីតូចៗពេក

ឃ. ការបង្កើនចំនួនមុខរបរ និងការពង្រឹងធនធានមនុស្ស

ង. ការធ្វើអន្តរាគមន៍លើទីផ្សារពលកម្ម ដើម្បីបង្កើតឱ្យមានកំរៃពលកម្មអប្បបរិមាដែលអាចរស់បាន និងសំណាញ់សុវត្ថិភាពផ្សេងទៀត ។

ការអនុវត្តន៍ព្រមៗគ្នាមួយនូវគោលនយោបាយនានា នឹងផ្តល់ផលចំណេញ ប្រសើរជាងវិធីសាស្ត្រដោះស្រាយមួយមុខម្តងៗ ។

# ជំពូកទី ១

# សេចក្តីផ្តើម

គេបានទទួលស្គាល់ជាទូទៅថា ការបែងចែកដីកសិកម្មមានសមភាពបង្គួរ ក្នុងចំណោមកសិករ និងអ្នកភូមិ នៅពេលប្រទេសកម្ពុជាលុបចោលរបបដីក្រុមសាមគ្គីនៅក្នុងឆ្នាំ១៩៨៩ ។ គ្រួសារប្រកបរបរកសិកម្មនាពេលនោះ ទទួលបានដីមួយប្លង់តូចដែលមានទំហំពីមួយទៅពីរហិកតា អាស្រ័យទៅតាមដីធ្លីដែលមាននៅក្នុងតំបន់នីមួយៗ និងតាមទំហំគ្រួសារ ។ គេមិនសូវមានពត៌មានច្រើនស្តីពីស្ថានភាពដីកសិកម្មនៅដើមទសវត្សរ៍១៩៩០ទេ ប៉ុន្តែនៅចុងទសវត្សរ៍១៩៩0 គេឃើញមានសញ្ញាបង្ហាញពីការប្រមូលផ្តុំដីធ្លីទៅក្នុងដៃមនុស្សមួយចំនួនតូច និងកំណើនភាពគ្មានដីធ្លី ។ នៅក្នុងសេដ្ឋកិច្ចមួយដែលមានប្រជាជនភាគច្រើនជាកសិករជីវព្រឹត្តិ និន្នាការបែបនេះអាចបង្កភាពអត់ការងារធ្វើ និងអសន្តិសុខស្បៀង ដែលមានកត់ត្រានៅក្នុងរបាយការណ៍របស់រដ្ឋាភិបាល ក៏ដូចជាការ សិក្សាដាច់ដោយឡែកផ្សេងៗទៀត (Murshid 1998; Biddulph 2000, RGC 2001, So *et al.* 2001; Bhargavi *et al.* 2001 – RGC 2002a; Chan 2002) ។ម្យ៉ាងទៀត ដោយសារកត្តាមួយចំនួន ដូចជាកំណើនប្រជាជន និងការបង្កើតប្រព័ន្ធទីផ្សារ សន្តិសុខស្បៀង អាចទទួលរងការប៉ះពាល់ជាច្រើនបែបយ៉ាង ។

តើដំណើរការនៃការបែងចែកដីធ្លី/ទ្រព្យសម្បត្តិ និងការប្រើប្រាស់ដីឡើងវិញ ឬការប្រែប្រួលខាងសេដ្ឋកិច្ច-សង្គមកិច្ចនៅថ្នាក់ភូមិ វាមានលក្ខណៈយ៉ាងដូចម្តេច, តើកត្តាទាំងនេះ ប៉ះពាល់ដល់សន្តិសុខស្បៀងរបៀបណា, តើប្រជាជនបានប្រកាន់យកយុទ្ធសាស្ត្រសំរាប់ការរស់រានជីវិតអ្វីខ្លះ នៅចំពោះមុខរចនាសម្ព័ន្ធកសិកម្មទើបផុសឡើងថ្មី? សំណួរមានន័យទូលាយនានាខាងលើបង្ហាញពីខ្លឹមសារសំខាន់នៃឯកសារនេះ ។

ឯកសារនេះព្យាយាមឆ្លើយតបនឹងសំណួរជាក់លាក់មួយចំនួនដូចខាងក្រោមៈ

- តើការបែងចែក និងការប្រើប្រាស់ដីកសិកម្ម មានលំនាំយ៉ាងដូចម្តេច?
- តើការប្រើប្រាស់ដី មានលំនាំ និងកំលាំងយ៉ាងណា?
- តើសកម្មភាពមិនផ្សារភ្ជាប់នឹងដីធ្លីដែលអ្នកភូមិអនុវត្ត ដើម្បីបំពេញបន្ថែម ឬជំនួសឱ្យចំណូលបានពីកសិកម្ម មានលំនាំ និងនិន្នាការយ៉ាងណា?
- តើទីផ្សារនៅជនបទសំរាប់ដីធ្លី ផលិតផលកសិកម្ម និងឥណទាន/មូលធន បានផុសឡើងយ៉ាងដូចម្តេច?
- តើប្រជាសាស្ត្រ ចំណាកស្រុក និងទីផ្សារពលកម្មមានលក្ខណៈយ៉ាងដូចម្តេច, តើកំណើនប្រជាជនលឿន វាមានចំណែកឬទេក្នុងការធ្វើឱ្យបញ្ហាជាប់ទាក់ទិនផ្សេងៗ កាន់តែធ្ងន់ធ្ងរថែមទៀត?

ឯកសារនេះជាផ្នែកមួយនៃកម្មវិធីស្រាវជ្រាវធំទូលាយស្តីពីដីធ្លី និងសន្តិសុខស្បៀង ធ្វើការបកស្រាយនូវសំណួរទាំងនេះដោយផ្អែកលើការសិក្សាតាមមូលដ្ឋានក្នុងភូមិចំនួនប្រាំមួយ ។ គោលបំណងដំបូងនៃការស្រាវជ្រាវ គឺធ្វើអង្កេតក្នុងភូមិចំនួន

ប្រាំបួន ដោយប្រើបញ្ជីសំណួរតាមបែបសិក្សាបរិមាណ (quantitative survey questionnaires) ។ ប៉ុន្តែ ក្រោយពីបានបង្ហើយអង្កេតផ្អែកលើបញ្ជីសំណួរនេះ ក៏មានការគិតឃើញថា ត្រូវធ្វើអង្កេតថែមទៀតជាចាំបាច់ ដោយប្រើវិធីសាស្ត្រសិក្សាគុណភាព (qualitative methods) ដើម្បីស្វែងយល់ពីនិចលភាពនៃសង្គមកសិកភូមិ ។ ដូច្នេះអង្កេតបន្ថែម ក៏បានធ្វើឡើងនៅក្នុងភូមិចំនួនប្រាំមួយ ក្នុងចំណោមភូមិទាំងប្រាំបួន ដោយប្រើបច្ចេកទេសសម្ភាសន៍ជាក្រុម និងការសង្កេត ។

ផ្នែកបន្ទាប់នៃជំពូកនេះ បង្ហាញត្រួសៗពីវិធីសាស្ត្របែបគុណភាព (qualitative methodology) ដែលបានប្រើប្រាស់ និងពន្យល់ពីការជ្រើសរើសភូមិគំរូតាង ។ ជំពូកទី២ រួមមាន ការបកស្រាយតាមប្រធានបទ (thematic presentation) នូវទិន្នន័យដែលទទួលបានពីការសិក្សាភូមិទាំងនេះ និងការពិភាក្សាពីបញ្ហាការកាន់កាប់ដីធ្លី, ការបែងចែកដីធ្លី និងទីផ្សារដីធ្លី, ផលិតកម្មកសិកម្ម និងលទ្ធភាពមានស្បៀងអង្ករ, សកម្មភាពមិនមែនកសិកម្ម (រួមទាំងសកម្មភាពពឹងផ្អែកលើធនធានធម្មជាតិ), ទីផ្សារមូលធននិងឥណទាន, ទីផ្សារពលកម្មដោយពិនិត្យពីប្រាក់កំរៃ យុទ្ធសាស្ត្រទប់ទល់ផ្សេងៗ និងចំណាកស្រុក ។ សំយោគនៃបញ្ហាចំបងៗដែលផុសចេញពីការសិក្សាមានបង្ហាញជូននៅក្នុងជំពូកទី៣ ។ ជំពូកទី៤ ពិនិត្យអំពីជំរើសច្រើនបែបយ៉ាងខាងគោលនយោបាយសាធារណៈ ដែលគេយល់ឃើញថា ជាផ្នែកមួយនៃដំណោះស្រាយជាយថាក្រម (systematic solution) ចំពោះបញ្ហាកសិកម្មនៅកម្ពុជា ។ ជំពូកទី៥ ផ្តល់នូវសេចក្តីសន្និដ្ឋានខ្លីមួយ ។ នៅក្នុងឧបសម្ព័ន្ធ មានចុះសេចក្តីសង្ខេបលំអិត (detailed synopses) នៃការសិក្សាលើភូមិនានា ។

## វិធីសាស្ត្រ និងការដកស្រង់ពត៌មាន

តំបន់អាកាសធាតុកសិកម្មមានបួន-ប្រាំនៅក្នុងប្រទេសកម្ពុជា ជាអាទិ៍ តំបន់ជុំវិញបឹងទន្លេសាប តំបន់ខ្ពង់រាប តំបន់វាលទំនាបមានដីជាតិល្អនៅភាគខាងលិច តំបន់ឆ្នេរសមុទ្រ និងតំបន់ទន្លេមេគង្គខាងក្រោម[១] ។ គំរូតាងធំនៃការសិក្សានេះមានភូមិចំនួនប្រាំបួន ដែលតំណាងឱ្យតំបន់អាកាសធាតុកសិកម្មទាំងអស់នៅកម្ពុជា ។ ប៉ុន្តែសំរាប់ការវិភាគបែបគុណភាពមានតែភូមិចំនួនប្រាំមួយទេដែលត្រូវបានចុះសិក្សា ប៉ុន្តែលក្ខណៈតំណាងខាងភូមិសាស្ត្រ ក៏ពុំមានបាត់បង់អ្វីច្រើនដែរ ពីព្រោះនៅក្នុងគំរូតាងតំបន់ខ្លះដែលធំៗ គឺមានភូមិសិក្សាលើសពីមួយភូមិ ដើម្បីក្តាប់យកពីបំរែបំរួលនៅផ្ទៃក្នុងនៃតំបន់នីមួយៗ ។

ទិន្នន័យស្តីពីលក្ខណៈសម្បត្តិមួយចំនួននៃភូមិទាំងនេះ មានចុះសង្ខេបក្នុងតារាង១.១ ។ របៀបអង្កេត (survey design) និងកំណត់ត្រាបានមកពីមូលដ្ឋាន, បានកំណត់ឡើងពីរបៀបចុះបង្ហាញទិន្នន័យនៅក្នុងតារាង និងការប្រើពាក្យមានន័យមិនសូវជាក់លាក់ (subjective words) ខ្លះដូចជា "ខ្ពស់", "ទាប"... ដែលមានលក្ខណៈប្រៀបធៀបទៅនឹងភូមិដទៃ និងតួលេខមធ្យមកំរិតជាតិ ។

ក្រៅពីលក្ខណៈតំណាងខាងអាកាសធាតុកសិកម្ម នៅមានលក្ខណៈវិនិច្ឆ័យផ្សេងទៀតសំរាប់ការជ្រើសភូមិទាំងនេះ ។ តំបន់ខ្លះជាកន្លែងខ្វះខាតស្រូវ (ត្រពាំងប្រិយ) ខ្លះទៀតជាកន្លែងមានស្រូវលើសពីតំរូវការ (ក្រសាំង, បាបោង), តំបន់ខ្លះពឹងផ្អែកលើត្រី (ត្រីសមុទ្រនៅកំពង់ត្នោត និងត្រីទឹកសាបនៅព្រែកក្មេង) និងកន្លែងខ្លះទៀតពឹងផ្អែកជាសំខាន់លើព្រៃឈើ (ភូមិដងក្តារ) ។ ទាំងអស់នេះបញ្ជាក់ពីគំរូដើមមួយចំនួន (prototypes) សំរាប់ការរស់រានមានជីវិតខាងសេដ្ឋកិច្ច-សង្គមកិច្ច និងលំនាំមុខរបរនៅក្នុងគំរូតាង ។ ការសិក្សានេះមិនអាចផ្តល់ការប្រៀបធៀបពីភាពខុសគ្នារវាងតំបន់នានានៅទូទាំងប្រទេសបានទេ (ពីព្រោះគំរូតាងត្រូវបានជ្រើសយកដោយខ្លួនឯង) ប៉ុន្តែវាឆ្លុះបញ្ចាំងពីដំណើរការ និងការផ្លាស់ប្តូរ ដែលកំពុងកើតឡើង និងបានប៉ះពាល់ (ល្អ និងមិនល្អ) ដល់សន្តិសុខស្បៀងនៅតាមតំបន់នានា បើផ្អែកតាមការរៀបរាប់ពីអ្នកឆ្លើយសម្ភាសន៍ ។

[១] អត្ថបទនេះបញ្ជាក់ថា តំបន់អាកាសធាតុកសិកម្មនៅកម្ពុជា មានបួន ឬប្រាំ ប៉ុន្តែមិនបញ្ជាក់ថាមានប៉ុន្មានជាក់លាក់ទេ ពីព្រោះគ្មានការមូលមតិគ្នា (consensus ) ។ អ្នកស្ថិតិមានយោបល់ខុសប្លែកពីអ្នកវិទ្យាសាស្ត្រកសិកម្ម ។

បទសម្ភាសន៍ត្រូវបានធ្វើឡើងជាមួយប្រភេទប្រជាជនដូចតទៅៈ ចាស់ទុំក្នុងភូមិ ម្ចាស់មធ្យោបាយដឹកជញ្ជូន អ្នកមានឥទ្ធិពល កសិករគ្មានដីធ្លី ស្ត្រីមេម៉ាយ កសិករក្រីក្រ អ្នកជំនួញតូចតាច អ្នកកាន់កាប់ដីធំៗ និងអ្នកចងការប្រាក់ ។ ទោះបីជាប្រភេទអ្នកឆ្លើយសម្ភាសន៍ខ្លះមានលក្ខណៈត្រួតគ្នាក៏ដោយ ក៏ប្រភេទទាំងនេះត្រូវបានរក្សាទុកសំរាប់ផ្ទៀងផ្ទាត់លើហេតុការណ៍ជាក់លាក់មួយចំនួន ។ ឧបករណ៍នៃអង្កេត គឺបញ្ជីសំណួរមានលក្ខណៈពាក់កណ្តាលរៀបចំ ។ ពត៌មានខ្លះ ត្រូវបានប្រមូលពីប្រភពទី២ និងអង្កេតបែបបរិមាណដែលធ្វើស្របគ្នា (parallel quantitative inquiry) ។ ឯកសារនេះ មានលក្ខណៈជាការសិក្សាតាមប្រធានបទ ជាជាងការសិក្សាផ្អែកលើភូមិជាក់លាក់មួយៗ ទោះបីជាក្នុងឧបសម្ព័ន្ធមានចុះសេចក្តីសង្ខេបលំអិត (synopses) ពីភូមិនីមួយៗក្តី ។ រយៈពេលគោលសំរាប់ការសិក្សា គឺប្រាំឆ្នាំចុងក្រោយ គឺចាប់ពីចុងទសវត្សរ៍១៩៩០ មកទល់នឹងដើមទសវត្សរ៍២០០០ ។ ចំពោះភូមិចំនួនបី (ក្នុងចំណោមភូមិចំនួនប្រាំមួយ) មានភូមិព្រៃកក្អែង ភូមិត្រពាំងប្រិយ និងភូមិបាបោង មានការធ្វើជំរើសនូវកត្តាដែលត្រូវយកមកប្រៀបធៀបគ្នាមើល ដោយផ្អែកលើកត្តាមួយចំនួនតូច ត្រូវបានសិក្សានៅក្នុងអង្កេតកាលពីឆ្នាំ១៩៩៧ ។

**តារាង១.១ លក្ខណៈសំគាល់នៃភូមិដែលបានពិភាក្សា**

| ឈ្មោះភូមិ | ភូមិក្រសាំង | ភូមិបាបោង | ភូមិត្រពាំងប្រិយ | ភូមិកំពង់ត្នោត | ភូមិដងក្តារ | ភូមិព្រៃកក្អែង |
|---|---|---|---|---|---|---|
| ខេត្ត | បាត់ដំបង | ព្រៃវែង | កំពង់ស្ពឺ | កំពត | កំពង់ធំ | កណ្តាល |
| ចំងាយពីផ្លូវធំ | ផ្លូវដែលងាយស្រួលគ្រប់រដូវ | ផ្លូវលិចទឹក, ធ្វើដំណើរតាមទូកនៅរដូវវស្សា | ផ្លូវអាចធ្វើដំណើរ គ្រប់រដូវ , ខាងក្នុង | ផ្លូវអាចធ្វើដំណើរ គ្រប់រដូវ ទៅមកស្រួល | ផ្លូវដី ចូលក្នុងជ្រៅ | លិចទឹក៦ខែ |
| នៅជិតឬនៅក្នុងព្រៃ | ជាប់ព្រៃលិចទឹក | មិនមែន | ព្រៃនៅឆ្ងាយពី១០-១៥គ.ម | ព្រៃបាត់បង់លឿន | នៅក្នុងព្រៃ | ជាប់នឹងព្រៃលិចទឹក |
| នៅជិតទន្លេ | មែន | មែន | មិនមែន | ជិតសមុទ្រ | មិនមែន | មែន |
| ដីស្រែ (ហិកតា) | ៣៣៧ | ៦៩៥ | ៣១ | ១៥០ | ១២៧ | ១៣៧ |
| ប្រជាជន | ១.២៦៣នាក់ឬ ២២៨គ្រួសារ | ២៥៧១នាក់ឬ ៥៣៦គ្រួសារ | ៣៨៧នាក់ឬ ៦៨គ្រួសារ | ២០៤៨នាក់ឬ ៣៣៩គ្រួសារ | ១៤២២នាក់ឬ ៣០៦គ្រួសារ | ១៥៩២នាក់ឬ ៤០២គ្រួសារ |
| ភាពគ្មានដីធ្លី | ខ្ពស់ | មិនសូវខ្ពស់ | ទាប | ខ្ពស់, ដីទំហំតូច | គ្មាន | ខ្ពស់ |
| ការងារមិនមែនកសិកម្ម-នេសាទ | ខ្ពស់ | ខ្ពស់ | គ្មាន | ខ្ពស់ខ្លាំង (ត្រីសមុទ្រ) | គ្មាន | ខ្ពស់ខ្លាំង |
| ការងារមិនមែនកសិកម្ម-ព្រៃឈើ | តិច | គ្មាន | គ្មាន | តិចណាស់ | ច្រើន | តិច |
| ចំណាកស្រុក | ខ្ពស់ | ទាប | ខ្ពស់ | ទាប | គ្មាន | គ្មាន |
| ឥទ្ធិពលទីផ្សារ | មាន | មាន | គ្មាន | មានតិច | គ្មាន | មាន |
| គុណភាពដី | ល្អ | ល្អ | អន់ | មធ្យម | មធ្យម/ អន់ | ល្អ |
| ចំនួនគ្រួសារថ្មី | ទាប | ទាប | ទាប | ខ្ពស់ | គ្មាន | មធ្យម |
| កំណើនប្រជាជន | ខ្ពស់ | ខ្ពស់ | មធ្យម | ខ្ពស់ | មធ្យម | ខ្ពស់ |
| លទ្ធភាពអាចរកបានធនធានទ្រព្យរួម | មាន | ថយចុះ | គ្មាន | ថយចុះ | មាន | មាន |

# ជំពូកទី ២

# គំហើញនៃអង្កេតនៅតាមមូលដ្ឋាន

មុននឹងបង្ហាញពីគំហើញនានា សំខាន់គេត្រូវកំណត់ពីអត្ថន័យនៃពាក្យសន្តិសុខស្បៀងនៅក្នុងបរិបទនៃប្រទេសកម្ពុជា ។ សន្តិសុខស្បៀង សំដៅ (ជាសំខាន់ ប៉ុន្តែមិនមែនទាំងស្រុងទេ) ដល់ភាពមានស្រូវអង្ករនៅក្នុងភូមិ (ពីព្រោះស្រូវអង្ករជាស្បៀងចំបង) និងលទ្ធភាពរបស់គ្រួសារនីមួយៗក្នុងការរកបានស្រូវអង្ករគ្រប់គ្រាន់សំរាប់បង្គ្រប់តំរូវការរបស់ខ្លួន ។ គ្រួសារអាចធានាឱ្យមានស្រូវអង្ករតាមរយៈការផលិតស្បៀងដោយខ្លួនឯង ឬតាមរយៈការទិញ ឬការដោះដូរ ។ បើសិនជាគ្រួសារមាន ឬគ្មានដីធ្លីមិនគ្រប់គ្រាន់ ឬមិនអាចរក្សាទុកផលិតផលរបស់ខ្លួនបាន គេត្រូវទិញចូលទាំងអស់ ឬមួយចំណែកនៃតំរូវការស្រូវអង្កររបស់ខ្លួន ។ បើសិនជាគ្រួសារនោះ មិនអាចទិញស្បៀង ដោយពុំមានប្រាក់ចំណូលគ្រប់គ្រាន់មកពីប្រភពផ្សេងទៀត (លោក Amartya Sen ហៅថា ការដោះដូរកម្មសិទ្ធិ) ឬត្រូវទទួលយកការងារមានលក្ខណៈមិនពិតប្រាកដ មានគ្រោះថ្នាក់សំរាប់រយៈពេលមិនកំណត់ និងមានកំរៃទាប ស្ថានភាពនេះត្រូវបានចាត់ទុកជាអសន្តិសុខស្បៀង ។ ក្នុងករណីបែបនេះ គ្រួសារត្រូវរស់នៅដោយត្បិតត្បៀតរស់រានបានដោយពឹងផ្អែកលើសប្បុរសធម៌ពីអ្នកដទៃ ឬក៏ប្រកាន់យកយុទ្ធសាស្ត្រហានិភ័យផ្សេងៗសំរាប់ឱ្យជីវិតរស់រានបាន ។ ឯកសារនេះប្រើពាក្យ "សន្តិសុខស្បៀង" (ឬអសន្តិសុខស្បៀង) ស្របតាមនិយមន័យដូចបានបញ្ជាក់ជូន ។

ភូមិសិក្សាទាំងប្រាំមួយ មានភាពខុសគ្នាយ៉ាងច្រើនខាងប្រជាសាស្ត្រ រចនាសម្ព័ន្ធមុខរបរ គុណភាពកសិកម្ម កំរិតនៃការអភិវឌ្ឍន៍ និងការប្រែប្រួលផ្សេងៗដែលបានកើតឡើងក្នុងការផ្ទេរកម្មសិទ្ធិដី និងការផលិតស្បៀង ។ ទិន្នផលកសិកម្មនៅភូមិក្រសាំង (ខេត្តបាត់ដំបង) និងភូមិបាបោង (ខេត្តព្រៃវែង) មានកំរិតខ្ពស់ពី ៣តោន ទៅ ៣,៥តោនក្នុងមួយហិកតា ហើយគេផលិតស្បៀងសំរាប់បំរើទីផ្សារ ពីព្រោះភូមិទាំងអស់នេះ ស្ថិតនៅក្នុងតំបន់ដែលដីមានជីជាតិបំផុត និងមានប្រព័ន្ធស្រោចស្រពមួយចំនួនផង ។ ភូមិត្រពាំងប្រិយ (ខេត្តកំពង់ស្ពឺ) ជាភូមិខ្វះខាតស្បៀង ដោយសារដីមានគុណភាពអន់ ខ្វះប្រភពទឹក និងស្ទើរតែ គ្មានធនធានផ្សេងៗទៀត ដូចជា ព្រៃឈើ ឬត្រី ដែលតែងតែឃើញមានជាទូទៅនៅកន្លែងដទៃ៖ ទិន្នផលស្រូវនៅភូមិនេះ គឺពី ១តោន ទៅ ១,៤តោនក្នុងមួយហិកតា ។ ភូមិនេសាទចំបងពីរ (ភូមិព្រែកក្មេង និងភូមិកំពង់ត្នោត) និងភូមិមានព្រៃឈើ (ភូមិ ដងក្តារ) បង្ហាញពីការពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានធម្មជាតិ ហើយអ្នកភូមិបានជួបការលំបាកជាច្រើន ដែលពាក់ព័ន្ធនឹងការ ធ្លាក់ចុះយ៉ាងយ៉ាប់យ៉ឺននៃអេកូឡូស៊ីនៅក្នុងមូលដ្ឋាន ។ ចំពោះហេដ្ឋារចនាសម្ព័ន្ធវិញ ភូមិទាំងអស់លើកលែងតែភូមិដងក្តារចេញ មានសាលាបឋមសិក្សាមួយៗ ប៉ុន្តែមជ្ឈមណ្ឌលសុខភាពច្រើនតែនៅឆ្ងាយ ជាទូទៅគឺជាមជ្ឈមណ្ឌលសុខភាពស្រុកតែម្តង ។ ដោយសារតែកង្វះខាតមូលនិធិ និងបុគ្គលិក, សេវាសង្គមកិច្ចទាំងអស់ មានគុណភាពទាប ។ មានផ្លូវអាចចេញចូលបានគ្រប់រដូវ ដែលតភ្ជាប់ទៅភូមិក្រសាំង ភូមិត្រពាំងប្រិយ និងភូមិកំពង់ត្នោត, តែផ្លូវភ្ជាប់ទៅភូមិក្រសាំង វាយ៉ាន់យ៉ឺនណាស់ ។ ភូមិបាបោង និងភូមិព្រែកក្មេង

ត្រូវកាត់ផ្តាច់ និង/ឬទឹកជន់លិចនៅរដូវវស្សា (អាចធ្វើដំណើរទៅបានតាមទូក) ចំណែកឯភូមិដងក្តារវិញ តភ្ជាប់ទៅដោយផ្លូវលំមួយ ។ ការលក់ដូរផលិតផលចំណាកស្រុក និងវិធីសាស្ត្ររកស៊ីចិញ្ចឹមជីវិតផ្សេងទៀត ត្រូវទទួលរងផលប៉ះពាល់ពីកត្តាទាំងអស់ដែលបានរៀបរាបខាងលើ (ពតិមានលំអិតមានចុះក្នុងសេចក្តីសង្ខេបនៃការសិក្សាពីភូមិ ដែលជូនភ្ជាប់ជាឧបសម្ព័ន្ធ) ។

## ២.១. លទ្ធភាពប្រើប្រាស់ដីកសិកម្ម

ដីកសិកម្មនៅកម្ពុជា ប្រហែលបានទទួលរងផលប៉ះពាល់ពីការវឹកវរក្នុងប្រវត្តិសាស្ត្រ ខ្លាំងជាងកន្លែងណាៗទាំងអស់ ។ ដីធ្លីបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឯកជនរហូតដល់ឆ្នាំ១៩៧៥ ទើបត្រូវគេប្រមូលដាក់ជាកម្មសិទ្ធិរួម ។ ដីបានឆ្លងកាត់របបគ្រប់គ្រងជាសហគមន៍មួយបែបទៀតនៅឆ្នាំ១៩៨០ និងបានធ្វើឯកជននីយកម្មឡើងវិញនៅឆ្នាំ១៩៨៩[២] ។ ចលនា និងការតាំងលំនៅជាថ្មីនៃប្រជាជនដ៏ច្រើនៗ បានកើតមាននៅក្នុងអន្តរកាលនេះ ហើយជាចំបងដោយសារភាពរអាក់រអួលខាងលើបញ្ហាដីនៅតែដោះស្រាយមិនទាន់បាន ។ កសិករខ្លះកំពុងស្វែងរកដី ដែលខ្លួនអាចរស់នៅបានសមរម្យ ឯខ្លះទៀតកំពុងរង់ចាំដំណោះស្រាយទំនាស់ដី ។ ពាក់ព័ន្ធនឹងរឿងដីធ្លី បញ្ហាលេចធ្លោធំៗមានជាអាទិ៍ ការវាស់វែង និងចេញកម្មសិទ្ធិដីមិនទាន់បានពេញលេញ, ការកំណត់យុត្តាធិការ និងសន្តិសុខកម្មសិទ្ធិ, ដំណើរការទីផ្សារដី, គ្រាប់មីននៅតាមតំបន់ខ្លះ និងភាពគ្មានដីធ្លី ។ បញ្ហារំខានខ្លាំងជាងគេ គឺភាពគ្មានដី ពីព្រោះខ្វះលទ្ធភាពមានដីប្រើប្រាស់ បានក្លាយជាមូលហេតុចំបងនៃភាពក្រីក្រនៅក្នុងសង្គមកសិកម្ម[៣] ។

នៅភូមិក្រសាំង ក្នុងខេត្តបាត់ដំបង ដីមិនដែលបែងចែកឡើងវិញជាផ្លូវការទេ (នេះជាការពិតនៅក្នុងស្រុកថ្មគោលទាំងមូល) ដោយសារបញ្ហាសន្តិសុខនៅតាមកន្លែងជាច្រើននៃតំបន់នេះក្នុងទសវត្សរ៍១៩៨០ និងដើមទសវត្សរ៍១៩៩០ ។ ចាស់ទុំក្នុងភូមិបានអះអាងថា មកទល់ឆ្នាំ១៩៩៤ ប្រជាជនជួបនឹងកង្វះខាតដីបង្កបង្កើនផល ពីព្រោះខ្មែរក្រហមកាន់កាប់ដីទំនាបលិចទឹកនៅជាប់ទន្លេសាបអស់ច្រើនកន្លែងធំៗ ។ ក្រោយឆ្នាំ១៩៩៣-៩៤ នៅពេលមានសន្តិភាពវិញ ប្រជាជនបានពង្រីកសកម្មភាពទៅខាងតំបន់លិចទឹក បានឆ្ងាយរហូតដល់ប្រហែល ១៥ - ២០គ.ម ពីភូមិ និងបានចាប់ផ្តើមប្រើដីទាំងនេះសំរាប់ធ្វើស្រែប្រាំង[៤] ។ តាំងពីពេលនោះមក ដីត្រូវបានដោះដូរពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ជាពិសេសដីនៅតំបន់លិចទឹក ។ ដោយសារកំណើនប្រជាជន ភាពគ្មានដីធ្លីកើនឡើងជារៀងរាល់ឆ្នាំ ។ នៅចុងឆ្នាំ២០០១ នាពេលធ្វើអង្កេតនេះ គឺមាន ១២៥គ្រួសារគ្មានដី (ជាងពាក់កណ្តាលនៃគ្រួសារទាំងអស់) ក្នុងនេះមាន ២៤គ្រួសារដឹកនាំដោយស្ត្រីមេម៉ាយ[៥] ។ គ្រួសារទាំងនេះភាគច្រើនត្រូវលក់ឬបញ្ចាំដីស្រែរបស់ខ្លួន ដោះស្រាយចំណាយផ្សេងៗដូចជា សងបំណុលព្យាបាលជំងឺ និង/ឬដោះកុនកង្វះខាតស្បៀងប្រចាំរដូវ ឬចំណាយធ្វើដំណើរឆ្លងដែន ទៅរកការងារធ្វើនៅថៃ ។ ពេលខ្លះម្ចាស់ដីធំៗដែលជាអ្នករកស៊ីចងការប្រាក់ផងដែរ បានទិញយកដីទាំងនេះ ។ ទំហំនៃការកាន់កាប់ដីជាមធ្យម គឺជិតដល់ ២ហិកតា (ដីស្រែ) ប៉ុន្តែអ្នកបានទិញដីនៅប៉ុន្មានឆ្នាំថ្មីៗ គឺមានដីច្រើន ឯអ្នកបានលក់ដី គឺមានដីកាន់កាប់កាន់តែតូចឬគ្មានសោះ ។ មានមនុស្សមួយចំនួនតូចកាន់កាប់ដីច្រើនជាង ២០ហិកតាក្នុងម្នាក់ៗ ។ ប្រជាជន មកពីភូមិជិតខាង (ឫស្សី) កាន់កាប់ដីស្រែជាង ១០០ហិកតានៅភូមិក្រសាំង[៦] ។ ភាគច្រើនគេទទួលបានដីទាំងនេះ

---

[២] រឿងរ៉ាវប្រវត្តិសាស្ត្រ មានអធិប្បាយនៅក្នុងឯកសាររបស់ Thion (1994) និង Meijers (1994) ព្រមទាំងអត្ថបទខ្លីៗមួយចំនួនរបស់ Sok *et al.* (2001) និង Sik (2000) ។

[៣] ការរៀបរាប់ក្បោះក្បាយពីបញ្ហាពាក់ព័ន្ធនឹងដីធ្លី ជាពិសេសភាពមិនបានចុះបញ្ជីនៅក្នុងឯកសាររបស់ Kato (1999), Williams (1999), Sida (2001) និង Sok *et al.* (2001) ។

[៤] អ្នកភូមិក៏បានយកដីលំនៅដ្ឋាន ដែលជាកេរ្តិ៍ពីឪពុកម្តាយគេកាន់កាប់ពីមុនឆ្នាំ១៩៧៥ មកវិញ ។

[៥] មូលហេតុមួយដែលថាគ្រួសារស្ត្រីមេម៉ាយគ្មានដី គឺដោយសារគេខ្វះកំលាំងមនុស្សភ្ជួរដី ។ ប្រសិនបើគេជួលពលករសំរាប់ធ្វើស្រែតំលៃវាខ្ពស់ពេក ។ អវត្តមាននៃសិទ្ធិកាន់កាប់ដីដ៏ជាក់លាក់ ការកាន់កាប់ដីមិនតែងតែមានសុវត្ថិភាពទេ ជារឿយៗគេតែងតែលក់ដីនោះ ។

[៦] ប្រៀបធៀបទៅនឹងប្រជាជននៅភូមិក្រសាំង ប្រជាជននៅភូមិឫស្សីមានជីវភាពរស់នៅខ្ពស់ជាង ដោយសារប្រជាជននៅភូមិនោះ ជាអ្នក

តាមរយៈការទិញ និងបញ្ចាំ ។

*ភូមិបាបោង* ក្នុងខេត្តព្រៃវែង មិនបានជួបការរីករាលដាលខាងនយោបាយធំដុំទេក្នុងទសវត្សរ៍១៩៨០ ហើយដីស្រែត្រូវបានបែងចែកឱ្យស្មើរតែស្មើៗគ្នាក្នុងឆ្នាំ១៩៨៩ ដោយមួយគ្រួសារទទួលបានដីពី ១ ទៅ ២ហិកតា ។ ទោះយ៉ាងនេះក្តី វិសមភាពនៃការកាន់ កាប់ដីបានផុសឡើងយ៉ាងឆាប់ ទី១. ដោយសារគ្រួសារខ្លះដែលមានមនុស្សពេញកំលាំង និងសត្វអូសទាញ បានរានព្រៃលិចទឹកធ្វើ ជាដីស្រែ ។ លើសពីនេះទៀត ដោយការកសាងប្រព័ន្ធធារាសាស្ត្រនៅចុងទសវត្សរ៍១៩៩០ កសិករខ្លះបានពង្រីកដីថែម ដោយរាន យកដីរួម ដើម្បីបានចំណេញពីឥទ្ធិពលសេដ្ឋកិច្ចវិមាត្រ (economies of scale)។ ការមកដល់នៃយន្តកម្មនៅចុងទសវត្សរ៍១៩៩០ ក៏បានជំរុញកសិករមួយចំនួនតូចឱ្យពង្រីកដីធ្លីដែរ ដើម្បីបានចំណេញពីឥទ្ធិពលសេដ្ឋកិច្ចវិមាត្រ ដែលបានបង្កើនថែមនូវវិសមភាពដី (មានរបាយការណ៍ពីការទិញដីដ៏គគ្រឹកគគ្រេង និងការប្រមូលដីតូចៗចូលគ្នាក្នុងកំឡុងពេលនោះ[៧] ។ នៅឆ្នាំ២០០១ មាន ១៥-២០គ្រួសារមានដីច្រើន ក្នុងនេះ ២គ្រួសារ កាន់កាប់ដីលើសពី ២០ហិកតា/គ្រួសារ ហើយកសិករពី ១០-១៥នាក់ទៀត កាន់កាប់ ដីពី ១០-១៥ហិកតាក្នុងម្នាក់ៗ ។ តួលេខនេះមិនរាប់បញ្ចូលដីបញ្ចាំទេ ។ ទី២. ការលក់ដោះទ័ល និងការបញ្ចាំដី ដើម្បីបំពេញ តំរូវការចំណាយបន្ទាន់ (ជាពិសេសចំណាយលើជំងឺ និងម្ហូបអាហារ), ការសងបំណុល (ការប្រាក់ខ្ពស់ដល់ ១០-១៥% ក្នុងមួយ ខែ) និងក្នុងករណីខ្លះការចាញ់ល្បែង, ត្រូវបានគេរាយការណ៍ថា ជាមូលហេតុមួយចំនួននៃភាពគ្មានដីធ្លី[៨] ។ ម្យ៉ាងទៀត អ្នកកាន់កាប់ដីតូចៗខ្លះដែលខ្វះខាតធាតុចូល ក៏បានលក់ដីដោយសារពុំមានលទ្ធភាពដាំដុះលើដីនោះដោយមានប្រសិទ្ធិភាព ។ ទី៣ ប្រជាជនមាតុភូមិនិវត្តន៍មកពីជំរំនៅតាមព្រំដែនថៃ គឺមានតិចនាក់ណាស់ដែលបានទទួលដីធ្លី ។ ទី៤ សហគមន៍ប្រជាជនដើមកំណើតវៀតណាមតូចមួយ គ្មានដីកសិកម្មឬដីលំនៅដ្ឋានទេ គឺគេរស់នៅលើទូក និងរកចិញ្ចឹមជីវិតដោយការនេសាទជាសំខាន់ ។ កំណើន ប្រជាជនគឺជាកត្តាមួយទៀតៈ ភូមិបាបោងមាន ៥៣៦គ្រួសារក្នុងឆ្នាំ២០០១ ធៀបនឹង ៤៣៤គ្រួសារនៅចុងទសវត្សរ៍ ១៩៨ៈ ការពុះចែកដីតូចទៅៗដែលកើតមានឡើង បានបង្កនូវវិសមភាព និងភាពគ្មានដីធ្លី[៩] ។

*នៅត្រពាំងប្រិយ* ខេត្តកំពង់ស្ពឺ ទំហំជាមធ្យមនៃការកាន់កាប់ដីកសិកម្មគឺ ០,៥៧ហិកតា ប៉ុន្តែគ្រួសារធូរធារមួយចំនួនតូច កាន់កាប់ដីពី ២-៣ហិកតាក្នុងមួយគ្រួសារ។ ប្រជាជនបានកើនឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗ (កើន ៧គ្រួសារក្នុងរយៈ ៥ឆ្នាំ ឬក៏ ២% ក្នុងមួយឆ្នាំ) ក៏ដីធ្លីមិនបានកើនឡើងទេ ដូច្នេះក៏គ្មានដីបន្ថែមនៅក្នុងភូមិសំរាប់ការបង្កបង្កើនផលដែរ ។ ថ្នាក់ដឹកនាំភូមិ និងចាស់ទុំបានបញ្ជាក់ថា មានគូរស្រករទើបរៀបការថ្មីដែលបន្តរស់នៅជាមួយឪពុកម្តាយពីព្រោះខ្វះខាតដីសង់ផ្ទះ ។វិសមភាពដី និងភាពគ្មានដីកើនឡើងដោយសារកសិករតូចៗខ្លះបានលក់ដីរបស់ខ្លួនទៅឱ្យកសិករធំៗ ។ មូលហេតុគឺគ្រួសារមួយចំនួនកាន់កាប់ដីតូចពេកមិនអំណោយផលខាងសេដ្ឋកិច្ច និងប្រហែលជាគ្មានមធ្យោបាយសំរាប់បង្កបង្កើនផលលើដីនោះ រឺក៏ប្រហែលជាជំពាក់បំណុលគេហើយត្រូវការប្រាក់ ។ អ្នកគ្មានដីបានកើនពី ៦-១០គ្រួសារពីឆ្នាំ១៩៩៧ ដល់ ២០០១ ។ ការជួលដីកើតមានឡើងនៅពេលដែលអ្នកក្រជួលដីរបស់ខ្លួនទៅឱ្យអ្នកធូរធារ ហើយចាកចេញពីភូមិទៅរកការងារធ្វើ ។ ម្យ៉ាងទៀតអ្នកទិញ ប្រហែលកាន់កាប់ដីជាប់នឹងដីរបស់អ្នកលក់ ហើយក៏ឆ្លៀតឱកាសនេះដើម្បីពង្រីកដីស្រែរបស់ខ្លួន ។ ដោយសារថ្លៃដីទៅតាមមូលដ្ឋានមានកំរិតទាបល្មម ដូច្នេះ ការទិញដូរវាងាយស្រួលចំពោះអ្នកមានប្រាក់ (ដីមួយកន្លែងទំហំ ៥០ម$^{២}$ អាចទិញបានក្នុងតំលៃយ៉ាងទាបត្រឹម

---

ជំនួញនៅផ្សារថ្មគោល ។ អ្នកខ្លះមានបងប្អូនរស់នៅបរទេសដែលផ្ញើលុយមកឱ្យគេម្តងម្កាល ។

[៧] នៅក្នុងប្រព័ន្ធទីផ្សារដែលមានលក្ខណៈមិនសុក្រិតណាមួយ មានអ្នកខ្លះរកបានធនធានច្រើនជាងអ្នកដទៃ ហើយលឿនទៀតផង អាចអនុញ្ញាតឱ្យគេទិញដី ។ ការទទួលបានធនធានបែបនេះត្រូវបានរៀបរាប់នៅក្នុង Chan និង Acharya (2002) ។

[៨] គេបានធ្វើការអះអាងយ៉ាងខ្លាំងក្លាថា ការចំណាយលើសពីប្រាក់ចំណូលដោយសារទីផ្សារផលិតផល បានដួលរលំក្នុងឆ្នាំ២០០០-២០០១ បន្ទាប់ពីទីផ្សារសំរាប់ផលិតផលនោះ បានឡើងខ្ពស់ដល់កំពូលនៅចន្លោះពីឆ្នាំ១៩៩៦ ដល់ ១៩៩៩ ។

[៩] មានទីផ្សារនៃការជួលដីសកម្មមួយដែលដំណើរការ ដើម្បីទប់ទល់បញ្ហានៃការបែកដីចេញជាចំណែក និងភាពមិនអាចរកបាននៃឧបករណ៍មធ្យោបាយ និងកំលាំងមនុស្ស ។

៥០០.០០០រៀល (១២៨ដុល្លារ) ក្នុងឆ្នាំ២០០១ ។ ក្នុងរឿងនេះ ចំនងសាច់ញាតិក្នុងចំនោមអ្នកមាន ក៏ជួយពង្រឹងស្ថានភាពដែរ ដោយគេប្រមូលផ្តុំធនធាន ដើម្បីបង្កើនទំហំទ្រព្យសម្បត្តិរបស់ពួកគេ ។ ឧទាហរណ៍ អ្នកឈ្មួញលក់ខាងរកស៊ីមួយចំនួននៅក្នុងភូមិនេះ បានរួមកំលាំងគ្នាប្រមូលផ្តុំដី ដោយសារពួកគេមានបងប្អូនជាអ្នកជំនួញធ្វូចារនៅផ្សារបាត់ដឹង (ប្រហែល ៣គ.មពីភូមិ) ។

*ភូមិព្រែកក្មេង* ក្នុងខេត្តកណ្តាល ក្នុងមួយឆ្នាំៗត្រូវលិចទឹកមួយរយៈ ។ តាមពិតភូមិទាំងមូលគឺជាវាលទំនាប ហើយមានដីតិចតួចណាស់ ដែលអាចដាំដុះជាធម្មតាបាននៅរដូវវស្សា ។ ជាង ៤០០គ្រួសារកាន់កាប់ដីសរុប ២៥០ហិកតានៅក្នុងភូមិ: ១/៣ នៃគ្រួសារនៅក្នុងភូមិជាអ្នកគ្មានដីធ្លី (តារាង១.១) ។ *ភូមិព្រែកក្មេង* ស្ថិតក្នុងចំណោមភូមិដែលបានថយចុះដីកសិកម្ម បើធៀបនឹង ១០ឆ្នាំមុន ។ ដីប្រហែល ៤០ហិកតា ត្រូវទុកចោលទំនេរ ដោយសារស្ថានីយ៍បូមទឹកឯកជនមួយបានឈប់ដំណើរការក្នុងឆ្នាំ១៩៩៤ បន្ទាប់ពីអ្នកភូមិជាច្រើននាក់មិនបានបង់ថ្លៃបូមទឹក ។ ដីមួយកន្លែងទៀតទំហំប្រមាណពី ៦០-១៥០ហិកតា មិនអាចដាំដុះបាន ឬសឹងគ្មានគេប្រើប្រាស់ ពីព្រោះវាបានក្លាយដីជាំទឹកបន្ទាប់ពីប្រលាយបង្ហូរទឹកចេញមួយ បានកកស្ទះកាលពី ៥ឆ្នាំមុន ។ សំពាធប្រជាជនបន្តកើនឡើង ដោយសារកំណើនជាលក្ខណៈធម្មជាតិ និងចំណាកស្រុកចូល (in-migration) ។ ទោះយ៉ាងនេះក្តី ការធ្វើកសិកម្មគឺជាវរបរចិញ្ចឹមជីវិតសំខាន់ទី២ នៅទីនេះ ហើយគ្មានវិបត្តិអ្វីធ្ងន់ធ្ងរទាក់ទិននឹងភាពគ្មានដីទេ ពីព្រោះការនេសាទ និងសកម្មភាពពាក់ព័ន្ធនឹងការនេសាទ បានជួយធានាជីវភាពពេញៗមួយឆ្នាំ ។

*នៅភូមិដងក្តារ* ខេត្តកំពង់ធំ គ្រួសារនានាបានបែងចែកដីស្រែគ្នាដែលមានមិនច្រើនទេ នៅក្នុងឆ្នាំ១៩៨១ ។ មនុស្សម្នាក់ៗបានទទួលដី ០,០៧ហិកតា ដោយមិនគិតពីអាយុ ដូច្នេះគ្រួសារមួយមានសមាជិក ៥នាក់ ទទួលបានដីតែ ០,៣៥ហិកតាប៉ុណ្ណោះសំរាប់ការដាំដុះជាធម្មតា ។ ភាពគ្មានដីជាចំហមិនសូវលេចធ្លោទេនៅក្នុងភូមិនេះ (ធៀបនឹងភូមិដទៃទៀតដែលមានលំនាំកាន់កាប់ដីធ្លីប្រហាក់ប្រហែលគ្នា) ដោយសារមូលហេតុពីរ ។ ទីមួយ ប្រជាជនអាចប្រកាន់យកវិធីដាំដុះផ្លាស់ទី (swidden cultivation) នៅក្នុងតំបន់ព្រៃបើកចំហ[១០] ។ ទីពីរ ក្នុងការរកចិញ្ចឹមជីវិតរបស់ប្រជាជន ការកាប់ឈើ ការប្រមូលអនុផលព្រៃឈើ និងការបរបាញ់សត្វ មានតួនាទីសំខាន់ជាងការដាំដុះ ។ ប៉ុន្តែក្នុងពេលថ្មីៗ គេឃើញមានការទិញ-លក់ដីខ្លះៗហើយ ។ ម្យ៉ាងទៀត តាំងពីពាក់កណ្តាលទសវត្សរ៍១៩៩០ មានការដាក់អនុវត្តសិទ្ធិលើព្រៃឈើកាន់តែខ្លាំងពីសំណាក់សម្បទានិក ដូច្នេះការដាំដុះផ្លាស់ទីជួបការពិបាក ហើយបញ្ហាកាន់តែធ្ងន់ធ្ងរទៀតដោយសារកំណើនប្រជាជន ។ ការវិវត្តន៍បែបនេះបង្ហាញថា យ៉ាងហោចណាស់ចំពោះបញ្ហាដីធ្លី ការជ្រៀតចូលនៃតំរូវការជំរុញដោយកំលាំងទីផ្សារ កំពុងតែចាក់ឫសនៅក្នុងភូមិ ។

នៅភូមិកំពង់ត្នោត ខេត្តកំពត ការកាន់កាប់ដីភាគច្រើនមានទំហំតូចទេ ពី ០,៥ ទៅ ០,៦ហិកតា ប៉ុន្តែមានចំនួនតូចដែរដែលមានដីដល់ ៣-៤ហិកតា ។ ភាពគ្មានដីធ្លីបានផុសឡើងក្នុងរយៈប៉ុន្មានឆ្នាំថ្មីៗដោយសារសំពាធប្រជាជនៈ ប្រជាជនបានកើន ៣៥% ក្នុងទសវត្សរ៍ចុងក្រោយនេះ ដែលរួមមានជនធ្វើមាតុភូមិនិវត្តន៍ ជនចំណាកស្រុកចូល (in-migrant) និងកំណើនប្រជាជនតាមលក្ខណៈធម្មជាតិ ។ នៅពេលមានគ្រួសារថ្មីកកើតឡើង ដីត្រូវបានពុះចែកជាបន្តបន្ទាប់រហូតដល់កំរិតមួយមិនអាចពុះចែកថែមទៀតបាន ហើយរឿងនេះក៏នាំឱ្យមានភាពគ្មានដីធ្លី ។ ការលក់ដីក៏កើតមានឡើង ដើម្បីយកប្រាក់ដោះស្រាយចំណាយបន្ទាន់ខ្លាំង ឬក៏សំរាប់សងបំណុល ។ ប៉ុន្តែដូចនៅភូមិព្រែកក្មេង និងភូមិដងក្តារដែរ ការងារមិនមែនកសិកម្ម ជាពិសេសការនេសាទទឹកប្រៃ និងការកែច្នៃផលនេសាទ គឺជាប្រភពដ៏សំខាន់សំរាប់ការចិញ្ចឹមជីវិត ហើយភាពគ្មានដីធ្លីមិនបានបង្កឱ្យមានស្ថានភាពវិបត្តិនៅក្នុងភូមិទេ ។

*សេចក្តីសង្ខេបជាទូទៅ*

- ទោះបីដីធ្លីត្រូវបែងចែក*ជាផ្លូវការ* ដោយមានលក្ខណៈស្មើភាពបង្គួរនៅចុងទសវត្សរ៍១៩៨០ក្តី ក៏ដំនើរការអនុវត្តន៍ពុំមានលក្ខណៈឯកភាពគ្នាល្អដូចគេតែងយល់ឃើញនោះទេ ។ មនុស្សជាច្រើនមិនបានចំណែកទេ ពីព្រោះមកដល់

[១០] ការដាំដុះផ្លាស់ទី គឺជាពាក្យបច្ចេកទេសទូទៅសំរាប់ការដាំដុះប្តូរកន្លែងចុះឡើង ។

ភូមិក្រោយពេលចែក, អ្នកខ្លះមានបញ្ហាក្នុងការបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន, ហើយនៅកន្លែងខ្លះទៀត ស្ថានភាពអសន្តិសុខមានកំរិតខ្ពស់ ។

- វិសមភាពនៃការកាន់កាប់ដី និងភាពគ្មានដី កើតឡើងដោយសារមូលហេតុជាច្រើនដូចជា ការបែងចែកដីមិនគ្រប់គ្រាន់, កំលាំងប្រជាសាស្ត្រ, ការថយចុះដីដាំដុះដោយសារការគ្រប់គ្រងមិនត្រឹមត្រូវ, ការថយចុះការដាំដុះផ្លាស់ទី, យន្តកម្ម និងសេដ្ឋកិច្ចវិមាត្រ (ក្នុងមូលដ្ឋានកសិកម្មជឿនលឿនពីរកន្លែង មានការពង្រឹងការកាន់កាប់ដី) និងការធ្លាក់ចុះប្រាក់កំរៃ ជាពិសេសកសិករធុនតូច ដោយសារស្ថានភាពទីផ្សារមិនអំណោយផល ។
- មានការជួលដីធ្លី ពីព្រោះអ្នកខ្លះដែលគ្មានលទ្ធភាពប្រើប្រាស់ដីរបស់ខ្លួន ដោយខ្វះខាតមធ្យោបាយបង្កបង្កើនផល បានជួលដីឱ្យគេ ។ ទង្វើបែបនេះ ធានាឱ្យមានការប្រើប្រាស់ដីមានប្រសិទ្ធិភាព ។

## ២.២. ការប្រើប្រាស់ដី និងលទ្ធភាពមានផលដំណាំដាស្បៀង

សន្តិសុខស្បៀងមានចីរភាពនៅក្នុងសង្គមកសិកម្មនានា ទាមទារឱ្យមានការប្រើប្រាស់ដី និងការបែងចែកផលចំណេញឱ្យបានសក្តិសិទ្ធិ ។ ផ្នែកនេះពិនិត្យមើលនូវទិដ្ឋភាពទាំងនេះ នៅក្នុងភូមិគំរូតាង ។

### *២.២.១. ការប្រើប្រាស់ដីសំរាប់កសិកម្មនៅភូមិក្រសាំង*

នៅភូមិក្រសាំង កសិករធ្វើស្រែប្រដេញទឹកនៅតំបន់ទំនាប នៅក្នុងរដូវប្រាំង (ទិន្នផល ៣-៣,៥តោនក្នុងមួយហិកតា) និងស្រូវលើដីខ្ពស់ធម្មតានៅរដូវវស្សា (ទិន្នផល ២,៥-៣,៥តោនក្នុងមួយហិកតា) ។ ស្រូវដាំលើដីខ្ពស់ ត្រូវការជីច្រើន ដោយសារគ្មានជីជាតិ ធម្មជាតិបន្សល់ទុកដោយទឹកសំរក ហើយស្រូវប្រភេទនេះទាមទារការស្ទូងដែលបង្កើនបន្ទុកចំណាយ ។ ប៉ុន្តែទឹកជំនន់ធ្ងន់ធ្ងរក្នុងឆ្នាំ២០០០ និង ២០០១ បានរារាំងដល់ការធ្វើស្រូវលើដីទាប១ក្នុងរយៈពីរឆ្នាំចុងក្រោយ ។ ទោះបីភូមិក្រសាំងមានអតិរេកផលស្រូវ (បានន័យថាជាភូមិនាំស្រូវចេញ) ក៏ដោយ ក៏កសិករខ្លះជួបកង្វះខាតស្រូវរហូតដល់ ៣ខែ ដោយសារគេគ្មានដី ឬមានដីតូចពេក ។ ម៉្យាងទៀត កសិករជាច្រើនត្រូវលក់ផលស្រូវបានថ្លៃយ៉ាងទាបនៅក្នុងរដូវច្រូតកាត់ ដើម្បីសងបំណុល និង/ឬដើម្បីដោះស្រាយចំណាយផ្សេង១ ហើយគេត្រូវទិញស្បៀងចូលនៅក្នុងខែដែលខ្វះខាត ។ ចំពោះកសិករទាំងនេះ ការបង្កបង្កើនផល មិនមែនជាមុខរបរមានចំណេញទេ ។ ដំណាំចំការ (ច្បារដំណាំនៅផ្ទះ, សាកវប្បកម្ម (horticulture), និងដំណាំហូបផ្លែ) គឺជាប្រភពស្បៀងដ៏សំខាន់ និងមានតួនាទីស្នូលក្នុងការរក្សាតុល្យភាពស្បៀងក្នុងខែមានកង្វះខាត ។ កសិករដាំក្រូច ចេក ស្វាយ ខ្នុរ ល្ហុង ត្របែក និងដើមឱសថផ្សេង១ ។ ប៉ុន្តែប្រាក់ចំណូលបានពីការធ្វើចំការមានតិចតួច ព្រោះដំណាំទាំងនេះភាគច្រើនទុកសំរាប់ហូបខ្លួនឯង ឬធ្វើការដោះដូរ មិនមែនសំរាប់លក់ទេ ។ ធៀបនឹងដីស្រែ ដីចំការមានការបែងចែកស្មើភាពជាងដែលបានជួយពង្រឹងដល់ស្ថានភាពសន្តិសុខស្បៀង ។

*នៅភូមិបាបោង* ការធ្វើស្រូវបែបទំនើបដែលគេអនុវត្តតាំងពីដើមទសវត្សរ៍១៩៩០ នាំឱ្យមានការប្រើប្រាស់យ៉ាងច្រើននូវពូជស្រូវមានទិន្នផលខ្ពស់ ជី និងគ្រឿងយន្ត ។ ការប្រើប្រាស់ធាតុចូលបានត្រឹមត្រូវ ធ្វើឱ្យទិន្នផលស្រូវកើនដល់ ៣-៤តោនក្នុងមួយហិកតា ប៉ុន្តែនៅស្រែខ្លះ ការប្រើប្រាស់មិនវិទ្យាសាស្ត្រនូវធាតុចូលគីមីបានបង្កើនជាតិអាស៊ីដនៅក្នុងដី ។ នាពេលថ្មី១ កសិករបានផ្លាស់ប្តូរការដាំដុះពីវិធីស្ទូង ទៅវិធីព្រួសវិញ ដើម្បីសំចៃលើចំណាយជួលពលកម្ម (ប្រហែល១២០.០០០រៀល/ហិកតា) ។ ប៉ុន្តែ តាមការអនុវត្តន៍បែបនេះ គេទទួលបានទិន្នផលខ្ពស់តែពីរដូវ បន្ទាប់មកទិន្នផលធ្លាក់ចុះ ។ ដូច្នេះកសិករជាច្រើនបានឆ្លាស់របៀបដាំដុះខុស១គ្នា ដើម្បីបានទទួលលទ្ធផលខ្ពស់បំផុត ។ ការសង្កេតនេះបានផ្តល់គំនិតថា ផលិតភាព និងអត្រាចំណេញមិនដើរស្របគ្នារហូតទេ ហើយកសិករក៏បានដឹងពីរឿងនេះដែរ ។ ថ្នាក់ដឹកនាំភូមិប្រាប់ថា ថ្លៃស្រូវខ្ពស់នៅកសិដ្ឋាន (៥០០រៀល/គ.ក) កាលពី ឆ្នាំ១៩៩៧-១៩៩៩ បានជួយអ្នកភូមិខាងផ្នែកហិរញ្ញវត្ថុយ៉ាងខ្លាំង: ដូចជា មានយ៉ាងតិច ២០គ្រួសារ បានសង់ផ្ទះថ្មី រឺជួស

ជុលផ្ទះចាស់ ។ ការធ្លាក់ថ្លៃផលិតផលនៅកសិដ្ឋាននៅក្រោយពេលនោះ បានប៉ះពាល់មិនល្អដល់សហគមន៍កសិករដែលក្នុងនេះមានយ៉ាងតិច ៧គ្រួសារបានបញ្ចាំដីស្រែទាំងអស់របស់ខ្លួន ។ បន្ទុកចំណាយខ្ពស់និងចំណូលទាប បានប៉ះពាល់ដល់សហគមន៍កសិករ ។ កសិករតូចៗ ថយចំណូលខ្លាំងជាង ពីព្រោះមានជំរើសតិចតួច ។ ទោះបីនៅបាបោងមានអតិរេកផលស្រូវក៏ដោយក៏ប្រហែល ១/៣ នៃគ្រួសារទាំងអស់ ជួបកង្វះខាតស្រូវពី ៣ ទៅ ៦ខែក្នុងមួយឆ្នាំៗ ដោយសារកង្វះ ឬការគ្មានដីប្រើប្រាស់ និងអសមត្ថភាពរបស់កសិករក្នុងការរក្សាទុកកសិផលរបស់ខ្លួនឱ្យបានពេញមួយឆ្នាំ ។ ពិតហើយ ដំណាំចំការបានជួយធានានូវស្បៀងបន្ថែមខ្លះ ប៉ុន្តែឥទ្ធិពលរបស់វា គឺមានកំណត់ ។

*ភូមិត្រពាំងប្រិយ* ជាភូមិខ្វះស្រូវ (ត្រូវទិញស្រូវចូល) ហើយជិត ៦០% នៃប្រជាជនជួបកង្វះខាតស្រូវ យ៉ាងហោចណាស់ពី ៣-៩ខែក្នុងមួយឆ្នាំៗ[១១] ។ ផលិតភាពស្រូវមិនឃើញរីកចំរើនទេក្នុងរយៈ៥ឆ្នាំចុងក្រោយ ។ បញ្ហាដីគុណភាពអន់ (ស្រែខ្លះមានដីប្រភេទខ្សាច់), ការប្រើប្រាស់ពូជស្រូវបុរាណផ្សេងៗ, និងការប្រើជីតិចតួច ឬគ្មានសោះ, នាំឱ្យស្រូវមានទិន្នផលតែ ៨០០-១.៣០០គ.ក/ហិកតា ។ ភ្លៀងធ្លាក់មិនទៀងទាត់ និងកង្វះខាតប្រព័ន្ធស្រោចស្រព បានអូសទាញកសិកម្មឱ្យនៅតែអន់ថយ ។ ស្រូវផលិតបានសំរាប់តែទុកហូបផ្ទាល់ខ្លួន គឺគ្មានផលិតផលនៅសល់ទុកសំរាប់លក់ទេ ។ អ្នកឆ្លើយសម្ភាសន៍រាយការណ៍ថាជាមធ្យមគ្រួសារមួយមានសមាជិក ៥នាក់ កាន់កាប់ដីស្រែមិនលើសពី ០,៥ហិកតាទេ ដូច្នេះពុំអាចមានសេដ្ឋកិច្ចវិមាត្រ និងមិនអាចមានអតិរេកស្រូវសំរាប់ទីផ្សារទេ ។ រហូតមកដល់ពេលនេះ មានតែកសិករធំៗ ប្រហែល ៤-៥នាក់ប៉ុណ្ណោះ ទទួលបានអត្ថប្រយោជន៍ពីកសិកម្មទំនើប ។ ភូមិនេះមានសក្តានុពលក្នុងការដាំដំណាំសំរាប់លក់យកប្រាក់ (cash crops) ដូចជាឪឡឹក ដំឡូងជ្វា និងបន្លែ ។ ដោយសារកង្វះខាតដើមទុន និងទីផ្សារ មានតែគ្រួសារធូរធារមួយចំនួនតូចប៉ុណ្ណោះ ដែលអាចធ្វើដំណាំប្រភេទនេះ និងអាចបានចំណេញដល់ទៅ ១០០.០០០-២០០.០០០រៀលក្នុងម្នាក់ៗក្នុងមួយឆ្នាំៗ ។ តាមសំដីរបស់អ្នកភូមិ ចំនួនកសិករដាំដំណាំលក់យកប្រាក់បានធ្លាក់ចុះជាលំដាប់ ពីព្រោះនេះជាសកម្មភាពចំណាយធាតុចូលច្រើន និងផ្តល់កំរៃតិចនៅក្នុងភូមិនេះ ។ ក្រៅពីកង្វះខាតទឹក និងគ្រោះថ្នាក់ខាងទីផ្សារ គេនិយាយថា សត្វចិញ្ចឹមលែងឱ្យដើរសេរីដែលចូលស៊ីដំណាំ គឺជាបញ្ហាចោទមួយទៀត ។ ដូច្នេះកសិករធំៗបានប្តូរទៅធ្វើស្រែ ឯកសិករតូចៗគេប្រឹងប្រែងចាកចេញពីរបរកសិកម្មតែម្តង ។

*នៅភូមិព្រែកក្មេង* ការធ្វើស្រូវគឺជាប្រភពសំខាន់ទីពីរ ក្នុងការចិញ្ចឹមជីវិតបន្ទាប់ពីការនេសាទ ប៉ុន្តែគេដាំស្រូវតែលើផ្ទៃដីប្រមាណ ១៣៧ហិកតាប៉ុណ្ណោះ (ក្នុងផ្ទៃដីសរុប ២៥២ហិកតា) ដោយសារទីតាំងភូមិសាស្ត្រនៃភូមិ ។ កសិករដាំស្រូវនៅរដូវប្រាំងពេលទឹកស្រក: ស្រូវវស្សាមិនអាចដាំនៅទីនេះទេ ពីព្រោះភូមិនេះលិចទឹកអស់ ៦ខែ ។ កសិករស្រោចស្រពដំណាំដោយប្រើម៉ាស៊ីនបូមយកទឹកពីអូរ និងបឹងបួរ ។ ដីមានផលិតភាពខ្ពស់ដោយសារដីល្បាប់បន្សល់ទុក ដោយការស្រកនៃទឹកទន្លេមេគង្គ ។ គ្មានអ្វីគួរភ្ញាក់ផ្អើលទេដែលទិន្នផលស្រូវបានខ្ពស់ដល់ ៣-៣,៥តោនក្នុងមួយហិកតា ទៅតាមពូជស្រូវដែលគេដាំ ។ ពីឆ្នាំ១៩៧៩-១៩៩៩ កសិករភាគច្រើនប្រើពូជស្រូវមូលដ្ឋានមួយ ដែលត្រូវការរយៈពេលដាំដុះ ៤ខែ ។ ចាប់ពីឆ្នាំ១៩៩៩ កសិករភាគច្រើនបានប្តូរទៅប្រើប្រាស់ពូជស្រូវមានទិន្នផលខ្ពស់ ដែលអាចច្រូតកាត់បានក្នុងរយៈ ៣ខែ ហើយផ្តល់ទិន្នផលមួយតោនខ្ពស់ជាងពូជស្រូវមូលដ្ឋាន ។ កសិករត្រូវជួលម៉ាស៊ីនកសិកម្ម ពីព្រោះគ្មានលទ្ធភាពទិញវាទេ ហើយទឹកជន់លិចអស់រយៈ៦ខែ មិនអនុញ្ញាតឱ្យចិញ្ចឹមសត្វអូសទាញនោះទេ (ប៉ុន្តែកាលពីមុនកសិករជួល សត្វអូសទាញ) ។ លើសពីនេះទៀត គេជួលពលកម្មពីអ្នកគ្មានដីធ្លី ។ ចំណាយសរុបសំរាប់ធ្វើស្រែ ១ហិកតា គឺប្រហែល ៥០០.០០០រៀល ។ ធៀបនឹងថ្លៃស្រូវនៅមូលដ្ឋាន (៣៥០រៀលក្នុងមួយគ.ក) ផលស្រូវក្នុងដីមួយហិកតា អាចផ្តល់ចំណូលសរុបប្រមាណពី ១,០-១,៤លានរៀល (២៥០ដុល្លារទៅ ៣៥០ដុល្លារ) ។ ក្រោយពីកាត់កងចំណាយហើយ ចំណូលសុទ្ធក្នុងដីស្រែមួយហិកតា គឺប្រហែល ១២០-២២០ដុល្លារ ។ ទោះបីជាផលិតភាពមានកំរិតខ្ពស់ក៏ដោយ ក៏ផលស្រូវក្នុងភូមិមិនគ្រប់គ្រាន់សំរាប់ការហូបចុកទេដោយសារតែចំនួនដី និងការបែងចែកដី ។

[១១] ទិន្នន័យលំអិតថែមទៀត មានចុះនៅក្នុងអង្កេតបែបគុណភាពនៃការសិក្សានេះ ។ ចំពោះទិន្នន័យទាក់ទិននឹងឆ្នាំ១៩៩៧ សូមអាចឯកសារ Murshid (1998) ។

តាមសំដីអ្នកភូមិដែលមានការយល់ដឹងច្រើន ប្រហែល ១០% នៃគ្រួសារកសិករនៅភូមិនេះ អាចផលិតស្រូវមានអតិរេកសំរាប់លក់, ២០% អាចធ្វើស្រូវបានគ្រប់គ្រាន់សំរាប់ហូប និង ៧០% ទៀតត្រូវទិញស្រូវចូលយ៉ាងហោចណាស់ក៏សំរាប់ ២-៣ខែក្នុងមួយឆ្នាំៗដែរ ។ ដូចបានលើករួចហើយ ប្រហែល ១/៣នៃគ្រួសារក្នុងភូមិ គ្មានដីទេ ។ ចំពោះដំណាំមិនសំរាប់ហូប កសិករដាំកក់សំរាប់លក់ចេញទៅខេត្តផ្សេងៗទៀត និងទៅវៀតណាម ប៉ុន្តែការដាំកក់បានថយចុះក្នុងរយៈ៥ឆ្នាំចុងក្រោយ ពីព្រោះដំណាំស្រូវផ្តល់កំរៃច្រើនជាង ។ គ្រួសារមួយចំនួនតូចដាំល្ហុ ពោត និងបន្លែ ។ ភូមិនេះត្រូវនាំចូលស្រូវ បន្លែ និងសាច់ ប៉ុន្តែមានផលត្រីសំរាប់នាំចេញ ។ ដោយសារមានទីតាំងនៅជិតក្រុងភ្នំពេញ ភូមិនេះទាក់ទាញជំនួយអភិវឌ្ឍន៍បានយ៉ាងច្រើនដែលបានជួយកាត់បន្ថយបញ្ហាផ្សេងៗទាក់ទិននឹងកង្វះខាតស្បៀង[១២] ។

*នៅភូមិដងក្តារ* ការធ្វើស្រែជាប្រភពប្រាក់ចំណូលដ៏សំខាន់តែមិនមែនជាប្រភពធំជាងគេទេ ។ កសិករធ្វើស្រែផង និងធ្វើចំការផង ។ ស្រូវមានធ្វើជាទៀងទាត់លើផ្ទៃដី ១២៧ហិកតា កាន់កាប់ដោយ ២៨០គ្រួសារ ។ ដីមានគុណភាពអន់ ដែលតាមធម្មតាអាចផ្តល់ទិន្នផលជាអតិបរមាប្រហែល ១,៤តោនក្នុងមួយហិកតា បើសិនមិនប្រើធាតុចូលទំនើបច្រើនៗ ។ បច្ចុប្បន្នមាន ៣០គ្រួសារគត់ដែលមានលទ្ធភាពទិញជីគីមី ហើយភូមិនេះស្ទើរតែគ្មានប្រព័ន្ធស្រោចស្រពសំរាប់គ្រប់គ្រងទឹក ។ ផលស្រូវមានគ្រប់គ្រាន់សំរាប់ប្រហែលជា ១/៣នៃតំរូវការស្រូវអង្ករក្នុងភូមិ ហើយសល់ពីនេះត្រូវទិញពីក្រៅ ។ គេរាយការណ៍ថា មានកសិករ ១០គ្រួសារបានទិញដីពីអ្នកដទៃ និងផលិតស្រូវបានលើសពីតំរូវការសំរាប់លក់ចេញ ។ ១០គ្រួសារទៀត ផលិតស្រូវបានគ្រប់គ្រាន់សំរាប់ហូបខ្លួនឯងប៉ុណ្ណោះ ឯគ្រួសារក្រៅពីនេះត្រូវទិញស្រូវពីកសិករធំៗ ឬពីឈ្មួញ ។ ការធ្វើចំការរួមមានការដាំស្វាយចន្ទី និងចេក នៅលើដីរានព្រៃបាន ។ ដីនេះមិនមែនជារបស់អ្នកភូមិទេៈ សព្វថ្ងៃវាស្ថិតក្នុងតំបន់ព្រៃសម្បទាន ប៉ុន្តែអ្នកភូមិអះអាងថាបានធ្វើកសិកម្មផ្លាស់ទី និង/ឬធ្វើចំការលើដីនេះជាង ៥០ឆ្នាំហើយ ។ កសិករបានត្រួសត្រាយដីបន្ថែមជាទៀងទាត់ ដើម្បីឆ្លើយតបនឹងកំណើនប្រជាជនយ៉ាងលឿន ។ បច្ចុប្បន្ននេះ មាន ៥០គ្រួសារកំពុងធ្វើកសិកម្មផ្លាស់ទី ធៀបនឹង ២០គ្រួសារកាលពីសម័យមុនសង្គ្រាម[១៣] ។ កសិករធ្វើកសិកម្មផ្លាស់ទី គ្មានដីធ្វើស្រែអចិន្ត្រៃយ៍ទេ ។ ពួកសម្បទានិកព្រៃឈើបានព្យាយាមទប់ស្កាត់ការពង្រីកដីបែបនេះ ប៉ុន្តែមិនបានជោគជ័យពេញលេញទេ ។ ឥឡូវនេះ គេបានផ្សះផ្សារដោយអនុញ្ញាតឱ្យអ្នកភូមិធ្វើកសិកម្មផ្លាស់ទីនៅផ្នែកខាងក្នុងនៃព្រៃឈើដែលស្ថិតនៅឆ្ងាយពីភូមិ និងពីភ្នែកមហាជន ។ ក្នុងកសិកម្មផ្លាស់ទី ផលិតភាពមានកំរិតទាបបើធៀបនឹងផលិតភាពនៃដីស្រែអចិន្ត្រៃយ៍ ។ ទាំង ៥០គ្រួសារដែលធ្វើស្រែចល័ត គឺជាអ្នកក្រីក្រជាងគេនៅក្នុងភូមិ ។ ការសិក្សាពិស្តារបង្ហាញថា កសិកម្មផ្លាស់ទីផ្តល់ចំនួលដុលប្រហែល ១.០០០រៀលក្នុងមួយថ្ងៃក្នុងពលករម្នាក់ គឺតិចជាងការងារគ្មានជំនាញផ្សេងទៀតដែលច្រើនបានកំរៃប្រហែល ២.៥០០រៀលក្នុងមួយថ្ងៃ ។ កសិករនៅបន្តធ្វើកសិកម្មផ្លាស់ទី ពីព្រោះកង្វល់ចំបងរបស់គេ គឺធានាឱ្យមានស្រូវអង្ករនៅក្នុងផ្ទះ ។

*ភូមិកំពង់ត្នោត* ពឹងផ្អែកលើស្រូវវស្សា និងការនេសាទត្រីសមុទ្រ ។ ស្រែលាតសន្ធឹងលើផ្ទៃដីប្រមាណ១៥០ហិកតា ឯប្រជាជនមាន ៣៣៩គ្រួសារ ។ ភូមិនេះមិនស្ថិតក្នុងតំបន់ងាយប៉ះពាល់ដោយគ្រោះធម្មជាតិដូចជាទឹកជំនន់ និងការរាំងស្ងួតនោះទេ ។ ផលិតផលស្រូវជាមធ្យមបានតែ ៨០០-១.២០០គ.កក្នុងមួយហិកតា ពីព្រោះគេប្រើធាតុចូលទំនើបតែតិចតួច ឯដីស្រែក៏តូចៗ មិនអាចប្រើប្រាស់បានប្រសិទ្ធិភាពល្អ ហើយនៅកន្លែងខ្លះដីមានជាតិប្រៃមិនអាចមានទិន្នផលខ្ពស់ទេ ។ ទោះបីមានកត្តាមិនអំណោយផលដូច្នេះក្តី ក៏ឃើញមានអតិរេកផលស្រូវមួយចំនួនតូចដែរ (ទាក់ទិននឹងកសិករប្រហែល ១២គ្រួសារ) ប៉ុន្តែមានគ្រួសារងាយរងគ្រោះជាច្រើន ត្រូវជួបនឹងកង្វះខាតស្រូវអង្ករក្នុងមួយរយៈពេលជារៀងរាល់ឆ្នាំ ។ ធៀបនឹងតំបន់ឯទៀតៗនៃ ប្រទេសកម្ពុជា ថ្លៃស្រូវមិនសូវចុះឡើងខ្លាំងទេ (ស្រូវថ្លៃប្រហែល ៥០០រៀលក្នុងមួយគ.ក) ប៉ុន្តែកសិករមិនអាចផលិតស្រូវបាន ច្រើនថែមទៀត ដោយសារកំហិតនៃការផ្គត់ផ្គង់ដែលបណ្តាលមកពីដីស្រែមានទំហំតូច ។ ដូច្នេះ

[១២] ស្ទើរតែរាល់ឆ្នាំក្នុងរយៈពេលថ្មីៗនេះ ភូមិព្រែកក្មេងបានទទួលជំនួយម្ហូបអាហារពី NGOs ក្នុងរដូវទឹកជំនន់ ។

[១៣] ក្នុងឯកសារនេះសម័យសង្គ្រាម សំដៅដល់រយៈពេលពីឆ្នាំ១៩៧០-១៩៩២ ។

ភូមិនេះត្រូវការស្រូវអង្ករបន្ថែម ពីខេត្តតាកែវដែលនៅជិតខាង ដើម្បីបង្គ្រប់ការហូបចុក ។ គ្រួសារភាគច្រើន មានដីឡូត៍ជុំវិញផ្ទះ ហើយគេដាំបន្លែ និងឈើហូប ផ្លែ ដែលអាចប្រមូលផលបានទាំងរដូវវស្សា និងរដូវប្រាំង ។ ដើមឈើហូបផ្លែ និងដើមដូង ច្រើនដុះនៅក្បែរផ្ទះ តែដើមឈើខ្លះ ទៀតដុះពាសវាលពាសកាល ។ ដូងខ្ចីមួយផ្លែលក់បាន ២០០រៀល ដូច្នេះបើក្នុងគ្រួសារមួយមានដូង ២០-២៥ដើម គេអាចរក កំរៃបាន ៨០.០០០-១០០.០០០រៀលក្នុងមួយឆ្នាំ ។ ថ្លៃដូងនៅកសិដ្ឋានគឺ ២០០រៀល តែនៅភ្នំពេញអាចលក់បាន ៨០០រៀល ។ តាមធម្មតា ឈ្មួញកណ្តាលមករកទិញដូងដល់ៗភូមិតែម្តង ។ នៅក្នុងភូមិមានដើមត្នោតច្រើន តែគ្មានអ្នកណាធ្វើស្ករត្នោតទេ ពីព្រោះដីមានជាតិអំបិលច្រើន ។

កសិករធូរធារនៅកំពង់ត្នោត គេដាំសណ្តែកដី ល្ង ឪឡឹក ដូង ពោត និងសណ្តែកសៀង បន្ថែមពីលើការដាំស្រូវ ។ តាមមធ្យោបាយនេះគេអាចការពារខ្លួនទប់ទល់នឹងកង្វះខាតស្បៀងតាមរដូវ ហើយអាចរកចំណូលបន្ថែមបានខ្លះទៀត ។ ចំណាយធាតុចូលសំរាប់ដាំដំណាំលក់យកប្រាក់ ដូចជា សណ្តែកដី ក្នុងទំហំដីកន្លះហិកតា ត្រូវចំណាយយ៉ាងតិច ១០០.០០០រៀលដែលរួមមានចំណាយទិញជី គ្រាប់ពូជ ថ្នាំសំលាប់សត្វល្អិត និងការស្រោចស្រព ។ ផលប្រមូលបាន អាចមានតំលៃ ២០០.០០០រៀល ។ ពិតហើយ អ្នកមានប្រាក់ទើបអាចដាំដំណាំទាំងនេះបាន ។ គ្រួសារខ្លះខ្ចីទុនពីអ្នកចងការប្រាក់ក្នុងអត្រា ការប្រាក់ ១៥% ក្នុងមួយខែ ។ បើសិនប្រមូលផលបានជាធម្មតា ចំណូលសុទ្ធត្រូវចំណាយលើការបង់ការប្រាក់អស់ពាក់កណ្តាលហើយ ។ តែបើដំណាំមានជំងឺគេអាចខាតបង់ ។ មានគ្រួសារមួយភាគតូចទេ (តិចជាង ១០%) ដែលដាំដំណាំសំរាប់លក់យកប្រាក់ ឯគ្រួសារឯទៀតចូលចិត្តធ្វើនេសាទ ពីព្រោះការនេសាទផ្តល់ប្រាក់ចំណូលប្រចាំថ្ងៃ និងឃើញហាក់ដូចជាមិនសូវមានគ្រោះថ្នាក់ ។

### *២.២.២. ឥទ្ធិពលនៃការប្រើប្រាស់គ្រឿងយន្តកសិកម្ម*

នៅឆ្នាំ១៩៩៣ ការធ្វើយន្តកម្មកសិកម្ម បានគេចាប់ផ្តើមនៅភូមិ ក្រសាំង បាបោង និង ព្រៃកក្អែង (សំរាប់ការភ្ជួរដី កាណូត និងការដឹកជញ្ជូន), ត្រពាំងប្រិយ (សំរាប់ការដឹកជញ្ជូន), កំពង់ត្នោត (សំរាប់កាណូត) ។ ភូមិដងក្តារមិនទាន់មានឧបករណ៍គ្រឿងយន្តអ្វីក្រៅពីរណាអារឈើទេ ។ មានម៉ាស៊ីនបីប្រភេទដែលគេប្រើប្រាស់ : ១. ម៉ាស៊ីនប្រើប្រេងម៉ាស៊ូតសំរាប់បូមទឹក បោកស្រូវ អូសកាណូត និងម៉ាស៊ីនភ្លើង, ២. គោយន្តសំរាប់បូមទឹក ដឹកជញ្ជូន និងភ្ជួរ/រាស់, ៣. ត្រាក់ទ័រសំរាប់ភ្ជួររាស់ និងដឹកជញ្ជូន ។ កសិករធូរធារមានដីស្រែច្រើន ក៏មានគ្រឿងម៉ាស៊ីនដែរ (ក្រសាំង បាបោង និងព្រៃកក្អែង) ។ កសិករភាគច្រើនប្រើបរិក្ខារកសិកម្មលើដីរបស់គាត់ផ្ទាល់ ព្រមទាំងជួលវាបន្ថែមផងដែរ-ថ្លៃឈ្នួលភ្ជួរដីទំហំ១ហិកតា គឺ ៩០០បាត (២៣ដុល្លារ) ។ អ្នកទាំងនោះក៏ជាឈ្មួញកណ្តាលក្នុងការជួញដូរស្រូវ ពីព្រោះមានទាំងមធ្យោបាយដឹកជញ្ជូន មានទាំងដើមទុនសំរាប់ទិញស្រូវមក ស្តុកទុកនៅរដូវប្រមូលផល សំរាប់បញ្ចេញលក់នៅពេលក្រោយ ។ តាមវិធីនេះពួកគេរកបានប្រាក់ចំណេញពីច្រើនប្រភព ។ ផ្ទុយ ទៅវិញ កសិករធុនតូចត្រូវជួលម៉ាស៊ីនគេ ពីព្រោះគ្មានលទ្ធភាពទិញវា ។ រឿងនេះបង្ហាញនូវលំហូរចេញនៃប្រាក់ចំណូល ពីព្រោះអាចមានការខ្ចីប្រាក់ក្នុងអត្រាការប្រាក់ខ្ពស់ ។ម្យ៉ាងទៀត បន្ទុកចំណាយក្នុងការប្រើប្រាស់ និងជួសជុល មានកំរិតខ្ពស់ ដោយសារអ្នកមូលដ្ឋានគ្មានចំណេះដឹងគ្រប់គ្រាន់ខាងគ្រឿងយន្ត គ្មានការផ្គត់ផ្គង់គ្រឿងបន្លាស់ទៀងទាត់ ហើយប្រេងម៉ាស៊ូតត្រូវនាំចូលពីក្រៅ និងមានថ្លៃខ្ពស់ ។ ប៉ុន្តែជាញឹកញយ បន្ទុកចំណាយត្រូវរ៉ាប់រងដោយអ្នកមកជួលម៉ាស៊ីនគេ ពីព្រោះម្ចាស់ម៉ាស៊ីនជាអ្នកកំណត់ថ្លៃឈ្នួល ។ ក្នុងន័យនេះ ការប្រើប្រាស់គ្រឿងយន្ត មានតំលៃខ្ពស់ច្រើនជាងសំរាប់កសិករធុនតូច ហើយដោយសារកត្តានេះ កំរិតចំនេញរបស់ពួកគេជាទូទៅមានកំរិតទាប គ្មានសោះឬអវិជ្ជមាន ។ ទាំងនេះមិនមែនមានន័យថា ការធ្វើយន្តកម្មកសិកម្មសុទ្ធតែមានផលអាក្រក់នោះទេ ប៉ុន្តែវាបង្ហាញថា អត្ថប្រយោជន៍នៃបច្ចេកវិទ្យាគ្រឿងយន្តជារឿយៗបែងចែកមិនស្មើគ្នាទេរវាង

កសិករធុនតូច និងធុនធំ គឺកសិករធុនតូចទទួលបានផលតិចជាង[១៤] ។ ពិនិត្យតាមផលវិបាកទាំងនេះ គេគួរចោទសួរថាហេតុអ្វីបានជាកសិករទទួលយកការប្រើប្រាស់គ្រឿងយន្ត? គេបានលើកឡើងនូវមូលហេតុពីរ ។ ទី១ វាមានការលំបាកក្នុងការបន្តប្រើប្រាស់បច្ចេកវិទ្យាចាស់ នៅពេលមានបច្ចេកវិទ្យាថ្មីហើយ ដោយសារបច្ចេកវិទ្យាថ្មីមានផលិតភាពខ្ពស់ជាង ។ ទី២ ទំនាក់ទំនងទីផ្សារទំនើប តែងលើកទឹកចិត្តដល់ការប្រើប្រាស់បច្ចេកវិទ្យាថ្មី ហើយបច្ចេកវិទ្យាទាំងនេះវាមកជំនួសទំនាក់ទំនងជួយគ្នាទៅវិញទៅមក (ឧទាហរណ៍ ការប្រវាស់ដៃ) ដែលត្រូវមានជាចាំបាច់ដើម្បីឱ្យវិធីសាស្ត្របុរាណបន្តរស់រានមានជីវិត ។

*សេចក្តីសង្ខេបទូទៅ*

- នៅគ្រប់ភូមិទាំងអស់ មានកសិករមួយចំនួនត្រូវជួបកង្វះខាតស្រូវក្នុងខែមួយចំនួន ។ នៅភូមិអន់ថយខ្លាំង កង្វះខាតនេះបណ្តាលមកពីផលិតភាពនិងផលិតកម្មទាប (មួយចំណែកដោយសារគុណភាពដីអន់) ព្រមទាំងវិសមភាពនៃកម្មសិទ្ធិដី ហើយនៅភូមិខ្លះទៀតគឺ វិសមភាពខ្ពស់ខាងកម្មសិទ្ធិដី និងភាពគ្មានដីធ្លី ។ កង្វះខាតស្រូវនៅកំរិតគ្រួសារកើតចេញមកពីដីទំហំតូច ភាពគ្មានដីធ្លី និងអនុបាតនៃថ្លៃធាតុចូល ធៀបនឹងថ្លៃផលិតផលដែលមិនអំណោយផល ។ នៅពេលខ្លះ អាកាសធាតុមិនល្អក៏មានផលប៉ះពាល់ដល់ផលដំណាំផងដែរ ។
- មានការទាញយកទឹកតិចតួចទេ សំរាប់ការស្រោចស្រព ហើយនេះគឺជាការខ្វះចន្លោះដ៏ចំបងមួយក្នុងដំណើរការធ្វើទំនើបភាវូបនីយកម្ម ។
- ជាទូទៅដីតូចៗ គឺជាឧបសគ្គចំពោះការវិនិយោគ និងផលិតកម្ម ។ កសិករធុនតូច ពុំមានមធ្យោបាយ (ហើយជាលក្ខណៈបច្ចេកទេសក៏មិនអាចធ្វើកើតដែរ) ដើម្បីធ្វើវិនិយោគឱ្យមានប្រសិទ្ធិភាព និងទទួលផលបានសមស្របអំពីដីធ្លីមានទំហំតូចពេក ។ ជាលទ្ធផល ផលវិបាកផលិតកម្ម និងកំរិតចំណេញនៅក្នុងកសិដ្ឋានដែលតូចៗខ្លាំង គឺមានកំរិតទាប ។
- ការប្រើគ្រឿងយន្តសំរាប់ធ្វើប្រតិបត្តិការភ្ជួររាស់រៀបចំដីធ្លី និងធ្វើពាណិជ្ជកម្មខាងកសិកម្ម អាចជួយបង្កើនផលិតភាព និងប្រសិទ្ធិភាព ប៉ុន្តែទន្ទឹមគ្នានេះ វាបង្កើនវិសមភាព និងកាត់បន្ថយការប្រើកំលាំងពលកម្ម ។ ការធ្វើពាណិជ្ជកម្ម អាចចូលមកជំនួសទំនាក់ទំនងជួយគ្នាទៅវិញទៅមក ដូច្នេះវាបង្កើននូវតំរូវការប្រាក់កាស ដែលតែងមានថ្លៃខ្ពស់ និងមានលក្ខណៈកេញប្រវ័ញ្ច ពីព្រោះប្រភពចំបងនៃប្រាក់កាសគឺអ្នកចងការប្រាក់ ។

## ២.៣. សកម្មភាពមិនមែនកសិកម្ម

ដូចសង្គមកសិកម្មឯទៀតដែរ ក្នុងភូមិសិក្សាទាំង ៦ គេឃើញមានសកម្មភាពមិនមែនកសិកម្ម (non-farm activity) និងសកម្មភាពក្រៅកសិដ្ឋាន (off-farm activity) យ៉ាងច្រើន ។ ក្នុងករណីខ្លះ សកម្មភាពទាំងនេះវាបំពេញឱ្យការងារធ្វើស្រែ និងក្នុងករណីខ្លះទៀត វាសំរាប់ផ្តល់ចំណូលបន្ថែម ។ វាផ្តល់ការងារចំពោះអ្នកខ្លះ និងជួយបំពេញប្រាក់ចំណូលបានពីកសិកម្ម ។ វាដើរតួជាទ្រនាប់ទប់ទល់នឹងការខូចខាតដំណាំ និងកង្វះស្បៀងប្រចាំរដូវ ។ ផ្នែកនេះពិពណ៌នាតែពីសកម្មភាពមិនមែនកសិកម្ម និងសកម្មភាពក្រៅកសិដ្ឋានធំៗដែលមាននៅក្នុងភូមិទាំងនេះ ។

### *២.៣.១. ការនេសាទនិងការកែច្នៃត្រី*

#### *២.៣.១.១. ការនេសាទ*

នៅភូមិក្រសាំង ភូមិបាបោង ភូមិព្រៃកក្អែង និងកំពង់ត្នោត គ្រួសារភាគច្រើននេសាទត្រីនៅតាមបឹង ទន្លេ វាលស្រែ និង

[១៤] ការបែងចែកផលចំណេញមិនស្មើភាពបែបនេះ ត្រូវបានសង្កេតឃើញក្នុងតំបន់ឯទៀតនៅទ្វីបអាស៊ី ។ សូមមើល Griffen (1974); Pearse (1980); Farmer (1977) ។

សមុទ្រ[១៥] សំរាប់ហូបខ្លួនឯង ។ រហូតមកដល់ចុងឆ្នាំ១៩៩០ ភូមិទាំងអស់ លើកលែងតែភូមិកំពង់ត្នោតដែលស្ថិតនៅតាមមាត់សមុទ្រ បានជួបប្រទះការរារាំងយ៉ាងខ្លាំងដោយសារប្រព័ន្ធសម្បទាន ។ ការបន្ធូរប្រព័ន្ធសម្បទាន បានជួយបង្កើនប្រាក់ចំណូល (និងការហូបចុក) របស់អ្នកភូមិ និងបានកាត់បន្ថយទំនាស់ ។ ក្រៅពីការនេសាទត្រី ប្រជាជនប្រមូលខ្យង លាស គ្រំ រុក្ខជាតិ និងសត្វក្នុងទឹកដទៃទៀតដែលអាចហូបបាន ។ គ្រួសារក្រីក្រដែលគ្មាន ឬមានតិចតួចនូវពលកម្មបុរសជាអ្នកប្រមូលភោគផលទាំងនេះ ហើយគ្រួសារស្ត្រីដឹកនាំមួយគ្រួអាចរកបាន ៣.០០០-៥.០០០រៀលក្នុងមួយថ្ងៃ (ឯគ្រួសារបុរសដឹកនាំ អាចរកចំណូលបាន ៥.០០០-១០.០០០រៀលក្នុងមួយថ្ងៃសំរាប់សកម្មភាពដូចគ្នា) ។ មានបញ្ហារួមគ្នាបីដែលគេជួបប្រទះ នៅគ្រប់កន្លែង គឺមានៈ ១. ការប្រើប្រាស់វិធីនេសាទដែលធ្វើឱ្យខូចបរិស្ថាន និងកាត់បន្ថយស្តុកត្រី, ២. កំនើនចំនួនប្រជាជន ប្រជែងគ្នាដណ្តើមស្តុកត្រី, ៣. ប្រជាជនមួយចំនួនខ្វះខាតឧបករណ៍ទំនើប ជាពិសេសប្រតិបត្តិករធុនតូច ។

នៅរដូវនេសាទ អ្នកនេសាទសំរាប់ពាណិជ្ជកម្មនៃភូមិក្រសាំង ជាទូទៅចេញនេសាទ ២-៣យប់ក្នុងមួយលើកៗ ដើម្បីចាប់ត្រី កង្កែប ពស់ អន្ទង់ និងសត្វស្លាប ដោយរកបានប្រហែល ១៥-២០គ.ក[១៦] ។ កង្កែប ពស់ អន្ទង់ គេប្រលាក់ហាល ឬប្រស់ទុកសំរាប់ដឹកតាមទូកយកទៅលក់នៅថៃ ។ ការខិតខំលក់ផលិតផលដើម្បីយកប្រាក់សងបំណុល ឬដោះស្រាយចំណាយក្នុងគ្រួសារ គឺមានកំរិតខ្ពស់ណាស់ ហើយប្រជាជនមួយចំនួនក្នុងស្រទាប់អ្នកក្រីក្រ បានត្អូញត្អែរពីកង្វះខាតជាតិប្រូតេអ៊ីន (ទោះបីក្នុងរដូវសំបូរត្រីក៏ដោយ) ដោយសារគេនាំផលិតផលនេសាទចេញ ជាជាងទុកវាហូប ។ ក្នុងរយៈប៉ុន្មានចុងឆ្នាំចុងក្រោយមានការ ធ្លាក់ចុះយ៉ាងខ្លាំងនូវបរិមាណត្រី ដោយសារប្រជាជនបានចាប់ផ្តើមប្រើឧបករណ៍ដែលធ្វើឱ្យខូចបរិស្ថាន ។ ការធ្លាក់ចុះបរិមាណ ត្រីនេះ បានកាត់បន្ថយឥទ្ធិពលវិជ្ជមាននៃការលុបសម្បទាន ។ គេគួរបញ្ជាក់ដែរថា ក្នុងភូមិនេះមាន ២គ្រួសារបានគ្រប់គ្រងការ នាំចេញទាំងអស់ ។

អ្នកនេសាទនៅភូមិបាបោង អាចរកចំនួលបាន ២០.០០០រៀលក្នុងមួយថ្ងៃ នៅក្នុងរដូវត្រីសំបូរបំផុតពីខែធ្នូ-កុម្ភៈ ។ នៅរដូវប្រាំង ប្រជាជនចាប់ក្តាម និងខ្យងនៅក្នុងវាលស្រែ ។ អ្នកមានទូក ពិសេសទូកម៉ាស៊ីន អាចនេសាទបានប្រសើរជាង ។ ប្រហែល ១២គ្រួសារបានទទួលឈ្មោះថាជាអ្នកនេសាទពាណិជ្ជករ គឺមានន័យថា គេបានចំណូលពីការនេសាទ ច្រើនជាងគ្រួសារឯទៀត ។ ពីខែធ្នូ-កុម្ភៈ គេអាចចាប់ត្រីបាន ២០-២៥គ.កក្នុងមួយយប់ (ប្រហែល ៥០.០០០រៀល) ប៉ុន្តែមិនមែនបានច្រើនដូច្នេះគ្រប់គ្នាទេ ពីព្រោះអ្នកភូមិភាគច្រើនជាអ្នកនេសាទធុនតូច និងធុនកណ្តាល ។ អ្នកនេសាទមួយក្រុមលើកឡើងថា គេត្រូវការឧបករណ៍ និងបទពិសោធន៍ទីផ្សារ ដើម្បីទាញយកប្រយោជន៍ឱ្យបានពេញលេញពីការបើកចំហឡូត៍នេសាទ ។

នៅភូមិព្រែកក្មេង អ្នកនេសាទម្នាក់អាចរកបាន ៥.០០០-២០.០០០រៀលក្នុងមួយថ្ងៃ បន្ទាប់ពីបានរំលែកត្រីខ្លះទុកហូបរួចហើយ ។ អ្នកនេសាទមួយចំនួនមិនលក់ត្រីចាប់បានទាំងអស់ទេ ប៉ុន្តែទុកខ្លះសំរាប់ធ្វើចំណីត្រីធំដែលគេចិញ្ចឹមក្នុងទ្រុង ។ ក្នុងមួយឆ្នាំពេញ គ្រួសារមួយអាចរកបាន ១-២លានរៀលពីការលក់ត្រី ។ ប៉ុន្តែដើម្បីបានប្រាក់ប៉ុណ្ណេះ គេត្រូវចំណាយពី ៤០០.០០០-៨០០.០០០រៀលលើមងនាំចូលពីថៃ ។ នៅព្រែកក្មេង ក៏មានរបាយការណ៍ពីការធ្លាក់ចុះចំនួនត្រីចាប់បានដែរ ។ គេបានបន្ទោសថា ការនេសាទហួសកំរិតនិងប្រើវិធីនេសាទដែលប៉ះពាល់អាក្រក់ដល់បរិស្ថានបានបង្កឱ្យមានការថយចុះបែបនេះ ។

នៅភូមិកំពង់ត្នោត ជាងពាក់កណ្តាលនៃគ្រួសារក្នុងភូមិធ្វើនេសាទជាលក្ខណៈពាណិជ្ជកម្មនៅសមុទ្រពេញៗមួយឆ្នាំ ។ អ្នកនេសាទស្ទើរគ្រប់គ្នា មានទូកចែវមួយ ឬទូកម៉ាស៊ីនតូចមួយ ។ ដោយសារគ្រោះថ្នាក់ព្យុះ អ្នកមានទូកចែវធ្វើនេសាទនៅក្បែរឆ្នេរដែលមានទឹកជំរៅពី ០,៨-១,០ម ។ កម្មសិទ្ធិ ឬលទ្ធភាពមានបរិក្ខារគ្រឿងយន្តប្រើ វាបែងចែងដាច់គ្នាយ៉ាងច្បាស់នូវលទ្ធភាពរបស់ប្រជាជនក្នុងការស្វែងរកផលិតផលនៅក្នុងសមុទ្រ ។ អ្នកនេសាទទាំងអស់សុទ្ធតែជាបុរស តាមធម្មតាឳពុកមួយ

---

[១៥] គ្មានផ្ទៃទឹកច្រើនទេ នៅភូមិដងក្តារ និងត្រពាំងប្រិយ ។

[១៦] ចំនួនពេលចេញទៅនេសាទ អាស្រ័យលើកំលាំងមនុស្ស និងឧបករណ៍ដែលមាន ។

កូនមួយបង្កើតបានក្រុមមួយ ។ ស្ត្រីនៅផ្ទះធ្វើការកែច្នៃត្រី និងក្តាមសំរាប់ទីផ្សារ ។ ដូច្នេះការបែងចែកពលកម្មតាមភេទនៅក្នុងប្រតិបត្តិការនេសាទ គឺមានលក្ខណៈជាក់ស្តែង ។ អ្នកភូមិទុកត្រី និងក្តាមតូចៗសំរាប់ហូបក្នុងគ្រួសារ ហើយលក់ត្រីនិងក្តាមធំៗទៅទីផ្សារ ។ បន្ទាប់ពីទូទាត់សោហ៊ុយលើសំភារៈនេសាទដែលមានតំលៃពី ៥០.០០០-៧០.០០០រៀលក្នុងមួយឆ្នាំ ប្រាក់ចំណេញសុទ្ធជាមធ្យមពីការនេសាទ គឺបានប្រហែល ៣៥.០០០-៥០.០០០រៀលក្នុងមួយថ្ងៃ ។ អ្នកភូមិត្អូញត្អែរថា ផលនេសាទធ្លាក់ចុះយ៉ាងខ្លាំងក្នុង ៤-៥ឆ្នាំចុងក្រោយដោយសារការនេសាទហួសកំរិត ។ មនុស្សជាច្រើនមកពីកន្លែងផ្សេងបានមកនេសាទនៅតំបន់នេះ ធ្វើឱ្យព្រៃកោងកាងលិចទឹកត្រូវវិចរិលចុះគុណភាព ។ ការផ្គត់ផ្គង់គ្មានភាពឃឺត បានប្រទាញឱ្យចំណូលរបស់អ្នកនេសាទស្ថិតនៅទាប ទោះបីជាទីផ្សារវារីកចំរើនបន្តិចហើយក្តី ។

ដូចបញ្ជាក់នៅខាងលើ អ្នកមានទូកម៉ាស៊ីន និងឧបករណ៍គ្រឿងយន្ត អាចចាប់បានត្រីច្រើនជាង ។ ម្យ៉ាងទៀត អតីតសម្បទានិកឡូត៍នេសាទ (ដែលនៅតែសកម្មក្នុងអាជីវកម្មនេសាទ ហើយដែលបានឆ្លើយសម្ភាសន៍ក្នុងអង្កេតនេះ) និងអាជ្ញាធរមូលដ្ឋាន បានអះអាងថា មានការប្រើប្រាស់ឧបករណ៍ខុសច្បាប់នៅតាមមូលដ្ឋានភាគច្រើន ដូចជា មងក្រឡាញឹក ឬអាគុយឡានសំរាប់ចាប់ត្រី ។ ទង្វើបែបនេះអាចកើតមាន ដោយសារការដាក់អនុវត្តន៍ច្បាប់នៅទន់ខ្សោយ ។ ពួកអ្នកភូមិ រួមទាំងប្រធានភូមិ និងប្រធានឃុំផងបានឱ្យដឹងថា អ្នកណាខ្លះប្រព្រឹត្តអំពើបែបនេះ ប៉ុន្តែមិនហ៊ានឃាត់ឃាំង ព្រោះខ្លាចមានការសងសឹក[១៧] ។ សព្វថ្ងៃ ៥៧% នៃផ្ទៃនេសាទបានបើកចំហឱ្យមហាជនធ្វើអាជីវកម្ម ប៉ុន្តែគេឃើញមានកំណើនសកម្មភាពនេសាទខុសច្បាប់ (ដូចជានៅព្រែកក្អែង) ។ ដើម្បីទប់ស្កាត់បញ្ហានេះ ត្រូវមានជាបន្ទាន់នូវសំពាធរួមគ្នា និងអភិបាលកិច្ចរឹងមាំ ។ គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការបង្កើតរបបគ្រប់គ្រងផ្ទៃទឹកដោយសហគមន៍ វាមានដំណើរយឺតយ៉ាវ ដោយសារកង្វះខាតធនធានមនុស្ស ហិរញ្ញវត្ថុ និងការរៀបចំ ។ ហើយការធ្លាក់ចុះស្តុកត្រីដែលកើតមានឡើង អាចធ្វើឱ្យជីវភាពរបស់ប្រជាជនកាន់តែយ៉ាប់យ៉ឺនថែមនៅក្នុងអនាគតមិនយូរ ។

ចាប់ពីទសវត្សរ៍១៩៨០ កំណើនប្រជាជនបានបង្កើនការប្រកួតប្រជែងចាប់ត្រីឱ្យបានកាន់តែច្រើន ទោះបីស្តុកត្រីនៅដដែលក្តី ។ កត្តានេះជាឧបសគ្គមួយយ៉ាងធំដែលរារាំងដល់ការប្រឹងប្រែងលើកកំពស់កំរិតជីវភាពប្រជាជន ។

### *២.៣.១.២. ការចិញ្ចឹមត្រីក្នុងទ្រុង*

អ្នកភូមិនៅព្រែកក្អែង ចិញ្ចឹមត្រីឆ្តោរនៅក្នុងទ្រុង ត្រាំក្នុងអូរដែលមានទឹកហូរកាត់ភូមិគ្រប់រដូវ ។ រហូតមកទល់ប៉ុន្មានឆ្នាំចុងក្រោយ គេចាប់យកកូនត្រីពីផ្ទៃទឹកក្នុងមូលដ្ឋាន ប៉ុន្តែបច្ចុប្បន្នគេទិញវាពីខេត្តកំពង់ឆ្នាំង ពីព្រោះមានគ្រួសារកាន់តែច្រើនបានចាប់យកមុខរបរនេះ[១៨] ។ ត្រីឆ្តោរត្រូវការពេល ៨-១០ខែ (ពីខែមិថុនា-កក្កដា ដល់មីនា-មេសា) ដើម្បីធំធាត់បានធំល្មមអាចចាប់លក់ឱ្យឈ្មួញបាន ។ នៅព្រែកក្អែង អ្នកភូមិចាប់ផ្តើមចិញ្ចឹមត្រីក្នុងទ្រុងនៅឆ្នាំ១៩៩០ ។ មកដល់ឆ្នាំ១៩៩៧ មានគ្រួសារប្រហែល ២៥% បានចាប់យកការចិញ្ចឹមត្រីជាការងារបន្ថែម ហើយនៅឆ្នាំ២០០១ គឺមានដល់ ៨៥% ។ នៅខែមិថុនា ជារៀងរាល់ឆ្នាំ អ្នកចិញ្ចឹមត្រីម្នាក់ៗត្រូវការប្រាក់ ៥០០.០០០រៀលសំរាប់ទិញកូនត្រី ក្នុងនេះប្រហែល ៩០% ត្រូវខ្ចីប្រាក់គេ ។ ការអនុវត្តន៍ជាទូទៅគឺខ្ចីមាស ៤ជី (ប្រហែល ៥០០.០០០រៀល) ពីអ្នកចងការប្រាក់ឯកជននៅភូមិជិតនោះ ។ បន្ទាប់ពីលក់ត្រីនៅខែមេសា (១០ខែក្រោយមក) ត្រូវសងគេវិញ ៦ជី ដូច្នេះការប្រាក់គឺប្រហែល ៥%ក្នុងមួយខែ ។ នៅដើមទសវត្សរ៍១៩៩០ ត្រីឆ្តោរមួយគីឡូក្រាមថ្លៃ ២.០០០រៀល, នៅចុងទសវត្សរ៍១៩៩០ វាថ្លៃ ២.៥០០រៀល ហើយពីឆ្នាំ១៩៩៩-២០០១ វាឡើងដល់ ៣.០០០រៀល ។ ទោះបីជាឡើងថ្លៃយ៉ាងនេះក្តី ក៏មិនអាចប៉ះប៉ូវការចុះថ្លៃប្រាក់រៀលបានដែរ ហើយនេះជាប្រភពនៃការមិន

---

[១៧] វិធានការណ៍សងសឹកដែលគេភ័យខ្លាចបំផុតគឺការដាក់ថ្នាំបំពុលត្រីក្នុងទ្រុង ដែលអាចធ្វើឱ្យម្ចាស់ត្រីត្រូវហិនហោចខាងហិរញ្ញវត្ថុ ។

[១៨] ក្នុងគំរូតាងនេះ គេពិនិត្យឃើញការចិញ្ចឹមត្រីក្នុងទ្រុងនៅភូមិព្រែកក្អែង ប៉ុន្តែការចិញ្ចឹមត្រីបែបនេះ គឺមានជាទូទៅនៅបណ្តាភូមិដែលស្ថិតនៅលើ ឬនៅក្បែរច្រាំងទន្លេសាប ឬទន្លេមេគង្គ ។

សប្បាយចិត្ត ជាពិសេសទាក់ទិននឹងមងដែលត្រូវនាំចូល ។ ក្នុងឆ្នាំ២០០១ គ្រួសារមួយមានត្រី ៣.០០០ក្បាលសំរាប់លក់ អាចរកប្រាក់ចំណូលបាន ៥លានរៀល ។ បន្ទាប់ពីដក ០,៥លានរៀល ចំណាយលើកូនត្រី ០,៣លានរៀលលើការប្រាក់ និងប្រហែល ១លានរៀលលើថ្លៃទិញធាតុចូលផ្សេងទៀត គេអាចបានប្រាក់ចំណេញសុទ្ធប្រហែល ៣លានរៀល ទោះបីអត្រាត្រីនៅរស់បានត្រឹមប្រហែល ៦០% ក៏ដោយ ។ អាជីវកម្មនេះមានផលចំណេញ (ចំណេញ ២០% លើចំណូលលក់សរុប) ថ្វីបើអ្នកនេសាទនៅតែត្រូវការខ្ចីបុលពីអ្នកចងការប្រាក់មកធ្វើដើមទុនក៏ដោយ ។ លទ្ធភាពមានចំណីត្រីក្នុងតំលៃសមរម្យជាទៀងទាត់ក៏មានគេលើកថា ជាកត្តាបង្កការបារម្ភដែរ ។ ដោយមូលហេតុនេះ ប្រជាជនខំធ្វើការខ្លាំងណាស់ ហើយជួនកាលបានប្រព្រឹត្តទាំងអំពើខុសច្បាប់ ទៀតផង ។ នេះជាបញ្ហាមួយដែលត្រូវដោះស្រាយ ។

### *២.៣.១.៣ . ការកែច្នៃត្រី*

អ្នកភូមិនៅព្រែកក្មេង ក៏ធ្វើការកែច្នៃត្រីដែរ: ៨៥% នៃគ្រួសារប្រជាជនទិញត្រីនៅរដូវត្រីសំបូរ (មករា-កុម្ភៈ) ដើម្បីឆ្អើរលក់ ។ នេះជាជំនួញមួយមានចំណេញច្រើន: គ្រួសារមួយអាចរកប្រាក់បាន ៣០០.០០០រៀល ដោយមានការ វិនិយោគពេលវេលាគ្រួសារចំនួន២៥ថ្ងៃ (៦០-៧០ថ្ងៃនៃពលកម្មមនុស្សម្នាក់) ។ ត្រីឆ្អើរលក់ចេញទៅខេត្តផ្សេងៗ និងនាំចេញទៅវៀតណាម ។ ចាប់ពីចុងទសវត្សរ៍១៩៩០ បរិមាណត្រីតូចចាប់បាន ត្រូវថយចុះដោយអ្នកខ្លះយល់ថា មកពីកំពស់ទឹកខ្ពស់ហួសប្រមាណ ។ អ្នកកែច្នៃត្រីជាច្រើននាក់ បានចាប់ផ្តើមទិញត្រីពីភូមិដទៃ ។

## *២.៣.២. ផលិតផលព្រៃឈើ និងការបេះប្រមូលផលព្រៃឈើ*

ដោយមានប្រជាជនពីគ្រប់ភូមិចេញទៅបេះប្រមូលរុក្ខជាតិ អុស និងរបស់ហូបផ្សេងៗ, ការធ្លាក់ចុះនៃលទ្ធភាពប្រើប្រាស់ធនធានទ្រព្យរួម (ដែលបណ្តាលពីឯកជននីយកម្ម និងការរិចរិលចុះគុណភាពធម្មជាតិ) បានបង្កនូវការមិនសប្បាយចិត្តជាទូទៅ ។ ក្នុងករណីមួយចំនួន ប្រាក់ចំណូលក៏ធ្លាក់ចុះផងដែរ ។ ទោះយ៉ាងនេះក្តី ការប្រមូលផលព្រៃឈើ បានផ្តល់នូវស្បៀងបន្ថែម និងជួយកាត់បន្ថយចំណាយ ។ ក្នុងភូមិភាគច្រើន គ្រួសារស្ត្រីដឹកនាំ គ្រួសារគ្មានដី និងពួកកុមារ បានផ្តល់ធនធានមនុស្សចំបង សំរាប់ការងារបេះប្រមូលផលព្រៃឈើ ។ នៅមូលដ្ឋានខ្លះ គេយកផលិតផលទាំងនេះទៅលក់ (នៅភូមិក្រសាំង បាបោង និងកំពង់ត្នោត) ហើយមនុស្សម្នាក់អាចរកបានពី ១.៥០០-២០០០រៀលក្នុងមួយថ្ងៃ ។

នៅភូមិដងក្តារ ប្រភពចំណូលធំជាងគេសំរាប់អ្នកភូមិគឺការកាប់ឈើ ។ អ្នកភូមិបានចំណេញច្រើនណាស់ ពីសកម្មភាពកាប់ឈើអនាធិបតេយ្យក្នុងឆ្នាំ១៩៩១-១៩៩៤ នៅពេលមានកំណើនតំរូវការភ្លាមៗ នៅក្រោយការបើកចំហសេដ្ឋកិច្ច និងនៅពេលដែលព្រៃឈើពុំមានការគ្រប់គ្រងពិតប្រាកដ ។ ក្នុងឆ្នាំ១៩៩២ រោងអារឈើ ១៣កន្លែង ត្រូវបានបង្កើតឡើង ហើយម្ចាស់រោងអារឈើបានជួលកម្មករឱ្យកាប់ឈើក្នុងកំរៃពី ៣.០០០-៤.០០០រៀលក្នុងមួយ១ម៣ ឈើមូល គឺលើសពីតំលៃការងារក្នុងមួយថ្ងៃទៅទៀត ។ ចាប់ពីឆ្នាំ១៩៩៨ និងក្រោយការវាយប្រយុទ្ធជាមួយខ្មែរក្រហមបានបញ្ចប់ គេឃើញមានការគ្រប់គ្រងមាំទាំជាងមុន ដោយក្រុមហ៊ុនសម្បទាន និងការអនុវត្តន៏ច្បាប់បានតឹងរ៉ឹងថែមទៀត ។ ជាលទ្ធផល ការកាប់ឈើជាឯកជនបានធ្លាក់ចុះ ហើយរោងអារឈើថយចំនួនសល់ត្រឹមតែ២ ក្នុងឆ្នាំ២០០១ ។ ទោះបីជាលក្ខណៈបច្ចេកទេស ការកាប់ឈើជាឯកជនវាខុសច្បាប់ ដោយសារឈើមិនមែនជាកម្មសិទ្ធិរបស់ភូមិ (ឈើជារបស់ក្រុមហ៊ុនសម្បទាន) សកម្មភាពកាប់ឈើដោយលួចលាក់បានកើនឡើង ។ ការកាប់ឈើសព្វថ្ងៃ តែងមានពលករមួយក្រុមមានគ្នា ៣-៤នាក់ ដែលទទួល "ការងារដុំ" មានរយៈមួយសប្តាហ៍ ប្រហែលពីរដងក្នុងមួយខែ ។ ការងារនេះរួមមាន រកមើលឈើមួយដើម កាប់ផ្តួលឈើនោះ ត្រួសត្រាយផ្លូវទៅកាន់ដើមឈើ និងដឹកឈើទៅភូមិ ឬទៅតំបន់ក្បែរៗដើម្បីលក់ ។ ប្រាក់ចំណេញ គឺ ២-៣ម៉ឺនរៀលក្នុងការងារមួយ ។ ប៉ុន្តែអ្នកភូមិអាចជួបគ្រោះថ្នាក់ត្រូវកងយាមល្បាតរបស់ក្រុមហ៊ុនចាប់បាន ហើយក្នុងករណីនេះគេត្រូវបង់ពិន័យយ៉ាងច្រើន ។ សព្វថ្ងៃ ប្រហែលតែ ១/៣ នៃគ្រួសារក្នុងភូមិប៉ុណ្ណោះ ដែលអាចធ្វើសកម្មភាពខុសច្បាប់នេះ ពីព្រោះយ៉ាងហោចណាស់ត្រូវមានក្របីធំមួយនឹមមាន

តំលៃ ៥០០ដុល្លារ និងរទេះមួយមានតំលៃ ២៥០ដុល្លារដែលអាចដឹកឈើហ៊ុបប្រវែង ៣-៧ម៉ែត្របាន[១៩] ។

ប្រហែល ១០% នៃគ្រួសារប្រជាជននៅភូមិដងក្តារ អះអាងថា ខ្លួនមានដើមឈើយកជ័រ ។ ពួកអ្នកភូមិបញ្ជាក់ទៀតថា ពួកខ្លួនជា "ម្ចាស់" ដើមឈើទាំងនេះជាច្រើនជំនាន់មកហើយ ។ គ្រួសារនីមួយៗកាលពីមុនមានដើមឈើពី ៣០០-៧០០ដើម ដែលអាចនៅឆ្ងាយពីភូមិដល់ទៅ ២០-៣០គីឡូម៉ែត្រ ។ នេះជាស្ថានភាពពីមុនឆ្នាំ១៩៩៥ ដែលជាឆ្នាំក្រុមហ៊ុនព្រៃសម្បទានចូលមកកាន់កាប់ទីនេះ ។ បច្ចុប្បន្ន មានតិចគ្រួសារណាស់ដែលមានដើមឈើយកជ័រ ហើយក្នុងមួយគ្រួសារៗមានមិនលើសពី ៥០ដើមទេ ។ បទប្បញ្ញត្តិមួយក្នុងច្បាប់ព្រៃឈើដែលហាមឃាត់ការកាប់ដើមឈើយកជ័រ បានជួយឱ្យដើមឈើទាំងនេះនៅគង់វង្សបានច្រើន ។ ចំពោះអ្នកភូមិ គេយល់ព្រមទទួលយក ៤.០០០-១០.០០០រៀល ពីក្រុមហ៊ុនព្រៃសម្បទាន សំរាប់ដើមឈើយកជ័រមួយដើម ពីព្រោះគេបារម្ភថា ដើមឈើទាំងនេះនឹងត្រូវកាប់ចៀសមិនផុតទេ ។ សព្វថ្ងៃ ឈើមួយដើមអាចផ្តល់ជ័រមានតំលៃ ២០.០០០រៀលក្នុងមួយឆ្នាំ ។ តាំងពីប្រជាជនមានដើមឈើយកជ័រនៅសល់តិចដើម ពួកគេបានពឹងផ្អែកលើការប្រមូលអនុផលព្រៃឈើ និង/ឬការលួចកាប់ឈើខុសច្បាប់ ។

នៅក្នុងភូមិមានព្រៃឈើ ការប្រមូលផ្តៅកាលពីមុនឃើញមានជាទូទៅ ប៉ុន្តែសព្វថ្ងៃបានថយចុះហើយ ។ នៅភូមិដងក្តារ គេប្រមូលគ្នា ៤-៥គ្រួសារក្នុងមួយក្រុមៗ ហើយនាំគ្នាចូលទៅក្នុងព្រៃជ្រៅរយៈ ៥-១០ថ្ងៃក្នុងមួយលើកៗ ដើម្បីរកកាប់ផ្តៅ ហើយអាចរកចំណូលបានពី ២០.០០០-៥០.០០០រៀលក្នុងមួយគ្រួសារ ។ អ្នកភូមិយល់ថា ផ្តៅនៅតែមានច្រើន តែវាធ្លាក់ថ្លៃទាបខ្លាំងណាស់ ពីព្រោះមានមនុស្សច្រើនតំណពេកមកកាត់យកចំណេញនៅក្នុងខ្សែរយៈលក់ដូរផ្តៅ ។ ប្រហែល ២៥% នៃគ្រួសារក្នុងភូមិប្រកបរបរបរបាញ់សត្វ ជីកដំឡូង និងបេះផ្លែឈើពីក្នុងព្រៃ ។ បុរសមាន ៣-៥នាក់ក្នុងមួយក្រុមៗ ធ្វើដំណើរចូលទៅក្នុងព្រៃជ្រៅដាក់អន្ទាក់ចាប់ឈ្លូស ពស់ អណ្តើក និងសត្វផ្សេងទៀត ។ អ្នកភូមិ ក៏អាចរកម្ហូបអាហារបន្ថែមតាមរដូវផ្សេងៗពីក្នុងព្រៃ ដូចជា ដំឡូងព្រៃ ផ្លែឈើ សត្វល្អិត និងអាពីង ។ ផលិតផលមួយចំនួនគេយកមកលក់នៅទីផ្សារក្បែរភូមិ (ប្រហែល ២៥គ.មពីភូមិ) ។ អ្នកដាក់អន្ទាក់អាចរកចំណូលបានច្រើនដល់ទៅ ១៥.០០០រៀលក្នុងមួយថ្ងៃ ។ តាមការឆ្លើយសម្ភាសន៍ ចំនួនសត្វព្រៃបាន ថយចុះយ៉ាងខ្លាំង ថ្វីបើចំនួនអ្នករកចាប់សត្វបានកើនឡើងក្តី ។ ម្យ៉ាងទៀត អ្នកបរបាញ់កាន់តែពិបាកគេចផុតពី យន្តការដាក់អនុវត្តច្បាប់ប្រឆាំងនឹងការចាប់សត្វព្រៃនោះហើយ ។

នៅតាមភូមិដែលមិនសូវមានធនធានធម្មជាតិ (ត្រពាំងប្រិយ) ឬមានធនធានធម្មជាតិរិចរិលចុះគុណភាពខ្លាំង (ភូមិបាបោង, កំពង់ត្នោត), ការថយចំនួនអុសដុត បានបង្កើតបញ្ហាជាច្រើន ។ ពី ៣០%-៤០% នៃគ្រួសារក្នុងភូមិត្រពាំងប្រិយត្រូវទិញអុសដុត ។ គ្រួសារមួយចំនួនដែលមានរទេះគោ ត្រូវធ្វើដំណើរ ២-៣ថ្ងៃ ដើម្បីទៅកាប់អុសយកមកលក់ក្នុងភូមិបានថ្លៃមួយរទេះ ១០.០០០រៀល ។ មានតែពីរ-បីគ្រួសារមានឥទ្ធិពលប៉ុណ្ណោះដែលអាចចូលទៅរកអុសនៅតំបន់ព្រៃដែលគេហាមឃាត់ ។ ដូច្នេះក្នុងការរកអុស ក៏ឃើញមានសិទ្ធិមិនស្មើគ្នាដែរ ។ អ្នកក្រពឹងផ្អែកទៅលើការប្រមូលធាងត្នោត/មែកឈើនៅក្នុងភូមិ ឬក៏ត្រូវចំណាយប្រាក់ទិញអុស ហើយរឿងនេះបានប៉ះពាល់ដល់ការជីវភាពរបស់គាត់ ។ នៅភូមិបាបោង និងកំពង់ត្នោត អ្នកភូមិបានចាប់ផ្តើមគាស់ឫសឈើ ក្នុងតំបន់ព្រៃលិចទឹកដែលខ្លួនកាន់កាប់ ដើម្បីយកមកលក់ ។ អ្នកឆ្លើយសម្ភាសន៍បានទស្សន៍ទាយថា ដើមឈើ/ឫសឈើ នឹងហិនហោចក្នុងរយៈពេល ៣-៤ឆ្នាំខាងមុខ ។

### ២.៣.៣. ការចិញ្ចឹមសត្វ

ប្រជាជននៅគ្រប់ភូមិ មានចិញ្ចឹមសត្វពាហនៈ និងសត្វស្លាប ដូចជា គោ ក្របី ជ្រូក មាន់ ទា ជាដើម ។ សត្វទាំងនេះខ្លះទុកសំរាប់យកសាច់ និងខ្លះទៀតសំរាប់ប្រើជាកំលាំងអូសទាញ ។ ចំនួនគោក្របី ជាពិសេសសត្វសំរាប់ធ្វើកំលាំងអូសទាញបានធ្លាក់ចុះនៅក្នុងភូមិនានាដែលគេបានចាប់ប្រើផ្តើមគ្រឿងយន្ត (ក្រសាំង, បាបោង, ព្រែកក្មេង) ប៉ុន្តែបសុ បក្សី និងជ្រូក

[១៩] អ្នកភូមិពុំមានបង់ថ្លៃលើតំរូវការទាំងនេះទេ ពីព្រោះគេចិញ្ចឹមសត្វពាហនៈ និងធ្វើរទេះដោយខ្លួនឯង ។

គឺមានសំបូរ ។ ភូមិព្រែកក្មេង មានសត្វចិញ្ចឹមតិច ពីព្រោះភូមិនេះត្រូវលិចទឹកស្ទើរអស់កន្លះឆ្នាំ ។ គេលើកថា ការថយចុះគោក្របីនៅតាមកន្លែងខ្លះ (ដូចជាបាបោង) បានបង្កើនការបារម្ភក្នុងចំណោមកសិករធុនតូច ដែលធ្លាប់តែអាចលក់សត្វពាហនៈនៅពេលមានគ្រោះអាសន្ន ។ គេហាក់ដូចជាឃើញមានទំនាក់ទំនងវិជ្ជមានរវាងផលិតភាពកសិកម្មកំរិតខ្ពស់ និងចំនួនសត្វពាហនៈ នៅភូមិត្រពាំងប្រិយ និងដងក្តារ អត្រាសត្វពាហនៈក្នុងមនុស្សម្នាក់មានកំរិតខ្ពស់ជាងនៅភូមិក្រសាំង និងបាបោង[២០] ។ រឿងនេះបង្ហាញថា សកម្មភាពដាំដុះ និងសកម្មភាពចិញ្ចឹមសត្វ មានលក្ខណៈបំពេញឱ្យគ្នាទៅវិញទៅមក ។ សឹងតែគ្មានភូមិណាមួយទេដែលសកម្មភាពចិញ្ចឹមសត្វអាចផ្តល់ការងារពេញម៉ោងឱ្យប្រជាជនៈ វាជាសកម្មភាពពាក់កណ្តាលម៉ោង ដែលជាទូទៅច្រើនធ្វើឡើងដោយស្ត្រី និងកុមារ ។ កសិករនៅភូមិក្រសាំង បាបោង ព្រែកក្មេង និងកំពង់ត្នោត យកសត្វចិញ្ចឹមដូរយកសាច់ហូប, នៅកន្លែងឯទៀត គេប្រើប្រាស់សត្វចិញ្ចឹមសំរាប់ការហូបចុកផ្ទាល់ខ្លួន និងសំរាប់ដូរអីវ៉ាន់ខ្លះៗ ។ បញ្ហាដែលប៉ះពាល់ដល់សេដ្ឋកិច្ចនៃការចិញ្ចឹមសត្វ គឺថ្លៃសាច់នៅកសិដ្ឋាន ថ្លៃចំណីសត្វនៅកសិដ្ឋាន ជំងឺសត្វ សត្វងាប់ និងចោរកម្ម (ក្នុងភូមិមួយយ៉ាងតិចគឺក្រសាំង) ។

## ២.៣.៤. សកម្មភាពដទៃទៀត

### ២.៣.៤.១. ការធ្វើស្ករត្នោត

ការសិក្សាពីលើកមុននៅឯត្រពាំងប្រិយ បានបង្ហាញថា ក្រៅពីការធ្វើស្រូវ អ្នកភូមិពឹងផ្អែកយ៉ាងខ្លាំងលើចំណូលបានពីការផលិតស្ករត្នោត ។ ក្នុងឆ្នាំ១៩៩៧ មាន ២៧គ្រួសារជាអ្នកធ្វើស្ករត្នោត (McAndrew 1998) ។ បច្ចុប្បន្ន ដោយសារការបាត់បង់អុស មានតែ ៧គ្រួសារប៉ុណ្ណោះដែលផលិតស្ករត្នោត ។ ទោះបីក្នុង ៥ឆ្នាំចុងក្រោយ អុសឡើងថ្លៃទ្វេរ មួយជាពីរក៏ដោយ ក៏ស្ករត្នោតឡើងថ្លៃតែពី ៥៥០រៀល ដល់ ៧៥០រៀល/គ.កប៉ុណ្ណោះ ។ អ្នកធ្វើស្ករត្នោតមួយក្រុមលើកថា ក្នុងរដូវធ្វើស្ករចុងក្រោយ (វិច្ឆិកា ២000 ដល់ មេសា ២00១) គេចំណាយអស់ជាមធ្យម ២៥0.000រៀលសំរាប់ការទិញអុស ។ កាលពីពាក់កណ្តាលទសវត្សរ៍១៩៩0 គេចំណាយអស់តែប្រហែល ១៣0.000រៀលប៉ុណ្ណោះ សំរាប់ទិញអុសចំនួនប៉ុនគ្នា ។ ជារឿយៗមានមនុស្សមកទិញដើមត្នោតចាស់ៗសំរាប់ធ្វើអុស និងសំភារៈសាងសង់ (ត្នោតមួយដើមថ្លៃ ៥0.000រៀល) ។

### ២.៣.៤.២. ការធ្វើអំបិល

នៅភូមិកំពង់ត្នោត ស្រែអំបិលមានសរុប ១៥៥ហិកតា កាន់កាប់ដោយ ៨ម្ចាស់ដែលជាអ្នកមានជាងគេនៅក្នុងភូមិ ។ នៅឆ្នាំ១៩៨៩ នៅពេលប្រព័ន្ធទីផ្សារត្រូវបានអនុញ្ញាតឡើងវិញ ស្រែអំបិលក៏ត្រូវបានធ្វើឯកជននីយកម្ម ។ អ្នកខ្លះ រួមទាំងអតីតមន្ត្រីរដ្ឋាភិបាលដែលមានជំនាញក្នុងកិច្ចការនេះ (គឺគេបានទទួលជំនាញនៅពេលស្រែអំបិលជាកម្មសិទ្ធិរដ្ឋ ហើយខ្លួនគេជាមន្ត្រីទទួលបន្ទុក) ហើយមានធនធានផង, បានទិញយកដីស្រែអំបិល ។ ស្រែអំបិលមួយមានទំហំប្រហែល ៥0ម$^{២}$ និងមានភ្លឺព័ទ្ធជុំវិញ ។ គេបូមទឹកប្រៃបញ្ចូលទៅក្នុងស្រែ ហើយគេប្រមូលយកអំបិល បន្ទាប់ពីទឹកបានហួតរីងដោយសារពន្លឺថ្ងៃ និងកំដៅ ។ នៅក្នុងកសិដ្ឋានស្រែអំបិលនីមួយៗ ត្រូវមានកម្មករជំនាញ ២ ទៅ ៣នាក់យ៉ាងតិចធ្វើការជាប្រចាំ ដោយម្នាក់ៗទទួលប្រាក់ខែ ១៨0.000-២00.000រៀលក្នុងមួយខែ ។ នៅរដូវប្រមូលផល (ពីខែវិច្ឆិកា ដល់ មេសា) កសិដ្ឋានស្រែអំបិលនីមួយៗជួលកម្មករបន្ថែមយ៉ាងតិច ១៥នាក់ដែលភាគច្រើនជាស្ត្រី ឱ្យប្រមូល និងដឹកជញ្ជូនអំបិលទៅដាក់ក្នុងឃ្លាំងដែលនៅជាប់នឹងស្រែអំបិល ។ គេជួលកម្មករលើមូលដ្ឋានអត្រាគិតតាមឯកតាផលិត ហើយជាមធ្យមបានកំរៃ ៣.៥00រៀលក្នុងម្នាក់ក្នុងមួយថ្ងៃ ។ ដីទំហំ ១៥ហិកតា ផ្តល់អំបិលជាមធ្យម ៧00តោនក្នុងមួយឆ្នាំ ។ សព្វថ្ងៃ អំបិលមួយបាវប្រហែល ៧0គ.ក បានថ្លៃប្រហែល ១២.000រៀល ។ តាមសំដីម្ចាស់ស្រែអំបិល ថ្លៃអំបិលមានកំរិតទាបក្នុងរយៈបីឆ្នាំចុងក្រោយ ដោយសាររដ្ឋាភិបាលអនុញ្ញាតឱ្យមានការនាំអំបិលចូលពីចិន និងវៀតណាម ។ ទង្វើនេះបានប៉ះពាល់ដល់កំរិតចំណេញរបស់ផលិតករអំបិលកម្ពុជា ។

*សេចក្តីសង្ខេបទូទៅ*

---

[២០] ចំពោះតួលេខ សូមអានឯកសារ Chan (2002) ។

- អ្នកភូមិភាគច្រើនបានចាប់យកការងារក្រៅកសិដ្ឋានផ្សេងៗដូចជានេសាទ ការប្រមូលអនុផលព្រៃឈើ និងការបរបាញ់ ។ សកម្មភាពទាំងនេះផ្តល់ការងារពេញម៉ោងដល់មនុស្សជាច្រើន, ផ្តល់ការងារបន្ថែមដ៏សំខាន់ដល់អ្នកខ្លះ និងជួយពង្រឹងសន្តិសុខស្បៀងរបស់គ្រួសារ, ហើយក្នុងនេះស្ត្រីមានតួនាទីសំខាន់ណាស់ ។ ការធ្វើអាជីវកម្មគ្មានលក្ខណៈវិទ្យាសាស្ត្រលើធានធម្មជាតិ បានបង្កភាពតានតឹងនៅក្នុងតំបន់ភាគច្រើន ។
- មានចំណងទាក់ទងជាវិជ្ជមាន (តែមានកំរិត) រវាងការងារកសិកម្ម និងការងារមិនមែនកសិកម្ម ហើយរឿងនេះបញ្ជាក់ថា ជារឿយៗការងារកសិកម្ម និងមិនមែនកសិកម្ម តែងបំពេញឱ្យគ្នាទៅវិញទៅមក ។

- សព្វថ្ងៃ សកម្មភាពមិនមែនកសិកម្មនៅតំបន់ជនបទ ច្រើនតែពាក់ព័ន្ធនឹងការទាញយកផលធនធានធម្មជាតិ ។ សកម្មភាពបង្កើតតំលៃបន្ថែមច្រើនៗ ដូចជា ការកែច្នៃស្បៀង (ក្រៅពីការធ្វើត្រីឆ្អើរ) ជាពិសេស ប្រភេទការងារដែលធនធានមនុស្សមានសារៈសំខាន់ចំបង គឺមិនទាន់លេចចេញជារូបរាងនៅឡើយ ។ បច្ចេកវិទ្យាប្រើប្រាស់នៅក្នុងការងារដែលមានស្រាប់ វាមានលក្ខណៈសាមញ្ញគំរាំងពេក និងជាកត្តារាំងស្ទះមួយ ។
- ពលករដែលមានឧបករណ៍ ទុនបង្វិល ឬមានឥទ្ធិពល មានប្រៀបក្នុងការរកប្រាក់ចំណូលច្រើនជាងអ្នកដែលគ្មាន ។ កម្មករអ្នកគ្មានធនធាន អាចរកចំណូលបានត្រឹមតែមួយរស់ ។

## ២.៤. នំរង់ទីផ្សារ

គួរបញ្ជាក់ពីដំបូងថា ទីផ្សារជនបទនៅកម្ពុជា បានបើកចំហភ្លាមៗទទួលការប្រកួតប្រជែងពីអន្តរជាតិ នៅក្នុងទសវត្សរ៍ ១៩៩០ ហើយសព្វថ្ងៃមានលំហូរស្ទើរតែសេរីទាំងស្រុងនូវទំនិញ និងសេវាឆ្លងកាត់ព្រំដែន ទោះបីមានបទប្បញ្ញត្តិខាងពន្ធគយហើយក៏ដោយ ។ ថ្លៃផលិតផលកសិកម្ម រួមទាំងស្រូវផង ទទួលឥទ្ធិពលពីថ្លៃនៅទីផ្សារអន្តរជាតិ (ពោលគឺថ្លៃនៅថៃ ឬវៀតណាម ទៅតាមទីតាំងភូមិសាស្ត្រនៃភូមិ ឬទីផ្សារជាប់ទាក់ទិន) ។ មានអ្នកជំនួញមួយចំនួនតូចបានត្រួតត្រាទីផ្សារ (មុខផលិតផល, ថ្លៃ...) ហើយគេរកចំណេញបានខ្ពស់បំផុត ដោយទិញផលិតផលក្នុងតំលៃថោក នៅរដូវប្រមូលផល ហើយបញ្ចេញលក់វាពេញៗមួយឆ្នាំ ។ ចំពោះទីផ្សារឥណទាន អ្នកជំនួញ និងម្ចាស់ដី នៅមូលដ្ឋានត្រួតត្រាវាក្នុងទំរង់ផ្តាច់មុខ ។ កំចីមានតំលៃខ្ពស់ណាស់ ។ ឥណទានស្ថាប័នសឹងតែគ្មានសោះ ហើយបើសិនជាមាន វាក៏មិនថោកដែរ ។ ផ្នែកនេះផ្តល់ឧទាហរណ៍ស្តីពីអសុក្រិតភាពនៃទីផ្សារដែលអាចប៉ះពាល់ដល់ការរកចិញ្ចឹមជីវិត និងសន្តិសុខស្បៀង ។

### ២.៤.១. ទីផ្សារផលិតផលសំការៈប្រើប្រាស់ និងវត្ថុធាតុដើម

ខាងក្រោមនេះជាឧទាហរណ៍ដកស្រង់ចេញពីការសិក្សាតាមភូមិ ដើម្បីផ្តល់ការបំភ្លឺអំពីទីផ្សារដែលមានស្រាប់ :

១. នៅភូមិក្រសាំង ថ្លៃស្រូវធ្លាក់ដល់ ៣,៥បាត/គ.ក នៅរដូវច្រូតកាត់ ហើយឡើងដល់ ៤,១បាត នៅរដូវវស្សា ។ កសិករភាគច្រើនលក់ផលិតផលបានថ្លៃទាបទេ ថ្វីបើអ្នកជំនួញ និងអ្នកកិនស្រូវ ទទួលបានថ្លៃខ្ពស់ នៅពេលគេលក់ផលិតផលរបស់កសិករចេញវិញ ។ គ្រួសារអ្នកធ្វើស្រូវប្រាំង ក៏បានត្អូញត្អែរពីថ្លៃដ៏ខ្ពស់នៃប្រេងម៉ាសូត ជី និងថ្នាំសំលាប់សត្វល្អិតដែលផ្ទុយគ្នាពីថ្លៃស្រូវ ។ ក្នុងភូមិមានឈ្មួញតែ ២-៣នាក់ទេដែលអ្នកត្រួតត្រាទីផ្សារនៅមូលដ្ឋាន ហើយមានទំនាក់ទំនងតាមរយៈសាច់ញាតិរបស់ខ្លួនជាមួយនឹងទីផ្សារនៅថ្មគោលដែលជាផ្សារធំមួយក្បែរនោះ ។

២. នៅភូមិបាបោង ស្រូវថ្លៃ ៥០០រៀល/គ.កក្នុងឆ្នាំ១៩៩៦-១៩៩៩ ប៉ុន្តែធ្លាក់ចុះមកត្រឹម ២៤០រៀលនៅឆ្នាំ២០០០-០១ ។ ដោយប្រាក់រៀលបានធ្លាក់ថ្លៃ ២០%-៣០% ក្នុងរយៈពេលនេះ ការខាតបង់របស់កសិករ វាធ្ងន់ធ្ងរលើសពីការធ្លាក់ចុះថ្លៃស្រូវ ៥០% នេះទៅទៀត ។ គេគិតថា មានកសិករដល់ទៅ ៤០% ក្លាយជាអ្នកគ្មានដី ដោយសារការស្រុតថ្លៃផលិតផលនៅកសិដ្ឋានក្នុងរយៈ២ឆ្នាំចុងក្រោយ កសិករ ៧គ្រួសារទៀតប្រហែលជិតធ្លាក់ខ្លួនដូច្នេះដែរ ។

ឈ្មួញ ៥នាក់ ដែលមានទំនាក់ទំនងទៅនឹងទីផ្សារនៅអ្នកលឿង បានត្រួតត្រាទីផ្សារនៅមូលដ្ឋានមួយភាគធំ[២១] ។

៣. នៅភូមិកំពង់ត្នោត ដូងមួយលក់នៅកសិដ្ឋានបានថ្លៃ២០០រៀល ឯនៅភ្នំពេញតាមធម្មតាវាលក់បាន ៨០០រៀល ។ អ្នកជំនួញ អ្នកដឹកជញ្ជូន និងអ្នកដទៃទៀតនៅក្នុងខ្សែបណ្តាញនៃជំនួញ ជាអ្នកកាត់យកកំរិតចំណេញនេះ ។

៤. នៅភូមិក្រសាំង អ្នកជំនួញពីរនាក់ត្រួតត្រាទីផ្សារត្រី និងសត្វទឹកផ្សេងទៀត ដោយបង្កើតបានជារូបភាពរកស៊ីផ្តាច់មុខមួយ ហើយគេក៏ត្រួតត្រាមួយភាគធំដែរនូវជំនួញផលិតផលនេះជាមួយថៃ ។

៥. កសិករនៅភូមិព្រៃកក្អែងដែលលក់ត្រីឆ្អោរចិញ្ចឹមក្នុងទ្រុង មិនពេញចិត្តដោយសារថ្លៃផលិតផលរបស់ខ្លួនមិនអាចទប់ទល់នឹងការចុះថ្លៃប្រាក់រៀលក្នុងប៉ុន្មានឆ្នាំថ្មីៗ ។ ដោយសារមេងត្រូវនាំចូលមកពីថៃ ដូច្នេះថ្លៃប្រៀបធៀបរវាងផលត្រីរបស់គេ និងធាតុចូល មិនអំណោយផលទេ ។

៦. អ្នកផលិតអំបិលនៅកំពង់ត្នោត បានត្អូញត្អែរថា ថ្លៃអំបិលត្រូវជាប់គាំង ដោយសារការអនុញ្ញាឱ្យនាំចូលអំបិលថោកៗពីវៀតណាម និងចិន ។

៧. អ្នកជំនួញមួយចំនួនតូចមកពីទីរួមខេត្តកំពត ត្រួតត្រាលើផលិតផលសមុទ្រភាគច្រើនដែលរកបាននៅកំពង់ត្នោត ។

ឧទាហរណ៍ទាំងនេះបង្ហាញថា កសិករ ជាពិសេសកសិករធុនតូច ត្រូវប្រឈមមុខនឹងថ្លៃដ៏ទាប និងឡើងចុះខ្លាំងនៃតំលៃផលិតផលរបស់ពួកគេ ។ ចំពោះផលិតផលមួយចំនួន ថ្លៃត្រូវកំណត់ដោយទីផ្សារអន្តរជាតិ និងកំនត់បន្ត ដោយអ្នកជំនួញនៅមូលដ្ឋាន ។ ទន្ទឹមគ្នានេះ ថ្លៃធាតុចូលមិនអាចចរចាបានទេៈ ជី សាំង ម៉ាស៊ូត គឺជាផលិតផលនាំចូល, អ្នកមានត្រាក់ទ័រកំណត់ថ្លៃឈ្នួល... ។ ក្នុងដំណើរការនេះ ឈ្មួញកណ្តាល និងពាណិជ្ជករបានចំណេញច្រើនខ្លាំងណាស់ ។

ចំនុចមួយស្តីពីលក្ខណៈនៃការត្រួតត្រាទីផ្សារគួរតែបញ្ជាក់ឡើង ។ នៅផ្នែកខាងដើម បានលើកថា ដីជាច្រើនបានផ្លាស់ប្តូរម្ចាស់ ហើយជនមួយចំនួនតូចមានដីកាន់កាប់ធំៗ ។ ក្នុងករណីជាច្រើន ម្ចាស់ដីធំៗក៏ជាអ្នកជំនួញ អ្នកដឹកជញ្ជូន និងអ្នកត្រួតត្រាទីផ្សារផងដែរ (ក្រសាំង បាបោង ត្រពាំងប្រិយ) ។ ជារឿយៗ ថ្លៃកំរិតទាប ឬការឡើងចុះថ្លៃនៅទីផ្សារធំៗ ត្រូវបានផ្ទេរបន្តពីម្ចាស់ដីធំៗទៅដល់ប្រតិបត្តិករតូចៗ និងអ្នកគ្មានដី តាមរយៈថ្លៃទិញចូលដ៏ទាប និងប្រាក់កំរៃពលកម្មដែលគ្រាន់តែមួយរស់ ។

### ២.៤.២. ទីផ្សារឥណទាន

ដោយសារសកម្មភាពកសិកម្មមានលក្ខណៈជាវដ្ត ដូច្នេះតំរូវការសាច់ប្រាក់មានពេលកំណត់យ៉ាងទៀងទាត់នៅក្នុងសង្គមកសិកម្ម ។ ប្រជាជនត្រូវការប្រាក់សំរាប់ចំណាយលើធាតុចូលកសិកម្ម (ដូចជា ឧបករណ៍នេសាទ), ស្បៀង និងពិធីបុណ្យផ្សេងៗ, ការទិញទ្រព្យសកម្ម, ការដោះស្រាយវដ្តនៃវិបត្តិ, ការធ្វើដំណើរ (ចំណាកស្រុក ឬការងារផ្ទាល់ខ្លួន) ឬសំរាប់សងបំណុលចាស់ ។

អ្នកភូមិក្រសាំងនិយាយថា ខ្លួនត្រូវបង្ខំចិត្តខ្ចីប្រាក់ពីសាច់ញាតិ, លក់ទ្រព្យសម្បត្តិ ដូចជា ដី និងសត្វចិញ្ចឹម, ឬខ្ចីបុលពីអ្នកចងការប្រាក់, នៅពេលជួបកង្វះខាតថវិកា ឬជួបប្រទះគ្រោះធម្មជាតិ ។ បើទឹកប្រាក់តូចល្មមគេអាចរកខ្ចីនៅក្នុងភូមិបាន តែបើទឹកប្រាក់នោះធំ កសិករត្រូវធ្វើដំណើរទៅផ្សារផ្ទះគោល ។ នៅទីនោះចំណងសាច់ញាតិដើរតួសំខាន់ៈ បើសិនអ្នកខ្ចីប្រាក់មានទំនាក់ទំនងល្អ ឬជាប់សាច់ញាតិជាមួយអ្នកចងការប្រាក់, អត្រាការប្រាក់អាចទាបត្រឹម ៥% ក្នុងមួយខែ ហើយក៏ពុំមិនបាច់មានដាក់វត្ថុធានាទេ ។ គ្រួសារក្រីក្រអាចគ្មានខ្សែបណ្តាញបែបនេះទេ ដូច្នេះគេត្រូវបង់ការប្រាក់ខ្ពស់ ដល់ ១០-១៥%ក្នុងមួយខែ

[២១] អ្នកមានជាងគេក្នុងចំណោមឈ្មួញទាំង៥នាក់អះអាងថា គាត់មិនមែនជាអ្នកកំណត់ថ្លៃទេ គឺឈ្មួញមកពីវៀតណាមជាអ្នកកំណត់ ឯខ្លួនគាត់គ្រាន់តែបានចំណេញតាមភាគរយថេរមួយប៉ុណ្ណោះ ។ ពេលថ្មីៗនេះ ឈ្មួញវៀតណាមកំរឡើងមកណាស់ ពីព្រោះត្រូវសូកប្រាក់ច្រើនពេកនៅតាមកុងត្រូល ហើយរឿងនេះធ្វើឱ្យថ្លៃធ្លាក់ចុះ ។ ឧទាហរណ៍នេះបានបង្ហាញពីរបៀបត្រួតត្រាថ្លៃឆ្លងព្រំដែន ។

និងត្រូវដាក់របស់ធានា ។ អ្នកភូមិជាច្រើនបានបាត់បង់វត្ថុធានា ដោយសារគេសងប្រាក់យឺត ឬគ្មានលទ្ធភាពសង[២២] ។ ការប្រាក់ខ្ពស់ជាទូទៅ តែងបង្កើនបន្ទុកបំណុលរបស់អ្នកខ្ចី ដែលត្រូវសងកំចីនោះវិញដោយប្រាក់ចំណូលបានពីការលក់ស្រូវ ហើយរឿងនេះបានរុញច្រាន ពួកគេឱ្យធ្លាក់ចូលទៅក្នុងវដ្តនៃកង្វះខាតស្បៀង ។ ម្យ៉ាងទៀត ពុំមានឯកសារជាលាយលក្ខណ៍អក្សរសំរាប់បញ្ជាក់ពីកំចី ឬការដាក់របស់ធានាទេ ។ រាល់កិច្ចព្រមព្រៀងធ្វើឡើងដោយផ្ទាល់មាត់ ហើយនេះជាប្រភពមួយទៀតនៃទំនាស់ ។ នៅភូមិក្រសាំងមាន ៦គ្រួសាររកស៊ីចងការប្រាក់ ភាគច្រើនជាម្ចាស់ដីធំៗ ។ គេរាយការណ៍ថា នៅបាបោង ៧០% នៃគ្រួសារកសិករត្រូវការប្រាក់កំចីជាទៀងទាត់ ហើយភាគច្រើនត្រូវពឹងផ្អែកលើអ្នកចងការប្រាក់ ។ គេខ្ចីប្រាក់ដើម្បីជួលគ្រឿងម៉ាស៊ីនកសិកម្ម និង ទិញធាតុចូល កសិកម្មផ្សេងៗ ហើយសងប្រាក់កំចីវិញនៅរដូវប្រមូលផល ។ ការប្រាក់អាចខ្ពស់ដល់ ២០-៣០%ក្នុងមួយខែ ។ ចំពោះអ្នកដែលគ្មានរបស់ធានា គេត្រូវសន្យាផ្តល់កំលាំងពលកម្ម ។ ប្រជាជននៅត្រពាំងប្រិយទៅខ្ចីប្រាក់ពីផ្សារបាត់ដឹង (ចំងាយ ប្រហែល ៣គ.ម) ក្នុងអត្រាការប្រាក់ ១០-២០% ក្នុងមួយខែ ។ គេប្រាប់ថា នៅកំពង់ត្នោតក៏ប្រហែលគ្នានេះដែរ គឺសាច់ញាតិ កសិករមាន១ៗដែលរស់នៅ ឯក្រុងកំពត គេរកស៊ីជាអ្នកចងការប្រាក់ធំៗ ហើយគេផ្តល់កំចីក្នុងអត្រាការប្រាក់ ១០-១៥% ក្នុងមួយ ខែទៅឱ្យកសិករ និងអ្នកនេសាទ[២៣] ។

ដូចបានបញ្ជាក់ខាងលើ ប្រជាជនក៏មានខ្ចីបុលសំរាប់ដោះស្រាយស្បៀងផងដែរ ។ ដើម្បីបន្ធូរស្ថានភាពតានតឹងនៅភូមិខ្លះមានបង្កើតធនាគារស្រូវ ។ ទោះបីគោលគំនិតនៃធនាគារស្រូវគួរឱ្យចាប់អារម្មណ៍ក្តី កំរៃការលើស្រូវកម្ចីមិនមែនតូចទេ ធ្វើឱ្យកំចីស្រូវមិនជាស្មើភាពប៉ុន្មានដែរ ។ ប៉ុន្តែកំចីស្រូវមិនទាក់ទិននឹងការឡើងចុះថ្លៃទេ ហើយស្រូវខ្ចីបាន ក៏មិនអាចបង្វែរទៅបំរើគោលដៅអ្វីផ្សេងដែរ ដូច្នេះវាធានាឱ្យសន្តិសុខស្បៀងប្រែប្រួលប្រសើរឡើង ។ ក្នុងគំរូតាងនេះ ធនាគារស្រូវមានដំណើរការនៅភូមិដងក្តារ និងភូមិកំពង់ត្នោត ។

កម្មវិធីឥណទានស្ថាប័នក្នុងទំរង់នៃការពង្រីកមីក្រូឥណទាន ត្រូវបានគេជំរុញឡើងនៅក្នុងភូមិទាំង៦ ។ កំចីរបស់ ACELEDA គំរោងបង្កើតឡើងដោយ UNICEF ធនាគារស្រូវឧបត្ថម្ភដោយ GTZ, ក្រុមផ្សព្វផ្សាយឥណទាន GRET ឬកម្មវិធីគាំទ្រដោយ World Vision, ឃើញមាននៅតាមភូមិនានា ។ គេបានលើកពីបញ្ហាមួយចំនួនទាក់ទិននឹងចំណុចខ្សោយនៃឥណទានស្ថាប័ន ។ បញ្ហាចំបង គឺកំរិតការប្រាក់ ដែលមិនមែនសុទ្ធតែទាបនោះទេ ពីព្រោះការប្រាក់ភាគច្រើនមានកំរិត ៤%-៥% ក្នុងមួយខែ[២៤] ឯមូលហេតុ គឺបុគ្គលិក NGO មួយចំនួនបានលើកថា មកពីប្រតិបត្តិការមានបន្ទុកចំណាយខ្ពស់ ប៉ុន្តែសេចក្តីពន្យល់បែបនេះមិនបានជួយដល់កសិករទេ ។ បន្ថែមលើនេះទៀត បែបបទផ្លូវការស្មុគស្មាញហួសហេតុដើម្បីសុំបានឥណទាន, ពេលកំណត់ដ៏តឹងរឹងនៃការទូទាត់សង, ដែនសកម្មភាពតូច និង ទុនមានកំរិតរបស់ទីភ្នាក់ងារនានា, លទ្ធភាពប្រើប្រាស់ឥណទានមិនដូចគ្នា និងសិទ្ធិកាន់កាប់ដីមិនទាន់ដោះស្រាយរួច, គឺជាឧបសគ្គខ្លះៗដែលរារាំងដល់ការប្រើប្រាស់ឥណទានជាផ្លូវការឱ្យបានសក្តិសិទ្ធិ ។

*សេចក្តីសង្ខេបទូទៅ*

- កសិករជា "អ្នកទទួលយកថ្លៃ" ចំពោះផលិតផលរបស់ខ្លួន ក៏ដូចជាធាតុចូលកសិកម្ម ។ គ្មានការប្រកួតប្រជែងសុក្រិតល្អទេ ហើយកំលាំងពីខាងក្រៅ និងអ្នកជំនួញ ត្រួតត្រាថ្លៃបានមួយកំរិតធំ ក៏ដូចជាតំរូវការ និងការផ្គត់ផ្គង់ទំនិញផ្សេងៗ ។ ក្នុងស្ថានភាពបែបនេះ កសិករមិនមែនសុទ្ធតែបានចំនេញពីការចូលទាក់ទងនឹងទីផ្សារធំៗនោះទេ ។

[២២] អ្នកចងការប្រាក់ម្នាក់និយាយថា "អ្នកខ្ចីប្រាក់ភាគច្រើនខ្ចីលុយដើម្បីធ្វើចំណាកស្រុកទៅធ្វើការនៅថៃ ។ ខ្ញុំអាចរកចំណូលបានយ៉ាងតិច ១.០០០បាត/ខែ ពីការចងការប្រាក់ឱ្យអ្នកទាំងនោះ" ។ សំដីនេះ និងសេចក្តីរាយការណ៍ប្រហាក់ប្រហែលគ្នាផ្សេងទៀត បានបញ្ជាក់គាំទ្រចំពោះមតិដែលថា ទីផ្សារចងការប្រាក់ឯកជនកំពុងរីកដុះដាល ។

[២៣] ចំពោះស្បៀងតិចតួច និងពូជស្រូវ គេអាចខ្ចីពីសាច់ញាតិ ឬអ្នកជិតខាងបានដោយគ្មានការប្រាក់ ប៉ុន្តែសំរាប់មួយរយៈខ្លីប៉ុណ្ណោះ ។

[២៤] តំលៃខ្ពស់នៃឥណទានមីក្រូ ពីប្រភពស្ថាប័នក៏ជាបញ្ហាមួយដែលលើកឡើងនៅក្នុងព្រឹទ្ធសភា សូមអាន Phnom Penh Post, vol 11, No 10, May 10-23-2002, p 4 ។

"គំលាតថ្លៃ" ដូចមានបង្ហាញជូនក្នុងអង្កេតនេះមានទំហំធំគួរកត់សំគាល់ ហើយមួយចំណែកនៃគំលាតថ្លៃនេះ គឺជាផលចំណេញរបស់អ្នកជំនួញ ។

- មធ្យោបាយទូទៅដើម្បីរកបានប្រាក់កំចី គឺតាមរយៈអ្នកចងការប្រាក់ដែលយកការប្រាក់យ៉ាងខ្ពស់ ហើយរឿងនេះបានប៉ះពាល់ដល់កំរិតប្រាក់ចំណូលរបស់កសិករ ។

- ក្នុងករណីជាច្រើន កសិករធំៗក្នុងភូមិក៏ជាអ្នកជំនួញ និងអ្នកចងការប្រាក់ផងដែរ ដោយធ្វើសកម្មភាពខ្លួនឯងផ្ទាល់ ឬធ្វើតាមរយៈបណ្តាញសាច់ញាតិ ។ ការ "រកស៊ីផ្តាច់មុខចាក់ស្រេះគ្នា" បែបនេះ ធានាឱ្យមនុស្សមួយក្រុមតូច អាចត្រួតត្រាលើធនធានមូលដ្ឋានមួយភាគធំ ។
- ប្រភពឥណទានស្ថាប័នមានតិចតួច, មូលដ្ឋានធនធាន និងការគ្របដណ្តប់របស់ស្ថាប័នឥណទាននៅមានកំរិត, នីតិវិធីវែងស៊ីពេលយូរដើម្បីបានទទួលឥណទាន, ហើយអត្រាការប្រាក់ស្ថាប័នក៏មិនថោកដែរ ។ កត្តាទាំងអស់នេះធ្វើឱ្យឥណទានស្ថាប័នគ្មានលក្ខណៈទាក់ទាញចិត្ត ។

## ២.៥. ប្រជាជន ចំណាកស្រុក និងទីផ្សារពលកម្ម

ផ្នែកនេះបង្ហាញពីយុទ្ធសាស្ត្រផ្សេងៗសំរាប់រស់រានជីវិត ដែលបានសង្កេតឃើញនៅក្នុងភូមិគំរូតាង ហើយប្រជាជនបានប្រកាន់យក ដើម្បីប្រឈមមុខនឹងកំណើនប្រជាជន និងការប្រែប្រួលក្នុងកសិកម្ម។

ប្រជាជនមានកំណើននៅគ្រប់មូលដ្ឋាន ។ ទោះបីចំនួនប្រជាជនសរុបនៅកម្ពុជាមិនធំក៏ដោយ ក៏លំនាំនៃការប្រើប្រាស់ធនធានបច្ចុប្បន្ន (ការប្រើប្រាស់ដីធ្វើកសិកម្មផ្លាស់ទីក្នុងតំបន់ខ្លះ, ធាតុចូលតិច/ផលិតភាពទាប ក្នុងកសិកម្មនៅមូលដ្ឋានជាច្រើន, ការងារក្រៅកសិដ្ឋានមិនគ្រប់គ្រាន់...) ព្រមទាំងរចនាសម្ព័ន្ធប្រជាសាស្ត្រមានអ្នកពឹងផ្អែកច្រើន[២៥] ធ្វើឱ្យគ្រួសារជាច្រើនមានជីវភាពយ៉ាប់យ៉ឺន ។ ភូមិក្រសាំង ភូមិបាបោង និងភូមិកំពង់ត្នោត បានទទួលជនមាតុភូមិនិវត្តន៍មួយចំនួនតូចនៅដើមទសវត្សរ៍១៩៩០, ឯនៅភូមិព្រៃកក្មេង និងភូមិដងក្តារ គេរាយការណ៍ថា ជាទូទៅគឺមានជនចំណាកស្រុកចូលមកតាំងទីលំនៅក្នុងរយៈពេលយូរ ។ កំនើន ប្រជាជននៅក្នុងទសវត្សរ៍ចុងក្រោយមានកំរិត ២%-២,៥%[២៦] ។

ពលករជាច្រើនជួលពលកម្មរបស់ខ្លួននៅនឹងមូលដ្ឋាននៅភូមិជិតៗ ឬនៅភូមិ/ទីក្រុងឆ្ងាយៗ ហើយអ្នកខ្លះធ្វើចំនាកស្រុកទៅបរទេសដើម្បីរកការងារធ្វើ (លើកលែងតែនៅដងក្តារ) ។ តាមពិតចំនាកស្រុកដើម្បីរកការងារធ្វើកំពុងក្លាយជាយុទ្ធសាស្ត្រសំរាប់ការរស់រានជីវិតដ៏សំខាន់មួយរបស់ជនក្រីក្រ ។ ពិតណាស់ លំនាំនៃការបែងចែកពលកម្មនៅមូលដ្ឋានមានលក្ខណៈផ្សេងៗគ្នា អាស្រ័យទៅលើលទ្ធភាពនៃវិស័យសកម្មភាពនីមួយៗក្នុងការបង្កើតការងារ និងលំនាំនៃការកាន់កាប់ទ្រព្យសម្បត្តិ ។ ពត៌មានពិស្តារពីរឿងនេះ មានបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយដាច់ដោយឡែកមួយស្តីពីរបកគំហើញនៃការសិក្សាបែបបរិមាណ ។

### *២.៥.១. ការចំណាកស្រុក*

នៅភូមិក្រសាំង ក្នុងចន្លោះពេលពីខែសាបស្រូវ ដល់ខែច្រូតកាត់ស្រូវវស្សា, អ្នកគ្មានដី និងកសិករធុនតូចធ្វើដំណើរឆ្ងាយៗទៅប្រទេសថៃ ដើម្បីរកការងារធ្វើ ពីព្រោះនៅពេលនោះតំរូវការពលកម្មនៅមូលដ្ឋានមានតិច ធ្វើឱ្យប្រជាជនជាច្រើន

---

[២៥] ការយោងលើរចនាសម្ព័ន្ធប្រជាសាស្ត្រមានលក្ខណៈសមស្របក្នុងករណីនេះ ពីព្រោះមនុស្សនៅក្នុងបន្ទុកមានចំនួនច្រើនពេក ធៀបនឹងចំនួនអ្នករកចំណូល ហើយស្ថានភាពកើតចេញពីអត្រាមានកូនដ៏ខ្ពស់នៅក្នុងទសវត្សរ៍១៩៨០ និង ១៩៩០ ។

[២៦] ចំពោះតួលេខ សូមមើលឧបសម្ព័ន្ធ និងការសិក្សាមុនៗស្តីពីភូមិបី ក្នុងចំណោមភូមិទាំងប្រាំមួយ (Mushid 1998) ។

ប្រឈមនឹងកង្វះខាតស្បៀង ។ អ្នកធ្វើចំណាកស្រុកភាគច្រើន គឺបុរស-ស្ត្រីពេញកំលាំង ដែលទៅបំរើការងារគ្មានជំនាញ និងពាក់កណ្តាលជំនាញនៅតាមបណ្តោយព្រំដែនថៃ ឬក៏ចូលជ្រៅទៅក្នុងប្រទេសថៃ ។ អ្នកគ្មានដីស្រែធ្វើចំណាកស្រុករយៈពេលយូរជាងគេ ។ ជាទូទៅប្រាក់កំរៃជាមធ្យមគឺ ៨០-១០០បាតក្នុងមួយថ្ងៃ (ប្រហែល២,២៥ដុល្លារ) ខ្ពស់ជាងប្រាក់កំរៃនៅក្នុងមូលដ្ឋានច្រើនណាស់[២៧] ។ អ្នកគ្មានដីក៏ធ្វើចំណាកស្រុកនៅក្នុងប្រទេសដែរ ដើម្បីទៅធ្វើជាពលករស៊ីឈ្នួលប្រចាំថ្ងៃ អ្នកដួញដូរ និងកម្មករដឹកជញ្ជូននៅតាមកន្លែងជិតៗភូមិ ។ ប្រាក់កំរៃ ៥០-៦០បាតក្នុងមួយថ្ងៃ រួមទាំងបាយមួយពេលផង (សរុបទៅប្រហែល ៧.០០០រៀល) អាចចាត់ទុកថាសមរម្យហើយនៅក្នុងមូលដ្ឋានទាំងនេះ ។

នៅភូមិបាបោង និងត្រពាំងប្រិយ, ពលករជាច្រើននៃគ្រួសារគ្មានដី និងគ្រួសារមានដីតូច តែងជួលពលកម្មរបស់ខ្លួននៅតាម ស្រុកជិតខាង នៅក្នុងរដូវវស្សា ។ នៅឆ្នាំ២០០១ ពលករខ្លះក្នុងភូមិទាំងពីរនេះ បានសន្យាផ្គត់ផ្គង់ពលកម្មឱ្យគេជាមុនដើម្បីបានកំរៃ ។ គេប្រាប់ថា កំរៃប្រចាំថ្ងៃជាមធ្យមគឺ ៥.០០០-៦.០០០រៀលសំរាប់ការងារសំណង់ ។ នៅភូមិទាំងពីរ ចំណាកស្រុកចេញកាន់តែមានច្រើន ដែលបានជួយទ្រទ្រង់យ៉ាងសំខាន់ដល់សន្តិសុខស្បៀងក្នុងគ្រួសារ ។ យុវជន និងយុវនារី ឥឡូវធ្វើដំណើរឆ្ងាយៗ មិនមែនទៅកាន់ស្រុកជិតខាង ដូចកាលពីឆ្នាំ១៩៩០-១៩៩៥ នោះទេ ។ ខុសគ្នាពីឆ្នាំ១៩៩៦-១៩៩៧ដែរ ឥឡូវនេះបុរស និងស្ត្រីធ្វើចំណាកស្រុកចេញក្នុងចំនួនប្រហាក់ប្រហែលគ្នា[២៨] ។ គេប្រាប់ថា នារីក្មេងៗនៅភូមិនេះ ចាកចេញពីភូមិទៅធ្វើកម្មករក្នុងរោងចក្រកាត់ដេរ ឬធ្វើជាអ្នករត់តុក្នុងភោជនីយដ្ឋាននៅឯទីក្រុង ។ ប៉ុន្តែក្នុងចំនោមអ្នកក្រ គឺមានតែអ្នកមានប្រាក់កាសខ្លះប៉ុណ្ណោះដែលអាចរកការងារបាន ដូចជាការងារក្នុងរោងចក្រកាត់ដេរជាដើម (ប្រាក់ខែ ៤០-៦០ដុល្លារក្នុងមួយខែ) ។ អ្នកក្រីក្រខ្លាំងនៅតែត្រូវធ្វើចំណាកស្រុកទៅតំបន់ជិតៗ ពីព្រោះគ្មានប្រាក់សំរាប់ដោះស្រាយសោហ៊ុយធ្វើចំណាកស្រុកផ្លូវឆ្ងាយ ។ ហេតុការណ៍ទាំងអស់នេះបង្ហាញថា លទ្ធភាពមានការងារធ្វើនៅមូលដ្ឋានបានធ្លាក់ចុះ ឯតំរូវការការងារស៊ីប្រាក់កំរៃ/ការងារបង្កើតចំណូលបានកើនឡើង ។

ចំណុចគួរចាប់អារម្មណ៍មួយទៀត គឺយ៉ាងហោចណាស់នៅភូមិបាបោង (និងនៅក្រសាំង/ក៏រិតតូច) ស្រូវប្រជេញទឹក (ដំណាំរដូវប្រាំង) វាបង្កើនតំរូវការជួលកំលាំងពលកម្មនៅរដូវប្រមូលផលពីខែមករា ដល់មេសា ។ នៅបាបោង តំរូវការនេះទាក់ទាញ*ជនចំណាកស្រុកចូល*តាមរដូវ ប្រហែល ៤០០-៥០០នាក់ពីស្រុកជិតខាង ។ ភូមិព្រៃកក្មេងក៏មានទទួលជនចំណាកស្រុកចូលដែរ ដោយសារភូមិនេះមានធនធាននេសាទ ។ ភូមិដងក្តារ ទទួលជនចំណាកស្រុកចូលជាយូរមកហើយដោយសារធនធានព្រៃឈើរបស់ភូមិនេះ ។

## *២.៥.២. ការជួលពលកម្មឱ្យគេនៅក្នុងភូមិ*

នៅតំបន់ដែលវិធីធ្វើកសិកម្មទំនើបបានចាក់ឫស កំលាំងពលកម្មស៊ីឈ្នួលកំពុងតែជំនួសកំលាំងពលកម្មប្រវាស់ដៃ រវាងគ្រួសារនានា ។ ឧទាហរណ៍ ការប្រវាសដៃ ក្នុងការស្ទូង ច្រូតកាត់ និងបោកបែន បានត្រូវជំនួសដោយទំនាក់ទំនង ផ្អែកលើប្រាក់កំរៃ ។ អ្នកខ្លះបានចាប់យកការងាររែកដី[២៩] ។ នៅតំបន់មានកសិកម្មអន់ថយ កសិករធុនតូច និងអ្នកគ្មានដី ដែលមិនធ្វើចំណាកស្រុក, បានធ្វើការជាពលករបណ្តោះអាសន្នឱ្យកសិករធុនធំ ។ ដោយសារពេលត្រូវធ្វើការដកស្ទូង វាមានលក្ខណៈសំខាន់បំផុត, ការជួលពលកម្មស៊ីប្រាក់កំរៃកាន់តែមានប្រជាប្រិយភាពនៅភូមិក្រសាំង និងបាបោង ។ ពលកម្មស៊ីប្រាក់កំរៃ បានផុសឡើង

[២៧] អ្នកខ្លះបានត្អូញត្អែរថា ការរកស៊ីនៅថៃ ពេលខ្លះមិនយុត្តិធម៌ទេ ។ ដូចជា សឿន អាយុ២៨ឆ្នាំ ដែលទើបត្រលប់ពីធ្វើការនៅថៃបានមួយខែ (ចុងឆ្នាំ២០០១) បានប្រាប់ថា គេបានសន្យាឱ្យគាត់ ១០០បាត/ថ្ងៃ ប៉ុន្តែបន្ទាប់ពីធ្វើការបាន ៧ខែ គេបើកប្រាក់ឱ្យគាត់តែ ៤ខែ ។ ជាច្រើននាក់បានខ្ចីលុយគេច្រើនៗដើម្បីដោះស្រាយចំណាយក្រៅផ្លូវការធ្វើដំណើរទៅថៃ ប៉ុន្តែគេពុំបានចំណេញទាំងអស់គ្នានោះទេ ។

[២៨] ទិន្នន័យសំរាប់ឆ្នាំ១៩៩៦ និង ១៩៩៧ អាចរកមើលនៅក្នុងឯកសារ Mc Andrew (1998) ។

[២៩] ដោយសារនៅក្នុងកសិកម្មប្រើគ្រឿងយន្ត មានតំរូវការពលកម្មតិច ចំនួនការងារសរុបក៏បានធ្លាក់ចុះ ។ ដូច្នេះហើយកសិករខ្លះបានចាប់យកការងារដឹក/ជញ្ជូនដី ។

ដោយសារយន្តកម្មកសិកម្ម ហើយមួយផ្នែកដោយសារការបើកឱ្យមានទីផ្សារ ។

អាត្រាកំរៃពលកម្មមានកំរិតទាបនៅគ្រប់ទីកន្លែង គឺស្ទើរតែមិនអនុញ្ញាតឱ្យរស់រានបានទេ ។ នៅឆ្នាំ២០០១ ឈ្នួលស្ទូងនៅភូមិក្រសាំងគឺ ១.៥០០-២០០០រៀល សំរាប់សំណាប ៤០កណ្តាប់ ដោយមានឱ្យបាយថ្ងៃត្រង់មួយពេល ។ ការងារស្ទូងស៊ីពេលប្រហែលកន្លះថ្ងៃ ឬជាងកន្លះថ្ងៃបន្តិច ។ កំរៃសំរាប់ការងារភ្ជួរគឺ ៥.០០០រៀលសំរាប់រយៈពេលកន្លះថ្ងៃដែលទូទាត់សងដោយគិតតាមចំនួនពេល ។ ការងារគេទូទាត់សងជាប្រាក់ ជារបស់ ឬក្នុងករណីតិចតួចជាការផ្តល់ពលកម្មឱ្យវិញ ។ នៅបាបោងកំរៃប្រចាំថ្ងៃគឺ ២.៥០០-៣.០០០រៀល និងបាយពីរពេលសំរាប់ការស្ទូង ឬ ៤.០០០រៀលក្នុងមួយថ្ងៃសំរាប់ការងារច្រូតកាត់[៣០] ។ កំរៃសំរាប់ការជីកដីនៅត្រពាំងប្រិយគឺ ៣០០០រៀល សំរាប់ដី ១ម$^{៣}$ ហើយគេអាចរកបានជាមធ្យម ៤.០០០-៦០០០រៀលក្នុងមួយថ្ងៃ ។ នៅភូមិកំពង់ត្នោត កំណើនចំនួនគ្រួសារគ្មានដី ជាហេតុផលមួយចំណែកនៃការបាត់បង់ប្រព័ន្ធប្រវាស់ដៃ[៣១] ។ គ្រួសារស្ត្រីដឹកនាំជាច្រើនអាចរកបានប្រាក់កំរៃប្រចាំថ្ងៃ ដោយប្រមូលអំបិល (កំពង់ត្នោត) ជីកប្រឡាយ ស្ទូង ច្រូត រែកដី... ។ ពលករយកកំរៃនៅក្នុងកសិដ្ឋានស្រែអំបិល អាចទទួលបាន ៣.៥០០រៀលក្នុងមួយថ្ងៃនៅពេលធម្មតា និង ៧.០០០រៀលក្នុងមួយថ្ងៃនៅពេលប្រមូលផល មមាញឹកដែលមានតែ ១ខែប៉ុណ្ណោះក្នុងមួយឆ្នាំ ។

*សេចក្តីសង្ខេបទូទៅ*

- ក្នុងភូមិពយ៉ាងតិច, ចំណាកស្រុក និងការងារយកកំរៃ កំពុងមានកំណើន ដោយសារការងារនៅតាមមូលដ្ឋានកាន់តែពិបាករក សំរាប់កំលាំងពលកម្មដែលបន្តកើនឡើង ហើយកំរិតប្រាក់កំរៃក៏បានត្រឹមតែមួយរស់ ។ ចំណុចគួរចាប់អារម្មណ៍ គឺចំណាកស្រុកមានកំរិតខ្ពស់នៅក្នុង ១ភូមិមួយយ៉ាងតិច (ក្រសាំង) ដែលកំពុងឆ្លងកាត់ទំនើបភាវូបនីយកម្មកសិកម្ម ។ ស្ថានភាពនេះបង្ហាញថា ទោះបីទំនើបភាវូបនីយកម្ម ពង្រីកទំនាក់ទំនងទីផ្សារក៏ដោយ ក៏វាមិនសុទ្ធតែជួយជំរុញឱ្យមានការបែងចែកយ៉ាងប្រសើរនូវផលចំណេញនោះទេ ។ តាមរយៈការធ្វើចំណាកស្រុកចេញពីក្រសាំង ហើយឆ្លងដែនទៅធ្វើការងារនៅក្នុងប្រទេសថៃ គេអាចទទួលបានកំរៃពលកម្មខ្ពស់ដល់ទៅពីរដងនៃកំរិតប្រាក់កំរៃនៅក្នុងមូលដ្ឋាននៅកម្ពុជា ប៉ុន្តែការធ្វើដំណើរមិនមែនងាយស្រួលរហូតទេ ពីព្រោះចំណាកស្រុកឆ្លងដែនវាមានគ្រោះថ្នាក់របស់វា ។
- ចំណាកស្រុកនៅក្នុងប្រទេស ធ្វើឱ្យគេទទួលបានកំរៃខ្ពស់ជាងនៅក្នុងការងារពាក់កណ្តាលជំនាញ និងក្នុងសកម្មភាពមិនមែនកសិកម្ម (ដូចជា ការងារនៅរោងចក្រកាត់ដេរ និងធ្វើជាងស៊ីម៉ង់) តែប្រាក់កំរៃមានកំរិត ទាបជាងសំរាប់ការងារមានជំនាញទាបដូចជាការរែកដីជាដើម ។ នៅក្នុងវិស័យកសិកម្ម កំរៃពលកម្មបានត្រឹមតែមួយរស់ ប៉ុន្តែការងារចំពេលខ្លះ ដូចជាពេលប្រមូលផលជាដើម អាចផ្តល់កំរៃខ្ពស់ ។
- ការប្រើប្រាស់ពលកម្មយកកំរៃកំពុងចូលមកជំនួស ការប្រវាស់ដៃយ៉ាងលឿន ។ ការធ្វើយន្តកម្មកសិកម្ម, ការជ្រៀតចូលនៃទីផ្សារ, កំណើនប្រជាជន, និងការពុះចែកដីតូចៗ, បានរួមចំណែកគ្នាធ្វើឱ្យពលកម្មយកកំរៃកើនឡើង ។ ទោះបីប្រាក់កំរៃទាំងនេះ ស្ថិតក្នុងកំរិតត្រឹមតែមួយរស់ក៏ដោយ ក៏ប្រជាជននៅតែចូលចិត្តធ្វើការងារពលកម្មយកឈ្នួល ពីព្រោះវាជួយបង្កើនចំនួនថ្ងៃធ្វើការងារក្នុងមួយឆ្នាំៗ នៅក្នុងរបបសេដ្ឋកិច្ច មួយដែលពឹងផ្អែកជាសំខាន់លើដំណាំតែមួយមុខ ។

---

[៣០] ប៉ុន្តែផ្ទុយទៅវិញ ម្ចាស់ត្រាក់ទ័រអាចរកចំនួលបាន ១០០.០០០រៀលសំរាប់ការភ្ជួរ ឬរាស់ ដី ១ហ.ត, ម្ចាស់ម៉ាស៊ីនបូមទឹកអាចរកចំនួលបាន ២.៥០០-៣០០០រៀលក្នុង*ប្រេងមួយលីត្រ* ពីការជួលបរិក្ខារ ឯម្ចាស់ម៉ាស៊ីនបោកស្រូវអាចទទួលបានស្រូវ១បាវ ពីការបោកស្រូវ៣០បាវ ។

[៣១] គេគួរចងចាំជាសំខាន់ថា ការប្រវាស់ដៃអាចធ្វើទៅបាន តែចំពោះកសិករដែលមានដីៈ គេអាចចែករំលែកពលកម្មឱ្យគ្នាទៅវិញទៅមក ដើម្បី ប្រើប្រាស់ធនធានមនុស្សមានប្រសិទ្ធិភាពខ្ពស់បំផុត ។

# ជំពូកទី ៣

# សំយោគពីការអង្កេតនៅមូលដ្ឋាន

បញ្ហាចំបងៗដែលផុសចេញពីរបកគំហើញជាគន្លឹះមួយចំនួននៅក្នុងការចុះសិក្សាតាមមូលដ្ឋាន ដែលបានបង្ហាញជូនខាងលើមានរៀបរាប់សង្ខេបនៅក្នុងផ្នែកផ្សេងៗដូចតទៅ :

## ៣.១. បញ្ហាប្រជាសាស្ត្រ

ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ គេឃើញមានកំណើនប្រជាជនយ៉ាងច្បាស់ បើប្រៀបធៀបទៅនឹងទសវត្សរ៍នានាមុនឆ្នាំ១៩៨០ ។ សភាពការណ៍នេះ បានធ្វើឱ្យធនធានដែលមានស្រាប់ កាន់តែមិនគ្រប់គ្រាន់ឡើងសំរាប់បំពេញតំរូវការក្នុងជីវភាព នៅក្នុងក្របខ័ណ្ឌបច្ចុប្បន្ននៃធនធាន បច្ចេកវិទ្យា និងចំណេះដឹង ។ ម្យ៉ាងទៀត មិនមែនមានតែកំណើនប្រជាជនមួយមុខទេ ប៉ុន្តែពីរ៉ាមីតប្រជាជន ( មានកុមារច្រើន ធៀបនឹងចំនួនអ្នករកចំណូល) បានប៉ះពាល់មិនល្អដល់សន្តិសុខស្បៀងគ្រួសារ ដោយសារប្រាក់ចំណូលគិតក្នុងមនុស្សម្នាក់ មានកំរិតទាប ។ លើសពីនេះទៀត ដោយសារមានបុរសស្លាប់ច្រើនពេក ( ដោយសង្គ្រាម... ) អតុល្យភាពខាងភេទក៏កើតមានឡើង ជាពិសេសគឺមានគ្រួសារស្ត្រីដឹកនាំយ៉ាងច្រើន ដែលសព្វថ្ងៃពុំសូវមានមធ្យោបាយគ្រប់គ្រាន់ទេសំរាប់ធ្វើការបង្កបង្កើនផល ហើយរឿងនេះបានប៉ះពាល់ដល់សន្តិសុខស្បៀងគ្រួសារ ។

## ៣.២. សំពាធនៃបរិស្ថាន និងការធ្លាក់ចុះនៃធនធានធម្មជាតិ

គុណភាពនៃបរិស្ថានធម្មជាតិកំពុងតែស្រុតចុះ ( ទឹក ត្រី ព្រៃកោងកាង ព្រៃឈើ... កំពុងតែជួបការតានតឹងកាន់តែខ្លាំង) ដោយសារមានតំរូវការកាន់តែច្រើនលើធនធានទាំងនេះ ដោយគ្មានបំពេញការប៉ះប៉ូវវិញទេ, ដែលធ្វើឱ្យការរកចិញ្ចឹមជីវិតកាន់តែលំបាក និងគ្មានចីរភាព ។ រឿងនេះកើតឡើង ដោយការផ្គត់ផ្គង់មានភាពយឺតកំរិតទាប (low supply elasticity) ដោយសារបច្ចេកទេសមានការផ្លាស់ប្តូរតិចតួចពេក, ការគ្រប់គ្រងមិនល្អលើធនធានធម្មជាតិ និងការប្រើប្រាស់គ្មានលក្ខណៈវិទ្យាសាស្ត្រ ។ ទោះបីក្នុងរយៈពេលដ៏ខ្លីប្រហែលមួយទសវត្សរ៍ក៏ដោយ ក៏អាចមើលឃើញពីផលប៉ះពាល់អាក្រក់នេះដែរ ។ ថ្វីបើសហគមន៍ក្នុងភូមិ មិនបានបង្កឡើងនូវការធ្លាក់ចុះទាំងនេះក៏ដោយ (តាមពិតតំរូវការភាគច្រើនផុសចេញពីអ្នកនៅខាងក្រៅសង្គមកសិកម្ម) ក៏ពួកគេនេះឯងដែលត្រូវតែប្រឈមមុខនឹងផលវិបាកផ្សេងៗ ។

## ៣.៣. ការលេចចេញនូវវិសមភាពដី និងភាពគ្មានដីធ្លី

វិសមភាពនៃការបែងចែកដី និងភាពគ្មានដីធ្លី បានផុសឡើងដោយសារមូលហេតុជាច្រើន គឺមានកំណើនភ្លាមៗនូវតំរូវការដីធ្លីពីប្រភពជាច្រើន ( មិនមែនសំរាប់តែកសិកម្មជីវព្រឹត្តិមួយមុខទេ), ការពាក់ព័ន្ធនឹងទីផ្សារ (market exposure), ការចូលមកដល់នៃសេដ្ឋកិច្ចប្រើប្រាក់កាស និងកំណើនប្រជាជន ។ មនុស្សមួយចំនួនតូចមានលទ្ធភាពប្រមូលយកដីបានធំៗ ឯអ្នកឯទៀត

មិនបានទទួលអត្ថប្រយោជន៍ទាំងអស់គ្នាទេ ។ ម្យ៉ាងទៀត និចលភាពនៃសកម្មភាពកសិកម្ម និងមិនមែនកសិកម្ម ទាមទារឱ្យមាន សាច់ប្រាក់យ៉ាងច្រើនសំរាប់ធ្វើដើមទុន ។ បើកសិករគ្មានប្រាក់ទេ គេត្រូវតែខ្ចីបុល ជាទូទៅគឺខ្ចីពីអ្នកចងការប្រាក់ ។ បើសិនមិន អាចសងបំណុលទាន់ពេលទេ ដីធ្លី/ទ្រព្យសម្បត្តិមួយចំណែក ឬទាំងអស់អាចត្រូវបាត់បង់ ។ មានរបាយការណ៍ជាច្រើនស្តីពីដីធ្លី ដែលផ្លាស់ប្តូរម្ចាស់ពីកសិករធុនតូចមានធនធានតិច ទៅកសិករធុនធំមានធនធានច្រើន ដែលបង្កឱ្យមានវិសមភាពដី និងទ្រព្យ សម្បត្តិ ហើយរឿងនេះបានបង្កបញ្ហាអសន្តិសុខស្បៀងចំពោះកសិករធុនតូច ។ អ្នកមានធនធានក៏បានពង្រឹងស្ថានភាពខ្លួនផងដែរ តាមរយៈបណ្តាញសាច់ញាតិ គឺគេចែករំលែកធនធានរបស់គេឱ្យគ្នាទៅវិញទៅមក ដើម្បីពង្រីកទំហំទ្រព្យសម្បត្តិរបស់គេ ។

## ៣.៤. ការពុះចែកដីតូចៗ

នៅតាមកន្លែងជាច្រើន គិតតាមលក្ខណៈសេដ្ឋកិច្ច និងបច្ចេកវិទ្យា ដីមួយប្លង់ៗត្រូវបានគេពុះចែកបន្តរហូតដល់កំរិតមួយ ដែលដីធ្លីទាំងនេះលែងអាចធ្វើអាជីវកម្មរស់បានទៀត ។ គេមិនអាចធ្វើវិនិយោគដោយលក្ខណៈប្រាកដនិយមលើដីនេះ និងមិនអាចធ្វើការដាំដុះអតិផលដោយប្រើប្រាស់ធាតុចូលទំនើបបានទេ ។ គ្រួសារដែលដាំដុះលើដីតូចៗ ត្រូវចាញ់ប្រៀបគេទាំងពីរយ៉ាង គឺដីធ្លីតិច និងទិន្នផលទាប ។

មតិស្តីពីគុណវិបត្តិនៃដីតូចៗពេក ក៏អាចលើកឡើងចំពោះការងារមិនមែនកសិកម្មផងដែរ ។ ឧទាហរណ៍ អ្នកនេសាទធុនតូចក្នុងពេលបច្ចុប្បន្ន មិនអាចឆក់យកឱកាសល្អដែលទីផ្សារផ្តល់ឱ្យដូចជាទាក់ទិននឹងធាតុចូល ឬទីផ្សារផលិតផល ។ គេក៏ពុំមានលទ្ធភាពប្រើប្រាស់វិធីសាស្ត្រទំនើប ដើម្បីបង្កើនទិន្នផលឱ្យដល់កំរិតអតិបរិមាដែរ ។

## ៣.៥. ការធ្វើយន្តកម្មយន្តកសិកម្ម និងការបែងចែកផលចំណេញ

កន្លងមកមានការធ្វើយន្តកម្មមួយចំនួន ក្នុងសកម្មភាពកសិកម្ម និងសកម្មភាពក្រៅកសិដ្ឋាន ។ ឧទាហរណ៍ ការប្រើប្រាស់គ្រឿងយន្ត កំពុងមកជំនួសកំលាំងសត្វអូសទាញក្នុងកំរិតផ្សេងៗនៅស្ទើរគ្រប់ទីកន្លែងទាំងអស់ (ប្រហែលលើកលែងតែខេត្តកំពង់ធំ) ឯទូកម៉ាស៊ីនត្រូវបានគេប្រើប្រាស់សំរាប់ការនេសាទ ។ ដោយសារគ្រឿងយន្តមានទំហំធំ ហើយថ្លៃខ្ពស់ ដូច្នេះគឺកសិករធុនធំដែលជាអ្នកកាន់កាប់គ្រឿងយន្តទាំងនេះដោយចៀសមិនផុត ។ ដូច្នេះ ដំណើរការនេះវាផ្តល់អត្ថប្រយោជន៍ដល់កសិករដែលមានដីចាប់ពីទំហំណាមួយឡើងទៅ ។ ដូចគ្នាដែរ ម្ចាស់ទូកម៉ាស៊ីនទទួលផលចំណេញច្រើនជាងអ្នកគ្មានបរិក្ខារគ្រឿងយន្ត ។ ទោះបីជាផលិតភាពជាទូទៅនៃប្រព័ន្ធបានកើនឡើង ប៉ុន្តែកសិករធុនតូចមិនមែនសុទ្ធតែបានចំណេញច្រើនដូចគេទេ ពីព្រោះមិនសូវមានប្រាក់ សំរាប់ជួលគ្រឿងម៉ាស៊ីន ហើយត្រូវប្រើប្រាក់កំចីមានការប្រាក់ខ្ពស់ហួសប្រមាណ ជាបន្ថែមទៅលើការបញ្ចាំទ្រព្យធនរបស់គេ ។ ថ្លៃជួលម៉ាស៊ីនមានកំរិតខ្ពស់ ។ រឿងនេះមួយចំណែកគឺដោយសារថ្លៃម៉ាស៊ីនខ្ពស់នៅក្នុងប្រទេសជិតខាង (ប្រភពនាំចូល), បន្ទុកចំណាយខ្ពស់ក្នុងការប្រើប្រាស់ម៉ាស៊ីន, និងកំរិតចំណេញខ្ពស់របស់អ្នកផ្គត់ផ្គង់សេវា ។ កត្តាទាំងអស់នេះបានប៉ះពាល់មិនល្អដល់សេដ្ឋកិច្ចនៃការគ្រប់គ្រងកសិដ្ឋានតូចៗ ។

## ៣.៦. នំនើបកម្មកសិកម្ម

នៅតាមមូលដ្ឋានជាច្រើន មានការប្រើប្រាស់ធាតុចូលទំនើបមួយចំនួនក្នុងវិស័យកសិកម្ម ដូចជាការប្រើពូជស្រូវមានទិន្នផលខ្ពស់ ជី ថ្នាំសំលាប់សត្វល្អិត... ។ ក្នុងករណីជាច្រើន ទិន្នផលឡើងខ្ពស់ដល់ ៣តោន ទៅ ៣,៥តោនក្នុងមួយហិកតា (ក្រសាំង, បាបោង) ។ ប៉ុន្តែដោយសារពុំទាន់មានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់, ការធ្វើស្រែអនុវត្តបានតិចលើកនៅឡើយ ហើយទិន្នផលក៏មិនទាន់បានខ្ពស់ដល់កំរិតជាសក្តានុពល ៤,០-៤,៥តោនក្នុងមួយហិកតានោះដែរ ។

រាល់ធាតុចូលត្រូវបាននាំចូលក្នុងតំលៃមួយដែលកំណត់ពីខាងក្រៅ ប៉ុន្តែធាតុចេញមានថ្លៃទាប និងឡើងចុះតាមរដូវ ។ ក្នុងករណីជាច្រើន ថ្លៃធាតុចេញត្រូវបានកំណត់ដោយថ្លៃដ៏ទាបនៃផលិតផលនាំចូលពីប្រទេសជិតខាង ដោយសារព្រំដែនស្ទើរតែបើកចំហទាំងស្រុង ។ ក្នុងបញ្ហានេះលក្ខខណ្ឌនៃការដោះដូររវាងផលិតផលកសិកម្ម ហើយនឹងធាតុចូល/សំភារៈទំនើបៗ ( ម៉ាស៊ីនជី និងថ្នាំសំលាប់សត្វល្អិត) មិនមែនសុទ្ធតែអំណោយផលចំពោះវិស័យកសិកម្មនោះទេ[៣២] ។ ក្នុងកាលៈទេសៈបច្ចុប្បន្ន ផលចំណេញពីបច្ចេកវិទ្យាទំនើប និងផលិតភាពខ្ពស់ គឺមិនបានទៅដល់កសិកររាល់ៗលើកទេ ។

## ៣.៧. អសុក្រិតភាព និងការត្រួតត្រាទីផ្សារ

ទោះបីលក្ខខណ្ឌនៃការដោះដូរបានប៉ះពាល់មិនល្អដល់វិស័យកសិកម្មទាំងមូលក្តី ក៏ពួកកសិករវៃឆ្លាត និងអាជីវករគេមាន មធ្យោបាយផ្ទេរផលប៉ះពាល់ទៅឱ្យកសិករតូចៗ ។ ក្នុងរឿងនេះ យន្តការមួយចំនួនដូចជា កំរៃទាប ការប្រាក់ខ្ពស់ និងចំណាយ លើដើមទុនខ្ពស់ (ដូចជា សំរាប់ជួលបរិក្ខារ) ត្រូវបានគេប្រើប្រាស់យ៉ាងទូលំទូលាយ ។ ម្យ៉ាងទៀត កសិករធុនធំជាច្រើន ក៏ជា អ្នកត្រួតត្រាធាតុចូល និងទីផ្សារផលិតផលនៅមូលដ្ឋាន ហើយក្នុងករណីជាច្រើន ក៏ជាអ្នកចងការប្រាក់ផងដែរ ។ អសុក្រិតភាព នៃទីផ្សារនេះដែលឈ្មួញកណ្តាលត្រួតត្រាបានយ៉ាងទូលំទូលាយ វាមិនសូវល្អទេសំរាប់ផលប្រយោជន៍របស់ប្រជាជនគ្រប់គ្នា ។ នៅក្នុងករណីជាច្រើន អសុក្រឹតភាពនៃទីផ្សារក៏បង្កឡើងផងដែរដោយហេដ្ឋារចនាសម្ព័ន្ធយ៉ាប់យ៉ឺន និងកង្វះខាតពត៌មាន ។

ដោយមានយន្តការស្ថានប័នតិចតួចពេកសំរាប់ទប់ទល់នឹងការប្រែប្រួលថ្លៃ (កំចីងាយស្រួលពីធនាគារ ការគាំទ្រថ្លៃ...) កសិករធុនតូចប្រឈមមុខនឹងការជំពាក់បំណុលអ្នកចងការប្រាក់ជាប់រហូត ។ ចំណាយដឹកជញ្ជូនខ្ពស់ខ្លាំង ពត៌មានស្តីពីទីផ្សារ និងថ្លៃមានតិចតួច, កិច្ចការពារទប់ទល់នឹងការខូចខាតផលិតផលមានកំរិតតិចតួចបំផុត, ទាំងអស់នេះលុបបំបាត់អត្ថប្រយោជន៍ទីផ្សារសំរាប់ជនក្រីក្រ និងលើកទឹកចិត្តឱ្យការរកស៊ីផ្តាច់មុខរីកដុះដាល ។ កន្លងមកមានកិច្ចប្រឹងប្រែងបង្កើតឥណទានស្ថាប័ន ប៉ុន្តែកិច្ចប្រឹងប្រែងទាំងនេះមានលក្ខណៈចោះៗ និងមិនសូវមានជោគជ័យទេ ។

## ៣.៨. ជំរើសការងារ និងប្រាក់ចំណូល

ចំនួនការងារកសិកម្មកំពុងថយចុះ ចំណែកឯការងារមិនមែនកសិកម្មមិនបានកើនឡើងលឿនគ្រប់គ្រាន់ទេ ។ គំលាតដែលកំពុងលេចចេញមករវាងតំរូវការការងារ និងការផ្គត់ផ្គង់ការងារ (សំខាន់ដោយសារការធ្វើយន្តកម្មកសិកម្ម ការបាត់បង់ទ្រព្យធនធានរួម ការបើកចំហព្រំដែនចំពោះទំនិញនាំចូលថោកៗ និងកំណើនយ៉ាងលឿននៃកំលាំងពលកម្ម) បានរួមចំណែកធ្វើឱ្យ មានការបារម្ភពីលទ្ធភាពមានប្រាក់កាស និងសន្តិសុខស្បៀងចំពោះប្រជាជនក្រីក្រ ។

ជាយុទ្ធសាស្ត្រសំរបសំរួល ប្រជាជនបានចាប់ផ្តើមចាប់យកការងារពលកម្មស៊ីប្រាក់កំរៃកាន់តែច្រើន ហើយក៏មានការធ្វើចំណាកស្រុកជាទៀងទាត់ដែរទៅកាន់ទីក្រុង តំបន់ជនបទផ្សេងទៀត ឬក៏ឆ្លងព្រំដែន ដើម្បីស្វែងរកការងារធ្វើ ។ ដោយសារជំរើសមុខរបរមានតិចតួច និងប្រាក់ចំណូលមានកំរិតទាប ការធ្វើចំណាកស្រុកក៏ជារឿងមួយគួរបារម្ភដែរ ។ នៅគ្រប់កន្លែងក្នុងប្រទេសកម្ពុជា កំរៃនៃការងារគ្មានជំនាញកំរបានលើសពី ៣.៥០០-៤.០០០រៀលក្នុងមួយថ្ងៃណាស់ ។ ទោះបីនៅថៃ ក៏បានប្រហែលតែ ៨០-១០០បាតក្នុងមួយថ្ងៃ ( ប្រហែល ២ដុល្លារ ប៉ុន្តែប្រាក់កំរៃសុទ្ធអាចតិចជាងនេះទៀត) ។

---

[៣២] ទោះបីគ្មានការសិក្សាចំៗពីលក្ខខណ្ឌនៃការដោះដូរទំនិញក្តី ក៏ការសិក្សាជាប់ទាក់ទិនមួយចំនួនដូចការសិក្សាដោយ Sik Boreak (សូមអាន Sok, Chea and Sik 2000) និងទិន្នន័យអំពីថ្លៃដែលបានប្រមូលនិងចងក្រងដោយ វបសអ ចាប់ពីឆ្នាំ១៩៩៧ បានផ្តល់ភស្តុតាងបញ្ជាក់ពីចលនាឃីតៗ និងអាក់ៗនៃថ្លៃស្បៀងកម្ពុជា បើធៀបនឹងថ្លៃទំនិញមិនមែនស្បៀងដែលកើនឥតឈប់ ។

ម្យ៉ាងទៀត គេគួរកត់សំគាល់ថា នៅក្នុងបរិបទនៃកំរៃពលកម្ម និងប្រាក់ចំណូល, ប្រាក់កំរៃពលកម្មប្រចាំថ្ងៃ មានកំរិតប្រហាក់ប្រហែលគ្នានៅគ្រប់មូលដ្ឋាន ដោយមិនទាក់ទិននឹងកំរិតធូរធារនៃតំបន់នីមួយៗទេ ។ ភាពខុសគ្នាជាចំបងរវាងតំបន់ធូរធារ និងតំបន់អន់ថយ គឺចំនួនថ្ងៃដែលគេអាចរកការងារបានធ្វើ ។ ដំណើរការនៃទីផ្សារពលកម្ម និចលភាពនៃប្រជាជនចំណាកស្រុក ស្ថានភាពរកស៊ីផ្តាច់មុខនៅមូលដ្ឋាន និងធនធានមនុស្សមានគុណភាពទាប គឺអាចជាកត្តាដែលគាបសង្កត់ឱ្យកំរៃពលកម្មនៅតែមានកំរិតទាប ។

# ជំពូកទី ៤

# ជំរើសគោលនយោបាយ

ក្រសួង-មន្ទីររបស់រដ្ឋាភិបាល ទីភ្នាក់ងារជំនួយអន្តរជាតិ និង NGOs បានធ្វើសេចក្តីថ្លែងការណ៍ខាងគោលនយោបាយជាច្រើនអំពីគោលការណ៍ និងវិធីសាស្ត្រផ្សេងៗសំរាប់វិស័យកសិកម្ម ការអភិវឌ្ឍន៍ជនបទ និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា (Brown and Timberman 1998; RCG 2002a; RGC 2002b) ។ គោលនយោបាយជាច្រើនត្រូវបានអនុវត្តលើកំណែទំរង់ដីធ្លី ទំនើបកម្មកសិកម្ម កំណែទំរង់ព្រៃឈើនិងការនេសាទ ការជំរុញមីក្រូឥណទាន និងការខិតខំទាញយកទឹកសំរាប់ការស្រោចស្រព ។ គោលនយោបាយនីមួយៗ បានជួយជំរុញកសិកម្ម និងសកម្មភាពជាប់ពាក់ព័ន្ធឱ្យរីកចំរើនបានមួយកំរិត និងបានជួយលើកកំពស់កំរិតជីវភាពប្រជាជន ។ ក្នុងនេះកិច្ចប្រឹងប្រែងមួយចំនួនធំ គឺសំដៅស្វែងរកដំណោះស្រាយក្នុងប្រភេទ*គ្រប់គ្រងមីក្រូ* ។ ប៉ុន្តែបញ្ហានៅកម្ពុជាទាមទារឱ្យមាន *ដំណោះស្រាយជាយថាក្រម* ជាបន្ថែមទៅលើវិធីសាស្ត្រនៅក្នុងប្រភេទគ្រប់គ្រងមីក្រូ[៣៣] ។ ឧទាហរណ៍ ដំណោះស្រាយជាយថាក្រមចំពោះបញ្ហាដីធ្លី ក៏នឹងដោះស្រាយផងដែរនូវបញ្ហាសន្តិសុខស្បៀង និងការគ្រប់គ្រងធនធានធម្មជាតិ ប៉ុន្តែដំណោះស្រាយតាមបែបគ្រប់គ្រងមីក្រូ អាចមិនបានដោះស្រាយដូច្នេះទេ ។

ជំរើសគោលនយោបាយដែលលើកឡើងក្នុងឯកសារនេះ គឺស្ថិតក្នុងស្មារតីនៃ "ការកំណត់គោលនយោបាយមានមូលដ្ឋានទូលំទូលាយ" ទោះបីវាពាក់ព័ន្ធតែនឹងរបកគំហើញដែលកើតចេញពីករណីសិក្សាក្តី ។ ជំរើសគោលនយោបាយទាំងនេះគ្រាន់តែអាចចាត់ទុកជាការបំពេញបន្ថែមនៅលើសំណើគោលនយោបាយនានាដែលមានស្រាប់ ហើយកំពុងអនុវត្តនៅក្នុងប្រទេស ។

## ៤.១. ទំនើបកម្មកសិកម្ម

ទីមួយ: ត្រូវមានការធ្វើទំនើបកម្ម និងចំរុះកម្មយ៉ាងធំក្នុងកសិកម្ម ជាបន្ថែមទៅលើកំណែទំរង់ដីធ្លី ផលិតផល និងកត្តាទីផ្សារ ។ គោលដៅចំបងគឺដើម្បីដកយកចេញនូវការខ្វះខាតដោយចំហ/បង្កប់ផ្សេងៗ ដែលវិស័យកសិកម្មត្រូវប្រឈមនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចធំទូលាយ ។ វិធីសាស្ត្រនេះអាចរួមមានការទាញយកទឹកជាទ្រង់ទ្រាយធំ ដើម្បីអាចដាំដំណាំផ្សេងៗបាន ២-៣ លើកក្នុងមួយឆ្នាំៗ ។ ដូចបានពិសោធន៍ជាក់ស្តែងនៅតៃវ៉ាន់ ហ្វីលីពីន កោះជ្វា... គេនៅតែអាចប្រើបានផលិតភាពល្អនូវពលកម្ម ២០០-២៥០នាក់/ថ្ងៃ លើផ្ទៃដីដាំដុះមួយហិកតា សំរាប់ដំណាំដែលមានការស្រោចស្រព ដោយយកចិត្តទុកដាក់នៅក្នុងតំបន់

[៣៣] មានឯកសារច្រើនណាស់ស្តីពីដំណោះស្រាយនូវបញ្ហាជាយថាក្រម ។ និក្ខេបបទបែបក្លាស៊ិកដែល Paul Rosenstein Rodan សរសេរនៅឆ្នាំ១៩៤៣ និងបានលើកឡើងថា មាន "ការជំរុញដ៏ខ្លាំងក្លាមួយ" ដែលចាំបាច់សំរាប់ឱ្យប្រទេសក្រីក្រ កាត់ផ្តាច់ចេញពីអតីតកាលរបស់ខ្លួនគឺជាចំណុចចាប់ផ្តើមដ៏សំខាន់មួយ ។ Gunna Myrdal (1968) ក្រោយមកទៀតបានវិភាគបន្ថែមលើចំនុចប្រហាក់ប្រហែលតែស៊ីជំរៅជាងដោយបានពិនិត្យពីកត្តាសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ចក្នុងបរិបទតំបន់អាស៊ី ។ គាត់បានស្នើឡើងនូវវិធីសាស្ត្រដែលទាមទារឱ្យមានការកាត់ផ្តាច់ទាំងស្រុងពីស្ថានភាពបច្ចុប្បន្ន ។ ចំពោះការប្រើប្រាស់មានផលិតភាពនូវកំលាំងពលកម្មលើស និក្ខេបបទបែបក្លាស៊ិករបស់លោក Arthur Lewis អាចយកជាការបានសំរាប់ពេលបច្ចុប្បន្ន ក៏ដូចជាកាលពីពេលមុន (Lewis 1954) ។

អាកាសធាតុកសិកម្មបែបនេះ ។ សព្វថ្ងៃកសិកម្មកម្ពុជាប្រើអស់តិចជាងឆ្ងាយណាស់នូវបរិមាណពលកម្មគិតជានាក់ថ្ងៃបែបនេះ ហើយក៏មានផលិតភាពទាបជាងដែរ ។ ការសិក្សាពីប្រវត្តិលំអិតស្តីពីជោគជ័យនៃកសិកម្មនៅអាស៊ី អាចជាចំនុចចាប់ផ្តើមដ៏មានប្រយោជន៍មួយ (Ishikawa 1967; Ishikawa 1981; Hayami and Kikuchi 1984) ។

តើកសិករធុនតូចអាចបានចំណេញឬទេពីកិច្ចប្រឹងប្រែងបែបនេះ? បទពិសោធន៍អន្តរជាតិបង្ហាញថា ក្នុងលក្ខខណ្ឌស្មើគ្នា កសិករធុនតូចមានប្រសិទ្ធិភាពជាងកសិករធុនធំនៅក្នុងបរិបទអាស៊ី ។ ប៉ុន្តែនៅមានសំនួរមួយទៀតគឺ *តើកសិដ្ឋានគួរមានទំហំតូចប៉ុណ្ណា?* ការពុះចែកដីធ្លីឱ្យតូចជាង ១-២ហិកតា អាចឱ្យផលអាក្រក់ ។ ដូច្នេះការត្រួតពិនិត្យលើការពុះចែកដីតូចៗហួសហេតុនឹងត្រូវមានជាចាំបាច់ដើម្បីទាញអត្ថប្រយោជន៍ឱ្យបានពេញលេញពីបច្ចេកវិទ្យា និងទំនើបកម្ម ។

## ៤.២. ដំណើរការទីផ្សារប្រកបដោយប្រសិទ្ធិភាព

ទីពីរៈ ដំនើរការប្រកបដោយប្រសិទ្ធិភាពនៃទីផ្សារផ្សេងៗដែលមានទំនាក់ទំនងជាមួយកសិករ គឺមានសារៈសំខាន់ ។ ទីផ្សារត្រូវមានលក្ខណៈប្រកួតប្រជែងជាបន្ថែមទៀតទៅលើប្រសិទ្ធិភាពនេះ ។

១. ការធានាឱ្យថ្លៃធាតុចេញមានស្ថិរភាព សំរាប់កសិករគ្រប់គ្នា និងនៅគ្រប់តំបន់ គឺមានលក្ខណៈចាំបាច់ គឺទាំងសំរាប់សកម្មភាពកសិកម្ម និងមិនមែនកសិកម្ម ។ រាល់ប្រទេសផលិតផលិតផលកសិកម្មធំបងៗបានអនុវត្តដូច្នេះ ទោះបីជាប្រទេសអភិវឌ្ឍន៍ ឬកំពុងអភិវឌ្ឍន៍ក្តី ហើយចំពោះប្រទេសកម្ពុជា ការបង្កើតយន្តការប្រហាក់ប្រហែលគ្នានេះក៏មិនមែនធ្វើមិនកើតដែរ ។

២. ទីផ្សារធាតុចូល (សំរាប់គ្រឿងយន្ត វត្ថុធាតុជីគីមី) ត្រូវមានលក្ខណៈប្រកួតប្រជែងថែម ហើយមតិនេះមានតំលៃដូចគ្នាសំរាប់សកម្មភាពមិនមែនកសិកម្មដូចជាការនេសាទជាដើម ។ ឧទាហរណ៍ទិដ្ឋភាពផ្សេងៗដូចជា លទ្ធភាពអាចរកបានចំណីត្រី គឺសំខាន់បំផុត ។ ចំពោះដំណោះស្រាយគឺមួយចំណែកវាស្ថិតលើការកែលំអហេដ្ឋារចនាសម្ព័ន្ធ ។

៣. កំណែទំរង់ នឹងពុំបានពេញលេញទេ បើសិនជាគ្មានការរៀបចំឡើងវិញឱ្យបានស៊ីជំរៅនូវទីផ្សារឥណទាន គឺធ្វើយ៉ាងណាឱ្យប្រាក់កម្ចីអាចរកបាននៅពេលមានតំរូវការ ហើយអត្រាការប្រាក់ និងលក្ខខណ្ឌកំចីផ្សេងៗ ក៏ត្រូវមានលក្ខណៈកាន់តែយុត្តិធម៌ថែមទៀត ។

៤. ដើម្បីឱ្យកំណែទំរង់ទីផ្សារទទួលបានជោគជ័យ វាជាការចាំបាច់ដែលទីផ្សារទាំងនេះត្រូវមានលក្ខណៈអព្យាក្រឹត ទោះបីអតិថិជនមានប្រតិបត្តិការទំហំប៉ុណ្ណាក៏ដោយ ។

## ៤.៣. សន្តិសុខនៃកម្មសិទ្ធិ

ទីបីៈ សន្តិសុខនៃកម្មសិទ្ធិត្រូវតែពង្រឹងបន្ថែម ។ម្យ៉ាងទៀត វាជាការចាំបាច់ត្រូវកំណត់ព្រំប្រទល់ដីឯកជន និងដីរួម និងដែនសមត្ថកិច្ចរបស់អ្នកជាប់ពាក់ព័ន្ធផ្សេងៗ ។ វិធីសាស្ត្របែបនេះនឹងជួយឱ្យមានការគ្រប់គ្រងយ៉ាងសក្តិសិទ្ធិ និងការប្រើប្រាស់មានចីរភាពនៃធនធានទ្រព្យរួម ។ ទោះបីជាការប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងទិសដៅនេះ ហាក់ដូចជាមានសព្វជ្រុងជ្រោយហើយក្តី ប៉ុន្តែការជំរុញពន្លឿនដំណើរការនេះអាចជួយបានមួយកំរិតទៀត ។

តើកំណែទំរង់ដីធ្លីដែលរដ្ឋាភិបាលកំពុងអនុវត្ត (ក្នុងនេះសន្តិសុខកម្មសិទ្ធិគឺជាផ្នែកមួយដ៏សំខាន់) វាអាចជួយដោះស្រាយបញ្ហាគ្មានដីធ្លី និងការពុះចែកដីធ្លីតូចៗដែរឬទេ? រឿងនេះអាចធ្វើបាន ។ នៅក្នុងការសិក្សាថ្មីមួយ (Chan *et at* 2001) គេបានរកឃើញថា នៅកម្ពុជាសព្វថ្ងៃមានដីគ្រប់គ្រាន់សំរាប់បំពេញតំរូវការរបស់អ្នកគ្មានដីធ្លី ដោយឈរលើមូលដ្ឋានសំរាប់មួយនាក់ដោះស្រាយឱ្យមួយដង ។

## ៤.៤. ការគ្រប់គ្រងធនធានធម្មជាតិ

ទីបួនៈ ធនធានធម្មជាតិត្រូវគ្រប់គ្រងតាមលក្ខណៈវិទ្យាសាស្ត្រប្រសើរថែមទៀត ដើម្បីធានាឱ្យមានចីរភាព និងមានទិន្នផលខ្ពស់ ។ វិស័យដែលមានសភាពធ្ងន់ធ្ងរជាងគេគឺ ធនធាននេសាទ និងព្រៃឈើ ។ សំណើបង្កើត និងជំរុញសកម្មភាពគ្រប់គ្រងធនធានរួមគ្នា ឬគំរោងគ្រប់គ្រងធនធានដោយសហគមន៍ ត្រូវបានលើកឡើង ប៉ុន្តែមកទល់សព្វថ្ងៃមិនទាន់បានទទួលជោគជ័យទេ ។ នៅពេលបច្ចុប្បន្ន គំរោងទាំងនេះមិនទាន់ល្អគ្រប់គ្រាន់សំរាប់ធ្វើប្រតិបត្តិការទេ ដោយសារកង្វះខាតខាងការចាត់តាំងទុន និងកំរិតជំនាញ ។ គំរោងទាំងនេះត្រូវបំផុសឡើងវិញជាបន្ទាន់ តាមការកែលំអចំណុចខ្វះខាតទាំងនេះ ។

## ៤.៥. ការធ្វើចំរុះកម្មមុខរបរ និងការកសាងធនធានមនុស្ស

ទីប្រាំៈ ការពង្រីកសកម្មភាពមិនមែនកសិកម្ម និងក្រៅកសិដ្ឋាន មានសារៈសំខាន់បំផុតពីព្រោះការធ្វើកសិកម្មតែមួយមុខ មិនអាចផ្តល់ដំណោះស្រាយយូរអង្វែងដល់បញ្ហារកចិញ្ចឹមជីវិត និងសន្តិសុខស្បៀងបានទេ ។ ការងារនេះគួរផ្តួចផ្តើមធ្វើតាមរយៈការបង្កើតមជ្ឈមណ្ឌលសំរាប់ការលូតលាស់បែបវិមជ្ឈការ ដែលក្នុងនេះបណ្តាញទីផ្សារ ត្រូវវិវត្តទន្ទឹមគ្នានឹងការបញ្ចូលជំនាញឯកទេសផ្សេងៗ ។ ទោះបីវិស័យមួយចំនួនដែលមានដំណើរការស្រាប់ហើយដូចជា ការនេសាទ និងការកែច្នៃត្រីជាដើម ត្រូវមានការពង្រឹងបន្ថែមផងដែរក៏ដោយ ក៏ទង្វើនេះមិនទាន់គ្រប់គ្រាន់ទេ បើសិនវាពាក់ព័ន្ធតែត្រឹមការនេសាទ និងការកែច្នៃត្រីប៉ុណ្ណោះគត់ ។ សកម្មភាពទីផ្សាររស់រវើកមួយចំនួនធំទៀត ក៏ត្រូវមានការជំរុញបន្ថែម ។ ក្នុងរឿងនេះ ការកសាងធនធានមនុស្សទ្រង់ទ្រាយធំ (សុខភាព និងការអប់រំ) និងការកសាងហេដ្ឋារចនាសម្ព័ន្ធ គឺជាតំរូវការដ៏បន្ទាន់ ។ មានឧទាហរណ៍ជាក់ស្តែងយ៉ាងល្អៗរបស់ប្រទេសជាច្រើនដូចជា ចិន វៀតណាម និងថៃ (ក្នុងកំរិតណាមួយ) ដែលអាចជួយត្រួសត្រាយផ្លូវសំរាប់ប្រទេសកម្ពុជា (Johansson and Ronnas 1992; Ronnas and Bhargavi 2001; Saith 1991) ។ ការកែលំអហេដ្ឋារចនាសម្ព័ន្ធ ក៏ដើរតួសំខាន់ក្នុងកិច្ចប្រឹងប្រែងបែបនេះដែរ ។

## ៤.៦. ការឱ្យមានតុល្យភាពទីផ្សារពលកម្ម

ទីប្រាំមួយៈ ត្រូវធ្វើស្ថិរភាវូបនីយកម្មទីផ្សារពលកម្ម គឺកាត់បន្ថយគំលាតរវាងការផ្គត់ផ្គង់ និងតំរូវការពលកម្ម ។ ត្រូវបង្កើតច្រើនថែមទៀតនូវការងារមានប្រាក់កំរៃប្រសើរ និងមានចំនួនថ្ងៃធ្វើការច្រើនជាងមុនក្នុងមួយឆ្នាំៗ ដើម្បីបង្កើនប្រាក់ចំណូលប្រចាំឆ្នាំរបស់កសិករធុនតូច ប្រជាជនមិនមែនជាកសិករ និងអ្នកគ្មានដីធ្លី ឬធនធានផ្សេងៗទេ ។ ក្នុងបរិបទនេះ គេត្រូវផ្តល់សំណាញ់សុវត្ថិភាពដ៏ធំមួយ សំរាប់អ្នកមិនបានទទួលអត្ថប្រយោជន៍ក្នុងរយៈពេលខ្លីពីទំនើបកម្មកសិកម្ម ដើម្បីជួយពួកគេក្នុងការទប់ទល់នឹងកង្វះខាតជាបណ្តោះអាសន្ន និង/ឬតាមរដូវ ហើយព្រមគ្នានេះដែរ គឺជួយបញ្ចូលគេទៅក្នុងប្រព័ន្ធផលិតកម្មដែលកំពុងលេចចេញជារូបរាងឡើង ។ វិធីសាស្ត្របែបនេះក៏នឹងអាចជួយបង្កើតកំរិតប្រាក់កំរៃអប្បបរិមាមួយដែលអាចរស់បាន ។ ក្នុងនេះគួរបញ្ជាក់ដែរថា កម្ពុជាត្រូវកំណត់កំរិតកំរៃពលកម្មអប្បបរិមាមួយសំរាប់តំបន់ជនបទ (Acharya 1990; World Bank 1990; Dreze and Sen 1991) ។

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន

ដោយប្រើប្រាស់វិធីសាស្រ្តតាមបែបគុណភាព និងនរវិទ្យា, អត្ថបទនេះស៊ើបអង្កេតពីនិចលភាពគន្លឹះមួយចំនួននៃរចនាសម្ព័ន្ធកសិកម្មនៃប្រទេសកម្ពុជា ដូចបានពិនិត្យឃើញនៅក្នុងការសិក្សាសំរាប់ ៦ភូមិ ដែលបានធ្វើឡើងនៅក្នុងឆ្នាំ២០០១ និងឆ្នាំ២០០២ ។ ចំណុចសំខាន់ៗចំនួន ៥ ត្រូវបានពិនិត្យមើល ១. ការបែងចែកដី និងភាពគ្មានដីធ្លី ២. ការប្រើប្រាស់ដី និងលទ្ធភាពមានអាហារ ៣. សកម្មភាពមិនមែនកសិកម្ម (រួមមានការរកចិញ្ចឹមជីវិតអំពីធនធានធម្មជាតិ) ៤. ទីផ្សារផលិតផលធាតុចូល និងទីផ្សារឥណទាន និង ៥. ទីផ្សារពលកម្មនិងកំរៃពលកម្ម ។ របកគំហើញក្នុងចំនុចនីមួយៗដូចខាងលើមានចុះសង្ខេបនៅភាគខាងចុងនៃផ្នែកនីមួយៗ គឺមិនបានលើកមកបញ្ជាក់ទាំងស្រុងឡើងវិញនៅទីនេះទេ ។

សេចក្តីសន្និដ្ឋានផ្សេងៗអាចសង្ខេបបានដូចតទៅ:

ក. តំបន់ជនបទកម្ពុជា ប្រឈមមុខនឹងអតុល្យភាពធំៗក្នុងន័យថា ប្រជាជន និងកំលាំងពលកម្មបានកើនលើសលទ្ធភាពប្រើប្រាស់ធនធានក្នុងពេលបច្ចុប្បន្ន ។ បញ្ហានេះបានប៉ះពាល់ដល់សន្តិសុខស្បៀង ។

ខ. ធនធានធម្មជាតិស្ថិតក្រោមសំពាធយ៉ាងធ្ងន់ធ្ងរដោយសារ ១. យុទ្ធសាស្រ្តដើម្បីរស់រានជីវិតផ្សេងៗដែលប្រជាជននៅជនបទបានប្រកាន់យក និង ២. តំរូវការធំហួសប្រមាណពីផ្នែកខាងក្រៅវិស័យកសិកម្ម ។

គ. វិសមភាពដីកើតមានឡើងដោយសារ តំរូវការដីដែលផុសចេញពីប្រភពជាច្រើន និងមិនមែនគ្រាន់តែសំរាប់កសិកម្មជីវព្រឹត្តិនោះទេ ។ រឿងនេះបានប៉ះពាល់ដល់ការរកចិញ្ចឹមជីវិតរបស់ពួកអ្នកបាត់បង់ដី ។

ឃ. នៅតាមមូលដ្ឋានមួយចំនួន ដីកសិកម្មត្រូវបានពុះចែកតូចៗពេក មិនអាចធានាជីវភាពបានសមរម្យ ឬការប្រើប្រាស់ធាតុចូលបែបវិទ្យាសាស្រ្តទំនើបទេ ។ កត្តានេះបង្កឱ្យមានទិន្នផលទាប ។

ង. យន្តកម្មកសិកម្មបានជួយបង្កើនផលិតភាពជាទូទៅ ក៏ប៉ុន្តែការបែងចែកផលចំណេញ វាអំណោយផលដល់កសិករធុនធំច្រើនជាងកសិករធុនតូច ។

ច. ទំនើបកម្មកសិកម្មបានផ្តល់អត្ថប្រយោជន៍ ប៉ុន្តែកង្វះប្រព័ន្ធស្រោចស្រព បានកាត់បន្ថយទំហំផលប៉ះពាល់ល្អចំពោះកសិករ ។ លក្ខណៈមិនស្មើភាពរវាងថ្លៃធាតុចូល និងថ្លៃធាតុចេញ ក៏ប៉ះពាល់មិនល្អដល់កសិករដែរ ។

ឆ. ទីផ្សារទាំងអស់គ្មានការប្រកួតប្រជែងល្អទេ ហើយការរកស៊ីផ្តាច់មុខបានធ្វើឱ្យខូចផលប្រយោជន៍កសិករ ។

ជ. ប្រជាជនបានប្រកាន់យកនូវយុទ្ធសាស្រ្តទប់ទល់មួយចំនួនដូចជាធ្វើចំណាកស្រុកចេញជាដើម ប៉ុន្តែគុណភាពអន់នៃធនធានមនុស្ស មិនអនុញ្ញាតឱ្យមានកំណើនប្រាក់ចំណូលគួរកត់សំគាល់ទេ ។

ដោយទាញយកបទពិសោធន៍ពីប្រទេសអាស៊ីឯទៀតៗ អត្ថបទនេះផ្តល់មតិថា គួរកំណត់គោលនយោបាយ ដោយផ្អែកលើដំណើរការផ្លាស់ប្តូរទាំងមូល ជាជាងការផ្លាស់ប្តូរតែក្នុងវិស័យមួយតូច ។ រឿងនេះពាក់ព័ន្ធនឹងទំនើបកម្មកសិកម្ម និងចំរុះកម្មមុខដំណាំ, កិច្ចដំណើការយ៉ាងសក្តិសិទ្ធិនៃទីផ្សារផលិតផលនិងកត្តាខាងទីផ្សារ, សន្តិសុខកម្មសិទ្ធិដី និងការត្រួតពិនិត្យលើការពុះចែកដីតូចៗហួសហេតុ, ការធ្វើចំរុះកម្មមុខរបរនិងធនធានមនុស្ស, និងការធ្វើអន្តរាគមន៍លើទីផ្សារពលកម្មដើម្បីកសាងសំណាញ់សុវត្ថិភាព និងការកំណត់កំរិតប្រាក់កំរៃពលកម្មអប្បបរិមាដែលអាចរស់បាន ។ ការអនុវត្តន៍ព្រមគ្នានូវគោលនយោបាយផ្សេងៗជាច្រើន វាផ្តល់ផលល្អជាងវិធីសាស្ត្រដោះស្រាយមួយមុខម្តងៗ ។

# ឯកសារយោង


Acharya, S. (1990), *The Employment Guarantee Scheme* (New Delhi: ILO-ARTEP)

Biddulph, R. (2000), *Making the Poor Visible* (Phnom Penh: Cambodia Land Project, Oxfam GB)

Bhargavi, R. Sik. B, Ronnås, P. & Sok, H. (2001), *Cambodia 1999–2000: Land Labour and Rural Livelihood in Focus* (Phnom Penh: Cambodia Development Resource Institute) Working Paper No. 21

Brown, F.Z and Timberman D.G. (1998) (eds.), *Cambodia and the International Community* (Singapore: Institute of Southeast Asian Studies, and New York: Asian Society)

Chan, S. Tep, S. & Acharya, S. (2001), *Land Tenure in Cambodia: A Data Update* (Working Paper No. 19, Phnom Penh: Cambodia Development Resource Institute)

Chan, S. & Acharya, S. (2002), *Land and Rural Livelihoods: A Survey of Nine Villages,* (Forthcoming as CDRI Working Paper)

Chan, S. & Acharya, S. (2002), *Land Transaction in Cambodia* (Phnom Penh: Cambodia Development Resource Institute) Working Paper No. 22

Development Analysis Network (ed.) 2001, *Labour Markets in Transitional Economies of Southeast Asia and Thailand* (Phnom Penh: Cambodia Development Resource Institute)

Dreze, J. and Sen, A. (1991), *Hunger and Public Action* (Helsinki: United Nations University-WIDER)

Farmer, B.H. (ed.) (1977), '*Green Revolution? Technology and Change in Rice Growing Areas of Tamil Nadu and Sri Lanka'* (London: Macmillan)

Griffen, K. (1974), *Political Economy of Agrarian Change* (London: Macmillan)

Hayami, Y. & Kikuchi, M. (1984), *Asian Village Economy at Crossroads: An Economic approach to Social Change* (Tokyo: Tokyo University Press)

Ishikawa, S. (1967), *Economic Development an Asian Perspective* (Tokyo: Kinokunia Bookstore Co)

Ishikawa, S. (1981), *Labour Use in Asian Agriculture* (Bangkok: ILO-ARTEP)

Kato, E. (1999), *Where Has All the Land Gone? Land Rights and Access in Cambodia* (Phnom Penh: Cambodia Land Project, Oxfam GB)

Lewis, W.A. (1990), Economic Development with Unlimited Supplies of Labour, *Manchester School,* Volume 22

Johansson, S. & Ronnås, P. (1996), *Rural Industrialisation: A Review of Selected Asian Experience,* (New Delhi: ILO-SAAT) SAAT Working Paper

Meijers, H. (1994), *Land Tenure and Agricultural Development in Cambodia* (Bangkok: Asian Institute of Technology)

McAndrew, J. (1998), *Interdependence of Household Livelihood Strategies in Two Cambodian Villages* (Phnom Penh: Cambodia Development Research Institute) Working Paper No. 7

Murshid, K.A.S. (1998), *Food Security in an Asian Transitional Economy: The Cambodian Experience* (Phnom Penh: Cambodia Development Research Institute) Working Paper No. 6

Myrdal, G. (1998), *Asian Drama: An Inquiry into the Poverty of Nations and The Challenge of World Poverty* (Oxford: Oxford University Press)

Pearse, A. (1980), *Seeds of Plenty, Seeds of Change* (Oxford: Clarendon Press)

Ronnås, P. and Bhargavi, R. (2001), *Entrepreneurship in Vietnam - Transformation and Dynamics* (Copenhagen: Nordic Institute of Asian Studies)

RGC, Royal Government of Cambodia (2001), *A Profile of Poverty in Cambodia - 1999* (Phnom Penh: Ministry of Planning)

RGC, Royal Government of Cambodia (2002a), Socio-economic Development Plan-2, (*draft*) (Phnom Penh: Ministry of Planning)

RGC, Royal Government of Cambodia (2002b), Poverty Reduction Strategy Paper, (*draft*) (Phnom Penh: Ministry of Planning)

Saith, A. (1991), “Asian Rural Industrialisation: Context, Features and Strategies,” in Bremen and Mundle.

Sik, B. (2000), *Land Ownership, Sales and Concentration in Cambodia* (Phnom Penh: Cambodia Development Research Institute) Working Paper No. 16

So, S. Real, S. Uch, U. Sy, R. Ballard, B. & Acharya, S. (2001), *Social Assessment of Land in Cambodia* (Phnom Penh: Cambodia Development Research Institute) Working Paper No. 20

Sida, Swedish International Development Agency (2000), *Cambodia: An Overview of the Land Sector* (Phnom Penh)

Sok, H. Chea, H. and Sik, B. (2001), *Annual Economic Review*, (Phnom Penh: Cambodia Development Research Institute)

Thion, S. (1993), *Watching Cambodia* (Bangkok: White Lotus)

Williams, S. (1999), *Review of Secondary Sources Relating to Land Tenure and Access Issues* (Phnom Penh: Cambodia Land Project, Oxfam GB).

World Bank (1990), *World Development Report* (Washington)

World Bank (2001), *World Development Report* (Washington)

# ឧបសម្ព័ន្ធសង្ខេបការសិក្សាលើភូមិនានា

## ១. ភូមិក្រសាំង ~ អតិរេកស្រូវអង្ករ ភាពគ្មានដីធ្លីកើនខ្ពស់ និងពលកម្មចំណាកស្រុក

### *១.១. ទិដ្ឋភាពភូមិ*

ភូមិក្រសាំងស្ថិតនៅក្នុងឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង ។ ភូមិនេះស្ថិតនៅក្នុងវាលទំនាបលិចទឹកនៃបឹងទន្លេសាបដែលស្ថិតនៅចំងាយ ២៥គីឡូម៉ែត្រពីភូមិនេះ ។ ក្នុងភូមិមានដើមឈើហូបផ្លែ និងច្បារដំណាំជាច្រើន ។ ភូមិនេះមានប្រជាជន ២២៨គ្រួសារ មានសាលាមួយតែគ្មានមណ្ឌលសុខភាព ឬពេទ្យទេ ហើយមណ្ឌលសុខភាពរបស់រដ្ឋនៅឯស្រុក ក៏មិនដំណើរការដែរ ។

នៅឆ្នាំ១៩៩២ ក្នុងពេលអនុវត្តកម្មវិធីធ្វើមាតុភូមិនិវត្តន៍ ភូមិក្រសាំងទទួលបាន ១៤គ្រួសារ ដែលភាគច្រើនគ្មានដីស្រែទេ ប៉ុន្តែគ្រួសារខ្លះបានទិញដីសង់ផ្ទះ ។ ភូមិនេះមានដី ២៣០ហិកតាជាដីស្រែវស្សា (ក្នុងនេះស្រែមួយចំនួនតូច អាចធ្វើស្រូវប្រាំងបាន ព្រោះមេទឹកមកពីស្រុកបវិល) និង ១១៧ហិកតាជាដីស្រែស្រូវឡើងទឹក ។ ចាប់ពីដើមទសវត្សរ៍១៩៩០ នៅក្នុងការងារកសិកម្មមានការផ្លាស់ប្តូរពីការប្រើកំលាំងសត្វអូសទាញទៅប្រើគ្រឿងយន្តវិញ ។ សព្វថ្ងៃភូមិនេះមានត្រាក់ទ័រ ៣គ្រឿង, គោយន្ត ៨គ្រឿង, ព្រមទាំងមានទូកនេសាទ ៥០, ឡានបើកដំបូល ១គ្រឿង, រទេះសេះ ៤, ម៉ាស៊ីនបូមទឹក ៣, អណ្តូងស្នប់ ៥, ត្រពាំង ២០ និងអណ្តូងដាក់លូ ៥ ។

### *១.២. ប្រាក់ចំណូល និងសន្តិសុខស្បៀង*

*កម្មសិទ្ធិដី*

ដោយសារបញ្ហាសន្តិសុខ, នៅភូមិក្រសាំងមិនដែលមានការបែងចែកដីជាផ្លូវការទេ ។ ចាស់ទុំក្នុងភូមិនិយាយថា ពីឆ្នាំ១៩៧៩-១៩៩៤ អ្នកភូមិជួបប្រទះកង្វះខាតដីបង្កបង្កើនផល ពីព្រោះដីទំនាបលិចទឹកជាច្រើនហិកតា ត្រូវពួកខ្មែរក្រហមកាន់កាប់ ដូច្នេះគេធ្វើស្រូវតែលើដីដែលនៅជិតភូមិ ។ អ្នកភូមិបានកាន់កាប់ដីតាំងពីឆ្នាំ១៩៨០ ហើយគ្រួសារនីមួយៗមានដីស្រែប្រហែល ២ហិកតា ។ នៅក្រោយឆ្នាំ១៩៩៣-១៩៩៤ នៅពេលមានសន្តិភាពឡើងវិញ ប្រជាជនបានពង្រីកសកម្មភាពរបស់គេនៅលើផ្ទៃដីលិចទឹក ដែលនៅឆ្ងាយពីភូមិប្រហែល ១៥-២០គ.ម ។ ចាប់ពីពេលនោះមក ដីបានផ្លាស់ប្តូរម្ចាស់ចុះឡើង ជាពិសេសនៅតំបន់វាលទំនាបលិចទឹក ។

ភាពគ្មានដីធ្លីបានកើនឡើងទន្ទឹមគ្នានឹងកំណើនប្រជាជនៈ នៅភូមិក្រសាំងមាន ១២៥គ្រួសារគ្មានដីធ្លី ក្នុងនេះមាន ២៤គ្រួសារដឹកនាំដោយជាស្ត្រីមេម៉ាយ ។ គ្រួសារមួយចំនួនធំត្រូវបង្ខំចិត្តលក់ដីស្រែរបស់ខ្លួន ដើម្បីដោះស្រាយចំណាយផ្សេងៗ ដូចជា បញ្ហាសុខភាព និង/ឬកង្វះខាតស្បៀងតាមរដូវ ។ គ្រួសារខ្លះលក់ដីដើម្បីបានប្រាក់ធ្វើដំណើរទៅថៃ ស្វែងរកការងារដែល

ផ្តល់កំរៃពលកម្មខ្ពស់ជាង ។ ជារឿយៗ ពួកអ្នកមានដែលជាអ្នកចងការប្រាក់ បានទិញយកដីទាំងនោះ ។ ប្រជាជនមកពីភូមិជិតខាងមួយ (ភូមិឫស្សី) បានគ្រប់គ្រងដីស្រែជាង ១០០ហិកតា នៅភូមិក្រសាំង ។ អ្នកភូមិឫស្សី មានកំរិតជីវភាពខ្ពស់ជាងអ្នកភូមិក្រសាំង ដោយសារពួកគេជាអ្នកជំនួញនៅផ្សារថ្មគោល ។ អ្នកខ្លះមានបងប្អូនរស់នៅឯបរទេសដែលផ្ញើប្រាក់មកឱ្យម្តងម្កាល ។

*ដំណាំស្រូវ*

កសិករអះអាងថា ការធ្វើស្រូវឡើងទឹកផ្តល់ផលចំណេញច្រើន ពីព្រោះចំណាយពលកម្មតិច ហើយបានទិន្នផលខ្ពស់ (ជាមធ្យម ៣,០-៣,៥តោនក្នុងមួយហិកតា) ។ ប៉ុន្តែ ក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការធ្វើស្រែលើដីទំនាបមិនបានផលល្អទេ ដោយសារទឹកជំនន់ ។ នៅឆ្នាំ២០០០ និង ២០០១ ផលស្រូវមានកំរិតទាបដោយសារទឹកជំនន់វាធំពេក ។ ស្រូវដាំនៅលើដីទួលជាទូទៅត្រូវការជីច្រើនជាងស្រូវលើដីលិចទឹក ពីព្រោះដីទួលគ្មានជីធម្មជាតិបន្សល់ទុកដោយទឹកជំនន់ ។ម្យ៉ាងទៀត ស្រូវដីទួលត្រូវការពលកម្មច្រើនជាង ព្រោះមានការងារស្ទូង ហើយទិន្នផលជាមធ្យមគឺពី ២,៥-៣,៥តោនក្នុងមួយហិកតា ។ ការច្រូតកាត់ធ្វើនៅខែធ្នូ ដែលអនុញ្ញាតឱ្យកសិករធុនតូចទាំងស្រីទាំងប្រុស អាចធ្វើចំណាកស្រុកទៅថៃ ដើម្បីស្វែងរកការងារបណ្តោះអាសន្នបាន ។ ក្នុងមួយរយៈរហូតដល់ខែធ្នូ គ្រួសារជាច្រើន ជាពិសេសគ្រួសារគ្មានដីធ្លី ឬគ្រួសារមានដីតូចតែងជួបប្រទះនឹងកង្វះខាតស្បៀង ហើយសមាជិកគ្រួសារទាំងនេះធ្វើចំណាកស្រុកចេញដើម្បីចៀសវាងបញ្ហានេះ ។ ក្រៅពីការលក់ពលកម្ម, ស្ត្រីមេម៉ាយ អ្នកគ្មានដី និងគ្រួសារក្រីក្រតែងដើរប្រមូលកួរស្រូវដែលជ្រុះតាមស្រែក្នុងពេលច្រូតកាត់ ហើយគេអាចយកស្រូវនោះមកផ្គត់ផ្គង់គ្រួសារបានយ៉ាងតិចក៏ ២ខែដែរ ។ ទោះបីភូមិក្រសាំងមានអតិរេកស្រូវអង្ករក្តី ប៉ុន្តែប្រជាជនទាំងនេះត្រូវប្រឈមនឹងកង្វះខាតស្រូវរហូតដល់ ៣ខែក្នុងមួយឆ្នាំៗ ។

ការប្រើប្រាស់គ្រឿងយន្តបានចាប់ផ្តើមនៅឆ្នាំ១៩៩៣ ។ គ្រួសារមួយមានត្រាក់ទ័រ ២គ្រឿង, គ្រួសារមួយទៀត មាន ១គ្រឿង, ហើយ ៨គ្រួសារទៀតមានគោយន្តមួយគ្រឿងក្នុងមួយគ្រួសារ ។ អ្នកធូរធារខ្លាំងដែលមានដីស្រែធំៗ ក៏មានគ្រឿងយន្តផងដែរ ។ ភាគច្រើនប្រើប្រាស់គ្រឿងយន្តលើកសិដ្ឋានរបស់ខ្លួនផ្ទាល់ ព្រមទាំងជួលសំភារៈទាំងនេះយកកំរៃផងដែរ ។ ជនទាំងនេះក៏ជាឈ្មួញកណ្តាលធ្វើការជួញដូរស្រូវថែមទៀត ពីព្រោះគេមានមធ្យោបាយដឹកជញ្ជូន និងទុន សំរាប់ទិញស្រូវស្តុកទុកក្នុងរដូវច្រូតកាត់ហើយ គេនឹងបញ្ចេញលក់វាវិញនៅពេលក្រោយដោយបានចំណេញយ៉ាងច្រើន ។ ផ្ទុយទៅវិញ កសិករធុនតូចត្រូវជួលគ្រឿងយន្ត ពីព្រោះគ្មានលទ្ធភាពទិញវាដោយខ្លួនឯង ដូច្នេះហើយក៏មានលំហូរចេញប្រាក់ចំណូល ដោយសារពួកគេត្រូវខ្ចីប្រាក់ជាញឹកញយនៅក្នុងកំរិតអត្រាការប្រាក់យ៉ាងខ្ពស់ ។ បន្ទុកចំណាយនៃការប្រើប្រាស់គ្រឿងយន្តក៏ខ្ពស់ដែរ ពីព្រោះកសិករនៅតាមមូលដ្ឋាន គ្មានចំណេះដឹងគ្រប់គ្រាន់ពីគ្រឿងយន្ត គ្មានការផ្គត់ផ្គង់គ្រឿងបន្លាស់ឱ្យបានទៀងទាត់ ឯប្រេងម៉ាស៊ូតមានថ្លៃខ្ពស់ ។ ប៉ុន្តែបន្ទុកចំណាយទាំងនេះ ត្រូវបានផ្ទេរទៅឱ្យអ្នកជួល ពីព្រោះថ្លៃជួលគឺម្ចាស់គ្រឿងយន្តជាអ្នកកំណត់ ។ ដោយមូលហេតុនេះ ការប្រើគ្រឿងយន្តបង្កើតបន្ទុកចំណាយខ្ពស់ចំពោះកសិករធុនតូច ហើយប្រាក់ចំនេញរបស់គេក៏ធ្លាក់ចុះទាប ។ ដូច្នេះអត្ថប្រយោជន៍នៃបច្ចេកវិទ្យាប្រើគ្រឿងយន្ត ជាទូទៅហាក់មិនបានបែងចែកស្មើគ្នាល្អទេរវាងកសិករធុនតូច និងកសិករធុនធំ ។

បញ្ហាផ្សេងទៀតដែលប៉ះពាល់ដល់កំរិតចំណេញខាងកសិកម្ម មានដូចតទៅ:

១. ថ្លៃស្រូវធ្លាក់ដល់ ៣,៥បាត/គ.ក នៅរដូវច្រូតកាត់, ហើយឡើងដល់ ៤,១បាត/គ.កនៅរដូវវស្សា ។ កសិករស្ទើរតែគ្រប់គ្នាជាពិសេសកសិករធុនតូច តែងលក់ផលិតផលរបស់ខ្លួននៅរដូវច្រូតកាត់ និងទិញស្បៀងចូលនៅរដូវវស្សា ។

២. អត្រាការប្រាក់លើកំចី គឺមានកំរិតខ្ពស់ពី ៥%-១៥% ក្នុងមួយខែ ។ កសិករជាច្រើនត្រូវបាត់បង់ដីនៅក្នុងដំណើរការបង់ការប្រាក់លើប្រាក់កំចីនេះ ។

៣. ចាប់ពីឆ្នាំ២០០០មក មានទឹកជំនន់ធ្ងន់ធ្ងរនៅក្នុងតំបន់ជាច្រើន ដែលបានធ្វើឱ្យខូចខាតផលដំណាំ ។

*ដំណាំចំការ*

១៣គ្រួសារមានចំការក្រូចតូចៗ (ចំការមួយៗប្រហែល ០,៣ហិកតា) ដែលស្ថិតនៅក្រោយផ្ទះរបស់គេ ។ កសិករក៏មានដាំចេក ស្វាយ ខ្នុរ ល្ហុង ត្របែក និងដំណាំឱសថមួយចំនួនទៀត ។ អ្នកភូមិត្អូញត្អែរថា ចាប់ពីឆ្នាំ២០០០ ដើមឈើហូបផ្លែជាច្រើនបានងាប់ដោយសារទឹកជំនន់ ដូច្នេះហើយគេបានប្រាក់ចំណូលតិចតួចណាស់ពីចំការ ។ ២គ្រួសារទៀតដែលមានដើមក្រូចប្រហែល ៥០ដើម ក្នុងមួយគ្រួសារបាននិយាយថា ផ្លែក្រូចមិនលក់ចេញទាំងអស់ទេ ហើយផ្លែក្រូចនៅសល់ទុកសំរាប់ឱ្យកូនចៅនិងក្រុមគ្រួសារហូប ។ ឬស្សីដុះជាលក្ខណៈធម្មជាតិ គ្រួសារភាគច្រើននៅក្នុងភូមិ គេមានឫស្សី ៣-៤គុម្ព ។ ក្រៅពីការប្រើប្រាស់ឬស្សីជាសំភារៈសំណង់ គេក៏យកទំពាំងវាមកហូបដែរ ។ ប្រាក់ចំណូលជាមធ្យមបានមកពីការលក់ផ្លែឈើ មានចំនួនតិចទេ ហើយប្រែប្រួលខុសគ្នាពីគ្រួសារមួយទៅគ្រួសារមួយ ។

*សត្វចិញ្ចឹម*

នៅក្នុងភូមិ មានគោ ១៣ក្បាល និងក្របី ២ក្បាល ដែលគេចិញ្ចឹមទុកសំរាប់យកសាច់ជាសំខាន់ ។ កសិករមួយចំនួននិយាយថា គាត់ឈប់ចិញ្ចឹមគោ-ក្របីហើយ ដោយសារមានអំពើប្លន់ ។ អ្នកខ្លះគិតថា ការចិញ្ចឹមសត្វធំៗ វានឿយហត់ណាស់ជាពិសេសនៅពេលដែលគ្រឿងយន្តបានផ្តល់នូវកំលាំងអូសទាញភាគច្រើន ។ ចំពោះសត្វជ្រូក គេលក់វាទៅឱ្យឈ្មួញនៅទីផ្សារស្រុកថ្មគោល ។ តំលៃសាច់នៅក្នុងភូមិក្រសាំងនាឆ្នាំ២០០១ មានដូចតទៅ: សាច់ជ្រូក ៨.០០០រៀល/គ.ក, សាច់គោ ៩.០០០រៀល/គ.ក, មាន់ ៦.០០០រៀល/គ.ក ។ កសិករអះអាងថា ក្នុងកំរិតថ្លៃទាំងនេះ គេអាចមានចំណេញ ឬអត់ វាអាស្រ័យទៅលើថ្លៃចំណីសត្វ ។

*ការនេសាទ និងការបេះប្រមូលរបស់ហូប*

មាន ១២គ្រួសារគឺជាអ្នកនេសាទលក្ខណៈពាណិជ្ជកម្ម ។ ដោយសារទីតាំងភូមិសាស្ត្រនៃភូមិក្រសាំង ស្ទើរតែគ្រប់គ្រួសារធ្វើនេសាទដើម្បីបំរើការហូបចុកក្នុងគ្រួសារ ។ នៅរដូវនេសាទ អ្នកនេសាទតាមធម្មតាត្រូវចេញទៅនេសាទ ២-៣យប់ក្នុងមួយលើកៗ ដើម្បីចាប់ត្រី កង្កែប ពស់ អន្ទង់ សត្វស្លាប ប្រហែល ១៥-២០គ.ក ។ ថ្លៃត្រីគឺ ៣.៥០០រៀល/គ.ក, ឯកង្កែប និងពស់ ៥.០០០រៀល/គ.ក ។ ជួនកាលគេប្រឡាក់ហាល អន្ទង់ ពស់ និងកង្កែប ជួនកាលគេទុកវាឱ្យនៅរស់ ដើម្បីដឹកទៅថៃ ។ អ្នកនេសាទធុនតូចជាច្រើនបានលើកឡើងថា គាត់ត្រូវជួបកកង្វះខាតជាតិប្រូតេអ៊ីនអស់រយៈពេល ៥ឆ្នាំ ដោយសារផលិតផលត្រីត្រូវនាំចេញទៅថៃជារៀងរាល់ថ្ងៃ ។ ទោះបីជានៅក្នុងរដូវនេសាទក្តី ក៏ពួកគាត់បានរាយការណ៍ពីការលំបាកក្នុងការមានត្រីបរិភោគ ។ មាន ២គ្រួសារ បានទិញផលិតផលនេសាទទាំងអស់សំរាប់នាំចេញទៅលក់នៅថៃ ។ ក្នុងប៉ុន្មានឆ្នាំចុងក្រោយ ធនធានត្រីបានធ្លាក់ចុះ ពីព្រោះមានមនុស្សជាច្រើនបានចាប់ផ្តើមប្រើប្រាស់ឧបករណ៍ដែលបង្កការខូចខាតដល់បរិស្ថាន ។ នៅរដូវវស្សា អ្នកគ្មានដីក៏ដើររកបេះត្រកួនផងដែរ សំរាប់ប្រើជាអាហាររបស់មនុស្ស និងសត្វ ។ ការងារនេះផ្តល់កំរៃពី ៥.០០០-៨.០០០រៀលក្នុងមួយថ្ងៃ សំរាប់អ្នកបេះមួយក្រុមមានគ្នា ៣-៤នាក់ ។

*ការងារក្រៅកសិដ្ឋាន*

អ្នកភូមិជាច្រើននាក់ធ្វើចំណាកស្រុកទៅថៃ ដើម្បីរកការងារធ្វើ ។ អ្នកគ្មានដី ក៏ប្រកបការងារជាពលករយកប្រាក់កំរៃប្រចាំថ្ងៃ អ្នកលក់ដូរ កម្មករដឹកជញ្ជូននៅក្បែរៗភូមិផងដែរ ។ កំរៃពលកម្មក្នុងកំរិត ៥០-៦០បាតក្នុងមួយថ្ងៃថែមបាយមួយពេល (សរុបប្រហែល ៧.០០០រៀល) គេចាត់ទុកថាល្អហើយនៅក្នុងមូលដ្ឋាននោះ ។ ប្រជាជនក៏ទទួលការងារគ្មានជំនាញ និងពាក់កណ្តាលជំនាញធ្វើដែរនៅតាមបណ្តោយព្រំដែនថៃ ឬចូលជ្រៅទៅក្នុងប្រទេសថៃ ។ អ្នកគ្មានដីស្រែ គេធ្វើចំណាកស្រុករយៈពេលវែងជាង ។ ប្រាក់កំរៃជាមធ្យមនៅក្នុងប្រទេសថៃគឺ ៨០-១០០បាតក្នុងមួយថ្ងៃ ប៉ុន្តែ មានច្រើននាក់បានត្អូញត្អែរថា ពេលខ្លះត្រូវគេបោកប្រាស ។ ឧទាហរណ៍ ឈ្មោះ សឿន អាយុ ២៨ឆ្នាំ ដែលទើបត្រលប់ពីថៃកាលពីមួយខែមុន (ចុងឆ្នាំ២០០១) បានទៅធ្វើការក្នុងកសិដ្ឋានបង្គារនៅឯនាយព្រំប្រទល់ ។ គេសន្យាឱ្យកំរៃគាត់ ១០០បាត/ថ្ងៃ ប៉ុន្តែ ៧ខែក្រោយមក ម្ចាស់កសិដ្ឋាន

បើកប្រាក់ឱ្យគាត់តែ ៤ខែប៉ុណ្ណោះ ។ ប្រជាជនជាច្រើននាក់បានខ្ចីប្រាក់ច្រើនៗ ដើម្បីបង់សោហ៊ុយក្រៅផ្លូវការធ្វើដំណើរទៅថៃ ប៉ុន្តែពួកគេមិនបានចំណេញគ្រប់ៗគ្នានោះទេ ។

### *១.៣. ឥណទាន និងប្រាក់កំចី*

*ឥណទានក្រៅផ្លូវការ*

អ្នកភូមិត្រូវបង្ខំចិត្តខ្ចីប្រាក់កាសពីសាច់ញាតិ លក់ទ្រព្យសម្បត្តិផ្សេងៗ ដូចជាដី សត្វចិញ្ចឹម និង/ឬ ខ្ចីបុលពីអ្នកចងការប្រាក់ នៅពេលជួបប្រទះបញ្ហាចោទខាងហិរញ្ញវត្ថុ ឬគ្រោះធម្មជាតិ ។ ចាស់ទុំក្នុងភូមិមួយក្រុមលើកថា បើសិនអ្នកភូមិត្រូវការប្រាក់ច្រើនៗ គេត្រូវទៅខ្ចីពីអ្នកចងការប្រាក់នៅក្នុងភូមិ ឬនៅឯផ្សារផ្ទះគោល ។ បើសិនគេមានទំនាក់ទំនងល្អ ហើយមានជំហរគួរឱ្យទុកចិត្ត ការប្រាក់អាចត្រឹមតែ ៥% ក្នុងមួយខែ ហើយមិនបាច់ដាក់វត្ថុធានាទេ ។ ចំពោះគ្រួសារក្រីក្រ គេត្រូវបង់ការប្រាក់ខ្ពស់ដល់ ១០% ទៅ ១៥% ក្នុងមួយខែ និងត្រូវដាក់វត្ថុធានាថែមទៀត ហើយជាច្រើនគ្រួសារត្រូវបាត់បង់វត្ថុធានាដោយសារការសងប្រាក់យឺតយ៉ាវ រឺក៏គ្មានលទ្ធភាពសងប្រាក់គេ ។ អាត្រាការប្រាក់ខ្ពស់ជាទូទៅបង្កើនទំងន់បំណុលចំពោះកូនបំណុលដែលនឹងរុញច្រានរូបគេឱ្យធ្លាក់ចូលទៅក្នុងវដ្តនៃកង្វះខាតស្បៀង ។ គ្មានឯកសារជាលាយលក្ខណ៍អក្សរអ្វីទេសំរាប់កំចី ឬការដាក់វត្ថុធានាបែបនេះ គឺកិច្ចព្រមព្រៀងទាំងអស់ធ្វើឡើងដោយផ្ទាល់មាត់ ហើយនេះគឺជាដើមហេតុមួយទៀតនៃទំនាស់ ។ មានអ្នករកស៊ីចងការប្រាក់ ៦គ្រួសារនៅក្នុងភូមិ ។ ចំពោះស្បៀង ឬពូជស្រូវបន្តិចបន្តួច គេអាចសុំខ្ចីពីសាច់ញាតិ ឬអ្នកជិតខាង ដោយគ្មានការប្រាក់ ប៉ុន្តែអាចខ្ចីបានតែមួយរយៈពេលខ្លីប៉ុណ្ណោះ ។

*ឥណទានជាផ្លូវការ (ពី NGOs) និងធនាគារស្រូវ*

Help Age បានបង្កើតធនាគារស្រូវមួយ (គំរោងសំរាប់ជួយធ្វើឱ្យថ្លៃ និងការផ្គត់ផ្គង់ស្រូវអង្ករមានស្ថិរភាព) និងគំរោងឥណទានមួយ ប៉ុន្តែលទ្ធភាពគ្របដណ្តប់មិនបានធំទេ ។ ACELEDA បានប្រឹងប្រែងម្តងដែរក្នុងការបង្កើតគំរោងឥណទានមួយនៅក្នុងភូមិ ប៉ុន្តែមិនបានជោគជ័យទេ ពីព្រោះអ្នកភូមិគិតថា អង្គការនេះយកការប្រាក់ខ្ពស់ពេក ។ ប្រធានភូមិរាយការណ៍ថា គាត់មិនហ៊ានធ្វើកិច្ចព្រមព្រៀងជាមួយ ACELEDA ទេ ពីព្រោះប្រជាជនជាច្រើនបានតវ៉ាថា ស្ថាប័ននេះយកកំរៃការប្រាក់ខ្ពស់ពេក ហើយប្រជាជនអាចបាត់បង់ដីធ្លី ដោយសារការសងការប្រាក់ ។ គាត់បានបញ្ជាក់ទៀតថា ទោះបីគ្មានកិច្ចព្រមព្រៀងផ្លូវការក្តី ក៏គ្រួសារមួយចំនួនដែលត្រូវការប្រាក់ជាបន្ទាន់ នៅតែទៅខ្ចីពី ACELEDA ។ គាត់មានជំនឿថា គ្រួសារទាំងនេះនឹងជួបការលំបាកក្នុងពេលអនាគត ។ រឿងនេះបង្ហាញថា ឥណទានផ្លូវការ ឬក្រៅផ្លូវការ គួរសំគាល់ចេញពីគ្នាដោយផ្អែកលើតំលៃថ្លៃ-ថោកនៃឥណទានមិនមែនលើផ្លាកឈ្មោះនោះទេ ។

## ២. បាបោង ‑ ភូមិមានអតិរេកស្រូវអង្ករ

### *២.១. ភូមិសាស្ត្រភូមិ*

បាបោងជាភូមិដែលមានអតិរេកស្រូវអង្ករ ។ ភូមិនេះនៅក្នុងឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង និងស្ថិតនៅចំងាយប្រមាណ ១៤គីឡូម៉ែតពីអ្នកលឿងនៅជាប់ទន្លេមេគង្គ ។ នៅពេលមានទឹកជំនន់ខ្លាំង គេអាចធ្វើដំណើរទៅកាន់ភូមិនេះតែតាមទូកទេ ។ ភូមិបាបោងមានសរុប ៥៣៦គ្រួសារ ក្នុងនេះមាន ១៤២គ្រួសារស្ត្រីដឹកនាំ ។ ចំនួនប្រជាជនបានកើនឡើងពី ៤៣៤ ដល់ ៥៣៦គ្រួសារ ក្នុងចន្លោះពេលពីពាក់កណ្តាលទសវត្សរ៍១៩៨០ ដល់ឆ្នាំ២០០១ ជាចំបងគឺដោយសារអ្នករៀបការថ្មីៗ និងជនធ្វើមាតុភូមិនិវត្តន៍មួយចំនួនតូចកាលពីដើមទសវត្សរ៍១៩៩០ ។

កំណើនប្រជាជនបានបង្កើតតំរូវការដីធ្លីយ៉ាងខ្លាំង: មានព្រៃលិចទឹកជាង ២០ហិកតាត្រូវបានគេកាប់រានយកចាប់តាំងពីចុងទសវត្សរ៍១៩៨០ ហើយសព្វថ្ងៃសឹងតែគ្មាននៅសល់ដីរួម រឺព្រៃលិចទឹកទេ ។ ភូមិបាបោងមានដីប្រមាណ ៧៤២ហិកតា ក្នុងនេះ ២៤ហិកតា ជាដីលំនៅស្ថាន, ២៣ហិចតា ជាផ្ទៃដីលិចទឹក, និង ៦៩៥ហិកតា ជាដីសំរាប់ដាំស្រូវ (ផ្ទៃដីស្រោចស្រពមាន

១៩០ហិកតា) ក្នុងនេះប្រហែល ២២៣ហិកតាជាដីស្រែវស្សា និង ៤៧២ហិកតាជាដីសំរាប់ស្រូវប្រដេញទឹក ។ ដីមានជីជាតិល្អ ដោយសារល្បាប់នៃទន្លេមេគង្គ ។

## ២.២. ប្រាក់ចំណូលនិងសន្តិសុខស្បៀង

ប្រជាជនប្រកបរបរធ្វើស្រែ បេះប្រមូលធនធានធម្មជាតិ នេសាទ ធ្វើពលកម្មយកប្រាក់កំរៃ និងលក់ដូរតូចតាច ។ កសិករជាច្រើនផលិតស្រូវក្នុងគោលដៅលក់ទៅទីផ្សារ ។

*លទ្ធភាពមានដីប្រើប្រាស់*

ជាមធ្យមគ្រួសារកសិករកាន់កាប់ដីពី ១,០-១,៥ហិកតា ។ ថ្វីបើគ្រួសារនីមួយៗទទួលបានដីពី ១,០-២,០ហិកតាក្នុងឆ្នាំ១៩៨៩ក៏ដោយ ក៏មួយរយៈពេលខ្លីក្រោយមក វិសមភាពនៃការកាន់កាប់ដីក៏ផុសចេញមក ដោយសារគ្រួសារខ្លះដែលមានកំលាំងពលកម្មបុរសនិងសត្វអូសទាញ បានរានព្រៃលិចទឹកយកដីធ្វើកសិកម្ម ។ម្យ៉ាងទៀត តាមការចាប់ប្រើប្រាស់គ្រឿងយន្តកសិកម្ម, សេដ្ឋកិច្ចវិមាត្រក៏ចាប់អនុវត្តដែលបណ្តាលឱ្យមានការបែងចែកដីឡើងវិញ ។

សមាគមន៍ប្រជាជនដើមកំណើតវៀតណាមតូចមួយ គ្មានដីធ្លីទេ គឺរស់នៅលើទូក ។ ម្យ៉ាងទៀតមានជនមាតុភូមិនិវត្តន៍មកពីជំរំតាមព្រំដែនថៃតិចនាក់ណាស់ដែលបានទទួលដីធ្លី ។ ការលក់ដីដោយមានចុះបន្ទាន់ និងការបញ្ចាំដី ដើម្បីដោះស្រាយចំណាយបន្ទាន់ៗ ល្បែងស៊ីសង និងអាត្រាការប្រាក់ខ្ពស់ គឺជាមូលហេតុមួយចំនួនទៀតដែលបង្កភាពគ្មានដីធ្លី ។ អ្នកកាន់កាប់ដីតូចៗខ្លះបានលក់ដី ពីព្រោះគេមិនអាចធ្វើស្រែមានប្រសិទ្ធិភាពល្អ ដោយសារតែកង្វះខាតធាតុចូល ។

*ផលិតកម្មកសិកម្ម*

ការធ្វើស្រូវតាមវិធីទំនើប បានចាប់ផ្តើមនៅដើមទសវត្សរ៍១៩៩០ ។ តាមការប្រើប្រាស់ធាតុចូលសមស្របទិន្នផលស្រូវអាចឡើងដល់ ៣-៤តោនក្នុងមួយហិកតា ។ ការធ្វើស្រូវគឺជាប្រភពចំណូលចំបងសំរាប់គ្រួសារប្រហែល ៨០% ។ វាក៏ផ្តល់ប្រាក់ចំណូលប្រចាំរដូវដល់ពលករកសិកម្មផងដែរ (គេប៉ាន់ថាមានប្រហែល ២០%), និងដល់ពលករចំណាកស្រុកប្រមាណ ៤០០នាក់ទៀតមកពីស្រុក និងខេត្តជិតខាង ។ ពលករម្នាក់អាចបានកំរៃពី ២.៥០០-៣០០០រៀលក្នុងមួយថ្ងៃ (ថែមបាយ ២ពេល) សំរាប់ការស្ទូងស្រូវ និងប្រហែល ៤.០០០រៀលក្នុងមួយថ្ងៃសំរាប់ការច្រូតកាត់ ។ ផ្ទុយទៅវិញម្ចាស់ត្រាក់ទ័រម្នាក់អាចរកចំណូលបាន ១០០.០០០រៀលពីការភ្ជួរ រីរាស់ដីមួយហិកតា, ឯម្ចាស់ម៉ាស៊ីនបូមទឹកអាចរកចំណូលបាន ២.៥០០-៣.០០០រៀលក្នុងប្រេងមួយលីត្រនៃការជួលម៉ាស៊ីនរបស់គេ, ហើយម្ចាស់ម៉ាស៊ីនបោកស្រូវអាចទទួលបានស្រូវ ១បាវ សំរាប់ការបោកស្រូវ ៣០បាវ ។ ទោះយ៉ាងនេះក្តី ប្រហែលជិតពាក់កណ្តាលនៃគ្រួសារក្នុងភូមិ ជួបនឹងកង្វះខាតស្រូវអង្ករពី ៣-៦ខែក្នុងមួយឆ្នាំ ដោយសារវិសមភាពនៃកម្មសិទ្ធិ ។

កសិករបានផ្លាស់ពីការធ្វើស្រូវស្ទូង មកធ្វើស្រូវពង្រួសវិញដើម្បីសំចៃលើថ្លៃឈ្នួលពលកម្ម ។ ប៉ុន្តែក្នុងវិធីថ្មីនេះ កសិករបានទិន្នផលខ្ពស់តែពីររដូវប៉ុណ្ណោះ បន្ទាប់មកទិន្នផលក៏ធ្លាក់ចុះ ។ ដូច្នេះកសិករខ្លះបានប្តូរវិធីធ្វើស្រែវិលចុះឡើង ដើម្បីបានទិន្នផលប្រសើរបំផុត ។ តាមសំដីអ្នកដឹកនាំភូមិ ថ្លៃស្រូវខ្ពស់នៅកសិដ្ឋាន (៥០០រៀល/គ.ក) ពីឆ្នាំ១៩៩៧-១៩៩៩ បានជួយយ៉ាងហោចណាស់ក៏ ២០គ្រួសារសំរេចបានការសង់ផ្ទះថ្មី ឬជួសជុលផ្ទះចាស់របស់គេឡើងវិញ ។ ការធ្លាក់ចុះថ្លៃស្រូវមកត្រឹម ២៨០រៀល/គ.ក នៅក្រោយឆ្នាំ១៩៩៩ បានប៉ះពាល់មិនល្អដល់សហគមន៍កសិកម្មៈ មានយ៉ាងតិច ៤៧គ្រួសារបានដាក់បញ្ចាំ រឺបាត់បង់ដីស្រែ ។ ផ្ទុយទៅវិញ ដីធ្លីជាច្រើនបានប្រមូលផ្តុំក្នុងដៃ ១០គ្រួសារ ។ គេរាយការណ៍ថា យ៉ាងតិច ២គ្រួសារមានដីលើសពី ២០ហិកតាក្នុងមួយគ្រួសារ ហើយ ៨គ្រួសារទៀតមានដីពី ១០-១៥ហិកតាក្នុងមួយគ្រួសារ ដោយមិនគិតដីបញ្ចាំចូលទេ ។

*ការប្រើប្រាស់គ្រឿងយន្តកសិកម្ម*

សព្វថ្ងៃភូមិបាបោង ពឹងផ្អែកទាំងស្រុងលើគ្រឿងយន្តកសិកម្មរបស់អ្នកក្នុងភូមិ គឺខុសពីពេលមុន ដែលប្រហែលពាក់កណ្តាលនៃផ្ទៃដីត្រូវភ្ជួរដោយម៉ាស៊ីនជួលមកពីក្រៅភូមិ ។ នៅខែកញ្ញា ឆ្នាំ២០០១ ក្នុងភូមិមានត្រាក់ទ័រ ១០គ្រឿង និងគោយន្ត ១៦គ្រឿង ធៀបនឹងត្រាក់ទ័រតែ ៣គ្រឿង និងគ្មានគោយន្តសោះ កាលពីមុនឆ្នាំ១៩៩៦-១៩៩៧ ។ មានកសិករមិនដល់ ២០% ទេដែលបន្តប្រើកំលាំងសត្វអូសទាញ ដូច្នេះការប្រើកំលាំងពលកម្មបានធ្លាក់ចុះតាមការប្រើគ្រឿងយន្ត ។

*សត្វចិញ្ចឹម*

ក្រៅពីគោក្របី ប្រជាជនមានចិញ្ចឹម មាន់ ជ្រូក និងទា ដើម្បីបង្កើនការផ្គត់ផ្គង់ស្បៀងក្នុងគ្រួសារ ។ជំងឺសត្វ កង្វះខាតចំណីសត្វ និងកំណើនការប្រើប្រាស់គ្រឿងយន្ត គឺជាមូលហេតុដែលគេលើកឡើងថា បានធ្វើឱ្យសេដ្ឋកិច្ចសត្វចិញ្ចឹមមិនរីកចំរើន ។ នៅក្នុងបរិបទនៃសន្តិសុខស្បៀងគ្រួសារ កសិករធុនតូចនិងមធ្យម សព្វថ្ងៃកាន់តែងាយរងគ្រោះ ពីព្រោះនៅពេលជួបវិបត្តិ ពួកគេពុំមានសត្វចិញ្ចឹមសំរាប់លក់ដូចពីមុនទៀត ។

*ការនេសាទ និងការបេះប្រមូលផលព្រៃឈើ*

អ្នកមានទូក ជាពិសេសទូកម៉ាស៊ីន អាចនេសាទបានប្រសើរជាង ។ ជាង ១០គ្រួសារក្នុងភូមិនេះ ត្រូវបានគេសំគាល់ថាជាអ្នកនេសាទពាណិជ្ជកម្ម និងជាអ្នកមានចំណូលយ៉ាងច្រើនពីការនេសាទ ។ ក្នុងចន្លោះពីខែធ្នូ ដល់ កុម្ភៈ គេអាចចាប់ត្រីបានច្រើនដល់ ២០-២៥គ.កក្នុងមួយយប់ (ប្រហែល ៥០.០០០រៀល) ។ រហូតដល់ឆ្នាំ២០០១ ការនេសាទស្ថិតនៅក្រោមប្រព័ន្ធនៃឡូត៍នេសាទសម្បទាន ។ សហគមន៍នៅក្នុងភូមិមានអំណរគុណចំពោះការលុបចោលប្រព័ន្ធសម្បទាន ដោយវាបានកាត់បន្ថយទំនាស់ ។ ប៉ុន្តែមានអ្នកនេសាទមួយក្រុមបានលើកថា គេត្រូវការឧបករណ៍ល្អជាងនេះ ព្រមទាំងបទពិសោធន៍ខាងទីផ្សារផង ដើម្បីទាញយកអត្ថប្រយោជន៍ឱ្យបានពេញលេញពីការបើកចំហឡូត៍នេសាទ ។

*ការប្រមូលអុស*

លទ្ធភាពរកអុសបានថយចុះនៅក្នុងតំបន់ជុំវិញភូមិទាំងមូល ។ ដោយសារគ្មានព្រៃលិចទឹកទៀត អ្នកភូមិបានចាប់ផ្តើមគាស់យកគល់/ឬសដើមឈើលិចទឹក នៅក្នុងតំបន់ជុំវិញនោះ ។ ប៉ុន្តែដោយសារដីព្រៃលិចទឹកមានការគ្រប់គ្រងជាឯកជន ដូច្នេះគេត្រូវសុំអនុញ្ញាតពីម្ចាស់ដីដើម្បីជីកគល់/ឬស ដែលជារឿយ១ត្រូវមានការបែងចែកអុស ឬបង់ប្រាក់ ។

*ការជួលពលកម្ម និងចំណាកស្រុក*

គ្រួសារខ្លះជួលពលកម្មខ្លួនឱ្យគេ សំរាប់ការរៀបចំដី ស្ទូងស្រូវ ច្រូតកាត់ បោកស្រូវ និងជីក-រ៉ែកដី ។ ការអនុវត្តន៍ផ្លាស់ប្តូរពលកម្មគ្នា ត្រូវបានជំនួសដោយការជួលពលកម្មវិញតាំងពីដើមទសវត្សរ៍១៩៩០ មក ។ ដោយតំរូវការជួលពលកម្មភ្ជួរដីបានថយចុះ ដោយហេតុតែការប្រើគ្រឿងយន្តកសិកម្ម, ការងារដែលអាចរកបាន មានចំនួនតិចជាងមុន ។ ស្រូវប្រដេញទឹកបានបង្កើនតំរូវការជួលពលកម្មនៅរដូវច្រូតកាត់ពីខែមករា ដល់ខែមេសា ដែលទាក់ទាញជនចំណាកស្រុកចូលតាមរដូវប្រហែល ៤០០-៥០០នាក់ ។ មនុស្សជាច្រើននៃគ្រួសារក្រីក្របំផុត បានទៅជួលពលកម្មឱ្យគេនៅតាមស្រុកជិតខាងនៅក្នុងរដូវវស្សា ។ នៅឆ្នាំ២០០១ គេបានយល់ព្រមជួលកក់ពលកម្មរបស់ខ្លួនជាមុន ដើម្បីបានកំរៃ ។ចំណាកស្រុកចេញកាន់តែកើនឡើង និងបានរួមចំណែកយ៉ាងសំខាន់មួយដល់សន្តិសុខស្បៀងគ្រួសារ ។ យុវជនយុវនារីឥឡូវនេះធ្វើដំណើរចំងាយឆ្ងាយ១ មិនមែនទៅស្រុកជិតខាងដូចកាលពីមុនឆ្នាំ១៩៩៦ នោះទេ ។ ហើយខុសប្លែកពីលំនាំចំណាកស្រុកក្នុងឆ្នាំ១៩៩៦-១៩៩៧, បុរស និងស្ត្រី ធ្វើចំណាកស្រុកចេញមានចំនួនស្មើគ្នា ។ គេរាយការណ៍ថា មាននារីយ៉ាងតិច ៣៥នាក់ (ក្នុងក្រុមអាយុ ១៦-៣០ឆ្នាំ) បានចាកចេញពីភូមិទៅធ្វើកម្មកររោងចក្រកាត់ដេរ រឺអ្នកបំរើការតាមភោជនីយដ្ឋាន ។ ប៉ុន្តែក្នុងចំណោមអ្នកក្រទាំងនេះ មានតែអ្នកមានប្រាក់កាសខ្លះដែរប៉ុណ្ណោះដែលអាចរកការងារក្នុងរោងចក្រកាត់ដេរបាន (អាចបានចំណូល ៤៥-៦០ដុល្លារក្នុងម្នាក់ក្នុងមួយខែ) ឯអ្នកក្រីក្រ

ខ្លាំងនៅតែធ្វើចំណាកស្រុកទៅតំបន់ជិតខាងដដែល ។ ការរៀបរាប់ទាំងអស់នេះបង្ហាញថា តំរូវការធ្ងន់ធ្ងរនូវការងារយកប្រាក់កំរៃបានកើនឡើង ។

### *២.៣. សេដ្ឋកិច្ចប្រវាស់*

*ការប្រវាស់ពលកម្មក្នុងការធ្វើស្រូវ*

គ្រួសារភាគច្រើនមានដីស្រែមួយចំនួន ប៉ុន្តែកសិករធុនតូចជាច្រើននាក់គ្មានគោ ឬមានតែមួយក្បាល (មានមួយនឹមទើបប្រើបាន) ។ ពេលខ្លះគ្រួសារទាំងនេះដោះស្រាយការភ្ជួរ-រាស់ដីស្រែរបស់ខ្លួន ដោយប្រើប្រាស់យន្តការប្រវាស់ ។ ឧទាហរណ៍ ស្ត្រីមេម៉ាយម្នាក់មានដី ២ហិកតា គាត់ទៅខ្ចីគោពីអ្នកជិតខាង ហើយជាសំណង គាត់ផ្តល់ពលកម្មរបស់គាត់ជួយស្ទូងស្រូវអ្នកជិតខាងវិញ ។ ប៉ុន្តែគេរាយការណ៍ថា ការផ្លាស់ប្តូរបែបនេះបានធ្លាក់ចុះចាប់ពីមានការប្រើប្រាស់គ្រឿងយន្តកសិកម្ម និងសេដ្ឋកិច្ចប្រើប្រាក់កាស ។ កសិករនារីមួយក្រុមបានបញ្ជាក់ថា ទំនាក់ទំនងជួយគ្នាទៅវិញទៅមកក្នុងភូមិ បានធ្លាក់ចុះយ៉ាងខ្លាំង ជាពិសេសការផ្លាស់ប្តូរពលកម្មធ្វើស្រែ ។ សេដ្ឋកិច្ចប្រើប្រាក់កាសផ្តល់ចំណេញដល់អ្នកជួលពលកម្មឱ្យគេ ប៉ុន្តែចំពោះអ្នកក្រជាច្រើននាក់ ការផ្លាស់ប្តូរចេញពីរបបជួយគ្នាទៅវិញទៅមក វាធ្វើឱ្យខូចប្រយោជន៍ ។ នៅក្នុងភូមិ ក៏មានការជួលដីផងដែរ ។

### *២.៤. លទ្ធភាពប្រើប្រាស់ទីផ្សារ*

កសិករពឹងផ្អែកលើការលក់ស្រូវ ត្រី មាន់ ជ្រូក និងដំណាំចំការ ដើម្បីដោះស្រាយការចំណាយក្នុងគ្រួសារ ។ គេទិញធាតុចូលកសិកម្ម ដូចជា គ្រឿងយន្ត ជី ថ្នាំសំលាប់សត្វល្អិត និងប្រេងម៉ាស៊ូត ។ នៅពេលថ្លៃស្រូវវាឡើងចុះ តែថ្លៃធាតុចូលនៅនឹងឬកើនឡើង កសិករត្រូវខាតបង់ ។ រឿងនេះធ្ងន់ធ្ងរជាពិសេសចំពោះអ្នកដែលមិនអាចរង់ចាំឱ្យថ្លៃស្រូវកើនឡើងសិនបាន ។ កសិករភាគច្រើនលក់កសិផលរបស់ខ្លួនទៅទីផ្សារអ្នកលឿង តាមរយៈឈ្មួញកណ្តាលស្រូវអង្ករ ៥នាក់នៅក្នុងភូមិ ។ គ្រួសារធូរធារជាងគេមួយនៅក្នុងភូមិនិយាយថា ពួកគាត់មិនបានកំណត់ថ្លៃស្រូវទេ គឺគ្រាន់តែបានចំណេញជាភាគរយពីឈ្មួញស្រូវធំនៅអ្នកលឿងប៉ុណ្ណោះ ។ ថ្លៃស្រូវអង្ករនៅអ្នកលឿង វាទាក់ទិននឹងការជួញដូរស្រូវអង្ករជាមួយវៀតណាម ។ គេប្រាប់គាត់ថា ថ្លៃស្រូវក្នុងរដូវទើបកន្លងទៅ វាមានការិតទាបដោយសារឈ្មួញវៀតណាម មិនឡើងមកទិញស្រូវ ពីព្រោះមានឧបសគ្គ ត្រូវបង់សំណូកច្រើនពេកឱ្យកន្លែងកុងត្រូលក្រៅផ្លូវការផ្សេងៗ ។

## ៣. ត្រពាំងប្រិយ ~ ភូមិអន់ថយដែលមានលក្ខណៈខ្វះខាតស្រូវ

### *៣.១. លក្ខណៈភូមិសាស្ត្រ*

ត្រពាំងប្រិយគឺជាភូមិក្រីក្រតូចមួយ នៅក្នុងឃុំក្រៀមក្សាន្ត ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។ ភូមិនេះមានប្រជាជនសរុប ៦៨គ្រួសារ (៦១គ្រួសារកាលពីឆ្នាំ១៩៩៧) ។ ភូមិនេះស្ថិតនៅចំងាយ ៣គ.មពីផ្សារបាត់ដឹង និង ៣៥គ.មពីក្រុងភ្នំពេញ ។ ភូមិត្រពាំងប្រិយមានផ្ទៃដីសរុបប្រហែល ៣៧ហិកតា ក្នុងនេះ ៣១ហិកតាជាដីស្រែ និង ៦ហិកតាជាដីលំនៅដ្ឋាន ។ អ្នកភូមិខ្លះប្រកបរបរធ្វើស្ករត្នោត ។ ប្រជាជនក៏មានចិញ្ចឹមសត្វផងដែរដូចជា គោ ជ្រូក មាន់ និងមានលទ្ធភាពប្រើប្រាស់ធនធានទ្រព្យរួមដើម្បីទ្រទ្រង់ជីវិត ។ ពួកគេក៏មានជួលពលកម្មយកប្រាក់កំរៃផងដែរ ។

### *៣.២. សន្តិសុខស្បៀង និងការរកចិញ្ចឹមជីវិត*

*លទ្ធភាពប្រើប្រាស់ដី*

ទំហំដីកាន់កាប់ជាមធ្យមគឺ ០,៥៧ហិកតា តែគ្រួសារធូរធាខ្លះមានដីដល់ទៅ ២-៣ហិកតាក្នុងមួយគ្រួសារ ។ ប្រជាជនបន្តកើនឡើង (កើន ៧គ្រួសារក្នុងរយៈពេល ៥ឆ្នាំ) ប៉ុន្តែផ្ទៃដីគ្មានកំណើន ដូច្នេះគ្មានសល់ដីសំរាប់ធ្វើការដាំដុះបន្ថែមទេ ។ គេរាយការណ៍ថា មានការលក់ដីដោយកសិករធុនតូចទៅឱ្យកសិករធុនធំ ។ ដោយថ្លៃដីនៅមូលដ្ឋានមានការិតទាប (ដីមួយឡូត៍ទំហំ

៥០ម² អាចទិញបានត្រឹមថ្លៃ ៥០០.០០០រៀល ឬ១២៨ដុល្លារ) ដូច្នេះ ប្រតិបត្តិការទិញដូរមានលក្ខណៈងាយស្រួលសំរាប់អ្នកទិញ ។ ចំនួនគ្រួសារគ្មានដី បានកើនពី ៦ ដល់ ១០គ្រួសារក្នុងចន្លោះពេលពីឆ្នាំ១៩៩៧ ដល់២០០១ ។

*កសិកម្មដាំដំណាំ*

ភូមិនេះមានឱនភាពស្រូវ ហើយប្រជាជនជិតដល់ ៦០% ជួបប្រទះកង្វះខាតស្រូវពី ៣ ដល់ ៥ខែក្នុងមួយឆ្នាំៗ ។ ផលិតភាពស្រូវគ្មានការកែលំអអ្វីទេក្នុងរយៈពេល ៥ឆ្នាំចុងក្រោយ ។ ដីគុណភាពទាប ពូជស្រូវប្រពៃណី និងការមិនប្រើប្រាស់ជី, បានធ្វើឱ្យទិន្នផលស្រូវមានកំរិតតែ ៨០០-១.៣០០គ.កក្នុងមួយហិកតា ។ ភ្លៀងមិនទៀងទាត់ និងកង្វះប្រព័ន្ធស្រោចស្រពក៏ធ្វើឱ្យកសិកម្មនៅតែអន់ថយដែរ ។ គេផលិតស្រូវទុកសំរាប់តែការហូបចុកផ្ទាល់ខ្លួន ។ អ្នកឆ្លើយសំភាសន៍បានប្រាប់ថា ជាមធ្យម គ្រួសារនីមួយៗមានដីដាំដុះត្រឹមតែ ០,៥-១,០ហិកតា ដូច្នេះមិនអាចផលិតស្រូវឱ្យបានច្រើនលើសពីតំរូវការទេ ។ មានតែគ្រួសារធូរធារមួយចំនួនតូចដែលមានដាំដំណាំសំរាប់លក់យកប្រាក់ ពីព្រោះការងារនេះត្រូវការដើមទុនដែលមិនសុទ្ធតែអាចរកបានដោយងាយស្រួលនោះទេ ។ ចំនួនអ្នកដាំដំណាំលក់យកប្រាក់កំពុងធ្លាក់ចុះ ពីព្រោះជាការងារនឿយហត់ និងបានចំណេញតិច ។ កង្វះទឹក គ្រោះថ្នាក់ទីផ្សារ និងសត្វដើររហែតរហូត គឺជាបញ្ហាចោទបន្ថែម ។

*សត្វចិញ្ចឹម*

សឹងគ្រប់គ្រួសារមានចិញ្ចឹមគោក្របី សំរាប់ប្រើជាកំលាំងអូសទាញ, និងជ្រូក មាន់ សំរាប់ប្រាក់ចំណូលបន្ថែម ។ នៅឆ្នាំ ១៩៩៧-១៩៩៨ គ្រួសារមួយចំនួនតូចបានចាប់ផ្ដើមចិញ្ចឹមទាយកស៊ុត ។ តាមរយៈធនាគារគោដែលអង្គការទស្សនៈពិភពលោក បានផ្តួចផ្តើមឡើង អ្នកភូមិដើមឡើយបានរំពឹងថា គ្រួសារនីមួយៗនឹងមានសត្វអូសទាញនៅពេលណាមួយនាអនាគត ។ ប៉ុន្តែកម្មវិធីនេះហុចលទ្ធផលតិចជាងការរំពឹងទុក ដោយសារជំងឺសត្វ និងកង្វះខាតសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ។ នៅពេលកសិករខ្ចីប្រាក់យកទៅវិនិយោគក្នុងការចិញ្ចឹមសត្វ ហើយសត្វនោះវាងាប់ គាត់ត្រូវប្រឈមនឹងការជំពាក់បំណុលគេ ។ ម្យ៉ាងទៀតក្នុងមួយរយៈពេលថ្មីៗ កសិករជាច្រើនបានបាត់បង់គោ ជ្រូក និងមាន់ សឹងតែរាល់ឆ្នាំ ។

*លទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ និងអុសដុត*

កាលពីឆ្នាំ១៩៩៧ គ្រួសារក្រីក្រអាចពឹងផ្អែកលើការប្រមូលផលរុក្ខជាតិព្រៃ ។ ដូចគ្នាដែរ ក្នុងចន្លោះពេលពីខែកុម្ភៈ ដល់មេសា កសិករអាចផ្គត់ផ្គង់បានមួយភាគធំនៃស្បៀងផ្សេងៗសំរាប់ការហូបចុកផ្ទាល់ខ្លួនដូចជា ត្រី បន្លែ ក្តាម កង្កែប ខ្យង ព្រមទាំង រុក្ខជាតិឱសថ និងអុសទៀតផង ។ ប៉ុន្តែលទ្ធភាពប្រើប្រាស់ធនធានទ្រព្យរួមបានធ្លាក់ចុះ ហើយឯកជននីយកម្មនៃធនធានទ្រព្យរួមក៏បានបិទសិទ្ធិប្រើប្រាស់របស់ពួកគេដែរ ។ សព្វថ្ងៃ ការនេសាទត្រី កង្កែប ក្តាម ខ្យង (ពីស្រែលិចទឹក) រឺការបរបាញ់សត្វស្លាប សឹងតែធ្វើមិនកើតដោយសារការនេសាទហួសកំរិត ដែលជាផលវិបាកនៃការប្រើវិធីនេសាទបង្កការខូចខាតដល់បរិស្ថានដូចជា ឧបករណ៍អគ្គិសនីជាដើម ។ ទោះបច្ចុប្បន្នមានការហាមឃាត់ ការអនុវត្តន៍បែបនេះក្តី ក៏អ្នកចាស់ទុំបានអះអាងថា ការបញ្ចុះបញ្ចូលឱ្យប្រជាជនឈប់ប្រើឧបករណ៍អគ្គិសនីខុសច្បាប់មិនមែនងាយស្រួលទេ ពិសេសពេលមានប្រជាជនកាន់តែច្រើនបានធ្លាក់ខ្លួនក្រីក្រ ។ គេនិយាយថា ការអត់ឃ្លានរបស់ប្រជាជន មិនអនុញ្ញាតឱ្យពួកគេប្រតិបត្តិតាមច្បាប់បានល្អនោះទេ ។

គ្រួសារប្រហែល ៣០%-៤០% ត្រូវទិញអុសប្រើ ។ អ្នកភូមិសឹងគ្រប់គ្នានិយាយថា កាលពីប្រហែល ៥ឆ្នាំមុន គេអាចរកអុសពីតំបន់ជុំវិញក្នុងរង្វង់ ៨គ.ម ដោយមិនបាច់បង់ប្រាក់ ។ ឥឡូវនេះ ក្នុងរដូវប្រាំង គ្រួសារមួយចំនួនតូចដែលមានរទេះគោគេទៅរកអុសពីទីឆ្ងាយៗដោយត្រូវចំណាយពេលពី ២ ទៅ ៣យប់ក្នុងមួយជើងៗ ។ មានតែគ្រួសារខ្លះៗដែលមានឥទ្ធិពលទេ ទើបអាចទៅរកអុសពីតំបន់ព្រៃហាមឃាត់បាន ។ អុសមួយរទេះគោថ្លៃ ១០.០០០រៀល ។ ខុសពីស្ថានភាពកាលពីពាក់កណ្តាលទសវត្សរ៍១៩៩០, ប្រជាជនក្រីក្រដែលគ្មានរទេះគោ ត្រូវពឹងផ្អែកយ៉ាងខ្លាំងលើការប្រមូលស្លឹកនិងធាងត្នោតនៅជុំវិញភូមិ ឬក៏ត្រូវទិញអុសមកប្រើ ។

*ការធ្វើស្ករត្នោត*

ការសិក្សាពីលើកមុននៅភូមិនេះ បានបង្ហាញថា ក្រៅពីការធ្វើស្រូវ អ្នកភូមិពឹងផ្អែកយ៉ាងខ្លាំងទៅលើចំណូលបានមកពីការធ្វើស្ករត្នោត ។ ក្នុងឆ្នាំ១៩៩៧ មាន ២៧គ្រួសារប្រកបរបរធ្វើស្ករត្នោត (McAndrew 1997) ។ សព្វថ្ងៃ ដោយសារការបាត់បង់អុស មានតែ ៧គ្រួសារទេដែលផលិតស្ករត្នោត ។ ការធ្លាក់ចុះនេះ អាចពន្យល់បានយ៉ាងសាមញ្ញ គឺថ្វីបើអុសវាបានឡើងថ្លៃមួយទ្វេជាពីរក៏ដោយ ក៏ថ្លៃស្ករត្នោតឡើងដល់តែ ៥៥០-៧៥០រៀល/គ.កប៉ុណ្ណោះក្នុង ៥ឆ្នាំចុងក្រោយ ។ អ្នកផលិតស្ករត្នោតមួយក្រុមនិយាយថា នៅក្នុងរដូវធ្វើស្ករត្នោតលើកក្រោយនេះ (ខែវិច្ឆិកា ឆ្នាំ២០០០ ដល់ខែមេសា ឆ្នាំ២០០១) គេបានចំនាយជាមធ្យម ២៥០.០០០រៀលសំរាប់ទិញអុស ។ នៅពាក់កណ្ដាលទសវត្សរ៍១៩៩០ អុសចំនួនប៉ុនគ្នាថ្លៃត្រឹមតែ ១៣០.០០០រៀល ។ គេនិយាយថា ជួនកាលគេទិញដើមត្នោតចាស់ៗយកមកធ្វើអុសដុតក្នុងតំលៃប្រហែល ៥០.០០០រៀលក្នុងមួយដើម ។

*ការជួលពលកម្មឱ្យគេ និងចំណាកស្រុក*

អ្នកភូមិជួលពលកម្មឱ្យគេ ទាំងនៅក្នុង និងនៅក្រៅភូមិ សំរាប់ការងារធ្វើស្រែ ជីកនិងរែកដី សំណង់ និងការងារនៅក្នុងរោងចក្រកាត់ដេរ ។ ការជួលពលកម្មឱ្យគេសំរាប់ការធ្វើស្រែ បានកើនឡើងក្នុងរយៈពេលថ្មីៗ ។ ដោយសារពេលវេលាត្រូវស្ទូងវាសំខាន់ខ្លាំង ដូច្នេះពលកម្មស៊ីឈ្នួលកាន់តែមានប្រជាប្រិយភាព ។ ប៉ុន្តែកំរៃពលកម្មមាន កំរិតទាបស្ទើរតែមិនអាចរស់បាន ។ ក្នុងឆ្នាំ២០០១ ថ្លៃឈ្នួលស្ទូង (សំរាប់សំណាប ៤០កណ្ដាប់) គឺ ១.៥០០-២.០០០រៀលបូកនឹងបាយថ្ងៃត្រង់មួយពេល, ឯកំរៃសំរាប់ការភ្ជួរគឺ ៥.០០០រៀលសំរាប់រយៈពេលកន្លះថ្ងៃ (គិតតាមពេល) ។ កំរៃពលកម្មអាចទូទាត់សងជាប្រាក់ ជារបស់ រឺជាការផ្ដល់ពលកម្មត្រឡប់វិញ ។ អ្នកខ្លះស្វែងរកការងារនៅខេត្តជិតខាង ឯខ្លះទៀតធ្វើដំណើររហូតដល់ខេត្តបាត់ដំបង ឬខេត្តពោធិសាត់ ។ ពួកគេជីក និងរែកដីនៅការដ្ឋានសំណង់ជួសជុលវត្តតាមភូមិ ជីកស្រះនិងលើកទំនប់ និងធ្វើការនៅក្នុងស្រែអ្នកដទៃ ។ កសិករមួយក្រុមនៅក្នុងភូមិនិយាយថា ដោយសារការរិចរិលធនធានធម្មជាតិ ប្រជាជនជាច្រើនបានស្វែងរកការងារនៅក្រៅភូមិ ។ គេរាយការណ៍ដែរថា នៅរដូវប្រាំងកសិករភាគច្រើនធ្វើដំនើរទៅខេត្តឯទៀត ហើយការងារមានកំរៃទាបបានកើនឡើងក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ ។ កម្មករខ្លះ (មានទាំងស្ត្រីផង) បានចាប់យកការងារសំនង់នៅទីរួមខេត្តកំពង់ស្ពឺ និងព្រៃកញ្ចៅ ។ ស្ត្រីមេម៉ាយម្នាក់ដែលធ្លាប់ធ្វើជាកម្មករសំណង់នៅជាយក្រុងភ្នំពេញបានពន្យល់ថា ការងារកម្មករសំនង់ វាយ៉ាប់យ៉ឺនដូចការងារជីកនិងរែកដីដែរ ឯប្រាក់ឈ្នួលជាមធ្យមគឺ ៥.០០០-៦០០០រៀលក្នុងមួយថ្ងៃដោយគ្មានផ្ដល់បាយឱ្យទេ ។ បច្ចុប្បន្នមាននារីក្មេង១៧នាក់ កំពុងធ្វើការក្នុងរោងចក្រកាត់ដេរនៅភ្នំពេញនៅលើមូលដ្ឋានកិច្ចសន្យា ដោយមានប្រាក់ខែជាមធ្យម ៥០-៦០ដុល្លារក្នុងមួយខែ ។ ពេលខ្លះគេមានការងារធ្វើប្រហែលបីខែ ហើយបន្ទាប់មកត្រូវបញ្ឈប់ការងារអស់ ២-៣សប្តាហ៍ ។

### ៣.៣. ឥណទាន

*ឥណទានមិនផ្លូវការ*

ទោះបីមានគំរោងឥណទានផ្លូវការដែលផ្ដួចផ្ដើមឡើងដោយអង្គការ GRET ក្ដី ក៏មានគ្រួសារជាច្រើនបានខ្ចីបុលពីអ្នកចងការប្រាក់ឯកជន ពីព្រោះកំចីផ្លូវការមានកំណត់វដ្ដនៃការខ្ចី-សងជាប់លាប់មិនផ្លាស់ប្តូរ ឯចំនួនអាចខ្ចីបានក៏មានកំរិតដូច្នេះមិនបាន ស្របតាមតំរូវការរបស់ដល់កសិករគ្រប់ៗគ្នាទេ ។ ពេលខ្លះអ្នកភូមិដែលត្រូវការប្រាក់ខ្លាំងត្រូវទៅសុំខ្ចីពីអ្នកចងការប្រាក់នៅ ផ្សារបាត់ដឹង ក្នុងអត្រាការប្រាក់ពី ១០% ទៅ ២០% ក្នុងមួយខែ ។ មានមួយករណីដែលការប្រាក់ត្រូវបង់គឺ *២០០រៀលក្នុងមួយ ថ្ងៃ* សំរាប់ប្រាក់កំចីឯកជនចំនួន ១០.០០០រៀល ។ ប្រជាជនមានខ្ចីស្រូវពីគ្រួសារធូរធារ ឬពីឈ្មួញស្រូវនៅផ្សារបាត់ដឹងផងដែរ ។ នៅរដូវច្រូតកាត់ កំចីស្រូវត្រូវសងវិញរួមទាំងការប្រាក់ជាស្រូវដែរ ។ ពិតហើយ គ្រួសារខ្លះមានសាច់ញាតិជាអ្នកធូរធារ ដែល អាចផ្ដល់កំចីថោកៗឱ្យពួកគេ ប៉ុន្តែគ្មានរបាយការណ៍អ្វីសោះ ស្ដីពីប្រជាជនដែលបានបាត់បង់ដីដោយសារតែការសងកំចីយឺតយ៉ាវ មួយមុខ ។

*ធនាគារស្រូវ*

អង្គការទស្សនៈពិភពលោក បានបង្កើតធនាគារស្រូវនៅឆ្នាំ១៩៩៧ ។ ក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (VDC) ធនាគារស្រូវប្រមូលស្រូវស្តុកទុកបាន ៧.៩៧០គ.ក នៅឆ្នាំ២០០១ ។ ពីដំបូងមានអ្នកចូលរួម ៥២នាក់ តែចំនួននេះថយចុះមកត្រឹម ៤៥នាក់ក្នុងឆ្នាំ២០០១ ដោយសារការប្រមូលផលបានផ្តល់លទ្ធផលល្អ ។ VDC និងប្រធានភូមិរាយការណ៍ថា គេបានឱ្យអ្នកចូលរួមខ្ចីស្រូវនៅខែកញ្ញា សំរាប់ដោះស្រាយកង្វះស្បៀងនៅក្នុងរដូវខ្វះខាត ។ ខុសប្លែកពីកំចីជាប្រាក់ អ្នកក្រីក្រពេញចិត្តនឹងកំចីមានការប្រាក់ទាប (២០% សំរាប់កំចីមានរយៈ ៤-៥ខែ) ពីធនាគារស្រូវ ។ កម្ចីស្រូវ ១០០គ.កនៅខែកញ្ញា ត្រូវសងវិញនៅរដូវច្រូតកាត់ ដោយត្រូវបង់ការ ២០គ.ក ស្រូវថែមទៀត ។

## ៤. ព្រែកក្មេង ជាភូមិនេសាទ និងភូមិកសិកម្ម

### *៤.១. លក្ខណៈភូមិសាស្ត្រ*

ភូមិព្រែកក្មេង ស្ថិតក្នុងស្រុកល្វាឯម ខេត្តកណ្តាល និងមានចំងាយពីភ្នំពេញប្រហែល ៣០គ.ម ។ ភូមិនេះស្ថិតក្នុងតំបន់លិចទឹកចំងាយ ៥គ.មពីទន្លេមេគង្គ និងត្រូវលិចទឹក ៦ខែក្នុងមួយឆ្នាំ ចាប់ពីខែកក្កដា ដល់ខែធ្នូ ។ ភូមិព្រែកក្មេងសឹងតែគ្មានចំណាកស្រុកចេញតែមានចំណាកស្រុកចូលខ្លះ ។ ចាស់ទុំក្នុងភូមិនៅចាំបានថា ភូមិនេះមានប្រហែល ៤០គ្រួសារក្នុងសម័យអាណានិគមបារាំង (មុនឆ្នាំ១៩៥៣) ហើយចំនួនប្រជាជនកើនដល់ ១០០គ្រួសារនៅទសវត្សរ៍១៩៦០, ២១៣គ្រួសារនៅដើមទសវត្សរ៍១៩៨០, ២៧០គ្រួសារនៅដើមទសវត្សរ៍១៩៩០ និង ៣៣៩គ្រួសារនៅដើមឆ្នាំ២០០១ ។

ប្រជាជននៅភូមិព្រែកក្មេងធ្វើការពេញៗមួយឆ្នាំគឺមានដំណាំស្រូវ ការដាំកក់ ការនេសាទ ការកែច្នៃត្រី ការចិញ្ចឹមត្រី និងការរកអុស ។ ប្រភពរកចិញ្ចឹមជីវិតមានច្រើនមុខ ដូច្នេះបានធ្វើឱ្យភូមិព្រែកក្មេង ក្លាយជាភូមិធូរធារមួយ ។

### *៤.២. សន្តិសុខស្បៀង និងការរកចិញ្ចឹមជីវិត*

*ផលិតកម្មស្រូវ*

ដំណាំស្រូវគឺជាប្រភពរកចិញ្ចឹមជីវិតចំបងទីពីរ បន្ទាប់ពីការនេសាទ ថ្វីបើ ១/៣ នៃគ្រួសារក្នុងភូមិគ្មានដីធ្លីក្តី ។ ដំណាំស្រូវធ្វើលើផ្ទៃដី ១៣៧ហិកតាក្នុងផ្ទៃដីកសិកម្មសរុប ២៥២ហិកតា ។ កសិករដាំស្រូវនៅរដូវប្រាំង នៅពេលទឹកស្រកទៅវិញ ។ គេធ្វើការស្រោចស្រពដោយប្រើម៉ាស៊ីនម៉ាស៊ូតបូមយកទឹកពីអូរ និងបឹង ។

ទំហំដីកាន់កាប់ជាមធ្យមគឺ ១ហិកតា ឯទិន្នផលស្រូវគឺ ៣,០-៣,៥តោនក្នុងមួយហិកតា អាស្រ័យទៅលើប្រភេទពូជដែលប្រើប្រាស់ ។ ពីឆ្នាំ១៩៧៩-១៩៩៩ កសិករភាគច្រើនប្រើពូជស្រូវនៅមូលដ្ឋានឈ្មោះមិត្តភាព ដែលត្រូវការរយៈពេលប្រហែល ៤ខែ ទើបអាចច្រូតកាត់បាន ។ ចាប់ពីឆ្នាំ១៩៩៩ មក កសិករភាគច្រើនបានប្តូរទៅប្រើពូជមួយទៀត ឈ្មោះថា សុរិយា ដែលអាចច្រូតកាត់បានក្នុងរយៈពេល៣ខែ និងផ្តល់ទិន្នផលខ្ពស់ជាងពូជមិត្តភាព ដល់ទៅមួយតោនក្នុងមួយហិកតា ។ គេត្រូវជួលពលកម្ម និងគ្រឿងម៉ាស៊ីន ពីព្រោះរយៈពេលលិចទឹកដល់ទៅ ៦ខែ មិនអនុញ្ញាតឱ្យចិញ្ចឹមសត្វអូសទាញបានទេ ។ ចំណាយសរុបសំរាប់ធ្វើស្រែ ១ហិកតា គឺប្រហែល ៥០០.០០០រៀល ។ គិតតាមថ្លៃស្រូវ ៣៥០រៀល/គ.កនៅមូលដ្ឋាន ដូច្នេះផលស្រូវក្នុងស្រែមួយហិកតាអាចផ្តល់ចំនួលសរុប ១,០-១,៤លានរៀល (២៥០-៣៥០ដុល្លារ) ឬប្រាក់ចំនេញសុទ្ធប្រហែល១២០-២២០ដុល្លារ ។

តាមរបាយការណ៍ ផលស្រូវក្នុងភូមិមិនគ្រប់គ្រាន់សំរាប់ការហូបចុកទេ ។ ម្យ៉ាងទៀត ប្រហែល ១០% នៃគ្រួសារធ្វើស្រែគេផលិតស្រូវបានច្រើនលើសតំរូវការអាចយកទៅលក់បាន, ២០% អាចផលិតបានគ្រប់គ្រាន់សំរាប់ការហូបចុកផ្ទាល់ខ្លួន, ឯ ៧០% ទៀតជាអ្នកទិញចូលបង្គ្រប់ហូប សំរាប់ពី ២-៤ខែក្នុងមួយឆ្នាំៗ ។

ផ្ទៃដីធ្វើស្រែបានថយចុះបើធៀបនឹងកាលពី១០ឆ្នាំមុន ។ ដីប្រហែល ៤០ហិកតាត្រូវទុកចោលទំនេរ ពីព្រោះស្ថានីយ៍បូមទឹកឯកជនមួយនៅលើទន្លេមេគង្គ បានឈប់ដំណើរការនៅឆ្នាំ១៩៩៤ ក្រោយពីអ្នកភូមិមួយចំនួនមិនបានបង់ប្រាក់សងថ្លៃទឹក ។ ផ្ទៃដីមួយកន្លែងទៀតទំហំប្រហែល ៦០-១៥០ហិកតា មិនអាចបង្កបង្កើនផលបានទៀតទេ ពីព្រោះវាក្លាយជាចំណែកមួយនៃបឹង បន្ទាប់ពីអ្នកម៉ៅការសង់ផ្លូវម្នាក់បានទប់ជិតប្រឡាយបង្ហូរទឹកចេញមួយកាលពីប្រហែល ៥ឆ្នាំមុន ។ លិខិតតវ៉ាមួយដែលបានផ្ញើជូនអាជ្ញាធរដែនដីស្រុក មិនទាន់ឃើញមានចំណាត់ការអ្វីតបមកវិញទេ ។

*ដំណាំផ្សេងទៀត*

កសិករដាំកក់សំរាប់ធ្វើកន្ទេល ។ កក់គេលក់វាចេញទៅខេត្តដទៃ ឬក៏នាំចេញទៅវៀតណាម ។ ការដាំកក់បានធ្លាក់ចុះក្នុងរយៈ ៥ឆ្នាំចុងក្រោយ ពីព្រោះគេរកឃើញថា ស្រូវផ្តល់ចំណេញបានច្រើនជាង ។ គ្រួសារខ្លះក៏មានដាំល្ងរ ពោត និងបន្លែផងដែរ ។ ភូមិនេះត្រូវនាំចូលស្រូវ បន្លែ និងសាច់ តែមានត្រីនាំចេញទៅវិញ ។

*ការនេសាទ*

គ្រួសារប្រហែល ៩០% ធ្វើការនេសាទ ទាំងសំរាប់ហូប និងសំរាប់លក់ ហើយពួកគេត្រូវប៉ះពាល់ដោយសារបំរាមលើការប្រើប្រាស់តំបន់នេសាទ ។ នៅចុងទសវត្សរ៍១៩៩០ សម្បទានិកឡូត៍នេសាទបានអនុវត្តបំរាមយ៉ាងតឹងលើការនេសាទក្នុងឡូត៍នេសាទដែលនាំឱ្យមានទំនាស់ហឹង្សា រវាងអ្នកភូមិ និងសម្បទានិក ។ ប៉ុន្តែចាប់ពីខែវិច្ឆិកា ឆ្នាំ២០០០ ៥៧% នៃផ្ទៃនេសាទចំនួន ៥.០០០ហិកតាត្រូវបានបើកឱ្យនេសាទ ។

ចំណូលបានពីការនេសាទមានការប្រែប្រួលខ្លាំង អាស្រ័យទៅតាមរដូវ និងឧបករណ៍នេសាទដែលប្រើប្រាស់ ។ ជាមធ្យម អ្នកនេសាទម្នាក់អាចរកចំណូលបានពី ៥.០០០-២០.០០០រៀលក្នុងមួយថ្ងៃ ជាបន្ថែមទៅលើត្រីដែលគេទុកសំរាប់ហូប ។ អ្នកនេសាទជាច្រើនមិនលក់ត្រីទាំងអស់ដែលខ្លួនរកបានទេ ប៉ុន្តែគេទុកមួយចំណែកសំរាប់ធ្វើចំណីត្រីធំដែលគេចិញ្ចឹមក្នុងទ្រុង ។ ក្នុងមួយឆ្នាំពេញ គ្រួសារមួយអាចរកប្រាក់បានពី ១-២លានរៀលដោយសារការលក់ត្រី ហើយត្រូវចំណាយ ៤០០.០០០រៀល ទៅ ៨០០.០០០រៀល ទិញមងដែលនាំចូលមកពីថៃ ។ ក្រៅពីមង អ្នកភូមិប្រើអង្រុត និងសន្ទូច ។

អាជ្ញាធរភូមិនិយាយថា មានអ្នកខ្លះប្រើឧបករណ៍ខុសច្បាប់ ។ អ្នកភូមិរួមទាំងប្រធានឃុំ និងប្រធានភូមិ ដឹងថាអ្នកណាប្រព្រឹត្តអំពើនេះ ប៉ុន្តែគេមិនឃាត់ឃាំងពីព្រោះខ្លាចមានការសងសឹកផ្ទាល់ខ្លួន ។ ចំពោះបញ្ហានេះ សំពាធរួមមានលក្ខណៈចាំបាច់ តែទង្វើនេះនៅមានការខ្វះខាត ។ ដោយផ្ទៃដីនេសាទ ៥៧% ត្រូវបានបើកឱ្យសាធារណជនប្រើប្រាស់សកម្មភាពនេសាទខុសច្បាប់បានកើនឡើង ។ គោលនយោបាយរដ្ឋាភិបាល ដើម្បីកសាងការគ្រប់គ្រងផ្ទៃទឹកដោយសហគមន៍ ត្រូវយឺតយ៉ាវដោយសារកង្វះខាតធនធានមនុស្ស និងថវិកា ។ នៅភូមិព្រែកក្មេង គ្មានអង្គការនេសាទសហគមន៍អ្វីសំរាប់គ្រប់គ្រងធនធានទ្រព្យរួមទេ ។ ស្ថានភាពនេះ បានបង្កើតឱកាសឱ្យប្រជាជនមួយចំនួន ធ្វើការចាប់ត្រីឱ្យបានច្រើនតាមអាចធ្វើកើត ដោយប្រើប្រាស់គ្រប់មធ្យោបាយ ។ ការថយចុះនៃស្តុកត្រី នឹងធ្វើឱ្យជីវភាពប្រជាជនជួបការលំបាកក្នុងអនាគតដ៏ខ្លីខាងមុខ ។

*ការចិញ្ចឹមត្រីក្នុងទ្រុង*

អ្នកភូមិចិញ្ចឹមត្រីឆ្តោរនៅក្នុងអូរដែលហូរកាត់ភូមិ ។ រហូតមកដល់ប៉ុន្មានឆ្នាំមុននេះ គេចាប់កូនត្រីពីផ្ទៃទឹកនៅមូលដ្ឋាន តែឥឡូវនេះគេទិញកូនត្រីពីកំពង់ឆ្នាំង ដោយសារគ្រួសារកាន់តែច្រើនបានរកស៊ីចិញ្ចឹមត្រី ។ ត្រីត្រូវការពេលប្រហែល ១០ខែ ដើម្បីបានធាត់ធំល្មម អាចលក់ទៅឱ្យឈ្មួញបាន ។ ប្រជាជនបានចាប់ផ្តើមចិញ្ចឹមត្រីក្នុងទ្រុងនៅឆ្នាំ១៩៩០។ នៅឆ្នាំ១៩៩៧ គ្រួសារដែលចាប់យករបរនេះមានប្រហែល ២៥%, ហើយនៅឆ្នាំ២០០១ មានដល់ទៅ ៨៥% ។ នៅរៀងរាល់ខែកក្កដា អ្នកចិញ្ចឹមត្រីម្នាក់ត្រូវការថវិកាប្រហែល ៥០០.០០០រៀលសំរាប់ទិញកូនត្រី ។ ប្រហែល ៩០% នៃអ្នកចិញ្ចឹមត្រី ត្រូវខ្ចីលុយគេដើម្បីទិញកូនត្រី ។ ការអនុវត្តន៍ជាទូទៅគឺ អ្នកភូមិខ្ចីមាសគេ ៤ជី (ប្រហែល ៥០០.០០០រៀល) ពីអ្នកចងការប្រាក់នៅភូមិក្បែរ

នោះ ។ បន្ទាប់ពីលក់ត្រីចេញនៅខែមេសា (១០ខែក្រោយមក) គេត្រូវសងវិញ ចំនួន ៦ដី ។ ក្នុងកូនត្រី ៥.០០០ក្បាលដែលគេយកមកចិញ្ចឹមពីដំបូងមានត្រឹម ១.០០០-៣.០០០ក្បាលប៉ុណ្ណោះដែលនៅរស់គ្រប់ ១០ខែ ។ ប៉ុន្តែទោះយ៉ាងនេះក្តី ក៏របរចិញ្ចឹមត្រីនៅតែមានចំណេញ ។

នៅដើមទសវត្សរ៍១៩៩០ ត្រីឆ្តោរថ្លៃ ២.០០០រៀល/គ.ក. នៅចុងទសវត្សរ៍១៩៩០ វាថ្លៃ ២.៥០០រៀល/គ.ក. ហើយនៅឆ្នាំ១៩៩៩-២០០១ វាឡើងដល់ ៣.០០០រៀល ។ ប៉ុន្តែកំណើនថ្លៃត្រី មិនអាចទប់នឹងការធ្លាក់ថ្លៃប្រាក់រៀលបានទេ ហើយនេះជាមូលហេតុមួយនៃការមិនសប្បាយចិត្តនៅមូលដ្ឋាន ។ នៅឆ្នាំ២០០១ គ្រួសារមួយមានត្រីប្រហែល ៣.០០០ក្បាល គេអាចរកប្រាក់ចំណូលបាន ៥លានរៀល ។ បន្ទាប់ពីផាត់ចំណាយ ០,៥លានរៀលលើកូនត្រី, ០,៣លានរៀលលើការប្រាក់, និងប្រហែល ១លានរៀលលើការទិញឧបករណ៍ផ្សេងទៀត, គ្រួសារនេះអាចរកបានប្រាក់ចំណេញសុទ្ធ ៣លានរៀល ។ របរនេះតែងមានចំណេញ ឱ្យតែចំណីត្រីអាចរកបានជាប្រចាំ និងក្នុងតំលៃមួយសមស្រប, ហើយអ្នកចិញ្ចឹមត្រីខិតខំធ្វើការងារខ្លាំង រួមទាំងការប្រើមធ្យោបាយខុសច្បាប់ចាប់ត្រីតូចៗយកទៅធ្វើចំណីត្រីធំផង ។

*ការកែច្នៃត្រី*

គ្រួសារប្រហែល ៨៥% ទិញត្រីតូចៗនៅរដូវត្រីសំបូរ (មករា-កុម្ភៈ) ដើម្បីយកមកឆ្អើរ ។ របរនេះមានចំណេញគួរសម (គ្រួសារមួយអាចរកចំណេញបាន ៣០០.០០០រៀល) តែគ្រួសារទាំងមូលត្រូវធ្វើការយ៉ាងមមាញឹកប្រហែល ២៥ថ្ងៃ ។ ត្រីឆ្អើរគេលក់ចេញទៅខេត្តឯទៀត និងទៅវៀតណាម ។ ចាប់ពីចុងទសវត្សរ៍១៩៩០ ត្រីតូចចាប់បាន គឺបានថយចំនួន (ប្រហែលមកពីកំពស់ទឹកខ្ពស់លើសធម្មតា) ហើយអ្នកកែច្នៃត្រីត្រូវទៅរកទិញត្រីបន្ថែមពីភូមិដទៃ ។

*វិធីសាស្ត្រផ្សេងទៀតនៃការរកចិញ្ចឹមជីវិត*

ក្រៅពីត្រី ប្រជាជន រកខ្យង លៀស គ្រំ បេះព្រលិត ត្រកួន ជីកត្រាវ ទំពាំង និងរកអុស ។ សកម្មភាពទាំងនេះច្រើនធ្វើឡើងដោយគ្រួសារក្រីក្រ និងគ្រួសារស្ត្រីដឹកនាំ ដែលមានប្រហែល ៥០-៦០គ្រួសារ ។ គ្រួសារស្ត្រីដឹកនាំមួយគ្រួ អាចរកបាន ៣.០០០-៥.០០០រៀលក្នុងមួយថ្ងៃ ឯគ្រួសារបុរសដឹកនាំអាចរកបាន ៥.០០០-១០.០០០រៀល សំរាប់សកម្មភាពដូចគ្នា ។ ធនធានបន្លែបានថយចុះតាំងពីចុងទសវត្សរ៍១៩៩០ ដោយសារទឹកជំនន់ ។ តែខ្យង គ្រំ និងលៀស បានកើនឡើង និងបានជួយប៉ះប៉ូវដល់ការបាត់បង់ប្រភពបន្លែ ។

## ៥. ដងក្តារ ភូមិពឹងផ្អែកលើស្រូវ និងព្រៃឈើ

### *៥.១. លក្ខណៈភូមិសាស្ត្រ*

ភូមិដងក្តារស្ថិតក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ, នៅចំងាយប្រហែល ៨០គ.ម ពីផ្លូវធំ (ផ្លូវជាតិលេខ៦) និងព័ទ្ធជុំវិញទៅដោយព្រៃ ដែលភាគច្រើនស្ថិតជាព្រៃសម្បទាន ។ មាន ៣០៦គ្រួសាររស់នៅក្នុងភូមិនេះ ។

*សាវតារ*

នៅក្រោមរបបអាណានិគម ភូមិនេះពឹងផ្អែកយ៉ាងខ្លាំងលើផលិតផលព្រៃឈើ ហើយការដាំដុះគឺជាសកម្មភាពទី២ ។ ទោះបីព្រៃផ្នែកខ្លះជាកម្មសិទ្ធិរបស់រដ្ឋ អ្នកភូមិអាចរកចិញ្ចឹមជីវិតបានដោយធ្វើស្រូវនៅលើដីចំហ និងដីព្រៃ ដោយប្រើវិធីដាំដុះផ្លាស់ទី ប្រមូលជ័រឈើ និងអនុផលព្រៃឈើផ្សេងទៀត និងជួលពលកម្មទៅកាប់ឈើឱ្យសម្បទានិកព្រៃឈើ ។ ទោះមានបំរាមក្តី ប៉ុន្តែលទ្ធភាពប្រើប្រាស់ព្រៃឈើនៅមានគ្រប់គ្រាន់សំរាប់ការទ្រទ្រង់ជីវិតមនុស្សមួយចំនួនតូច (ប្រហែល ៥០-៧០គ្រួសារ) ។

នៅក្នុងដំណាក់កាលទី១នៃរយៈពេលក្រោយបានឯករាជ្យ (១៩៥៤-១៩៧០) ប្រជាជនបានបន្តលំនាំរកចិញ្ចឹមជីវិតដូចមុន ប៉ុន្តែជំនួញ និងការធ្វើដំណើរបានកើនឡើង ។ គ្មានចំណាកស្រុកចេញទេ ប៉ុន្តែមានចំណាកស្រុកចូលមួយចំនួនដើម្បីមកទាញ

យកផលប្រយោជន៍ពីធនធានធម្មជាតិដ៏សំបូរ ។ ភូមិនេះធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម នៅដើមឆ្នាំ១៩៧១ ។ ការដាំដុះត្រូវបានរំខានយ៉ាងខ្លាំង ឬក៏បញ្ឈប់ ហើយថ្លៃទំនិញមកពីក្រៅជាពិសេសអំបិល បានកើនយ៉ាងលឿនដោយសារសង្គ្រាម ។ ការលំបាកបានបន្តពីឆ្នាំ១៩៧៥-១៩៧៩ ហើយប្រជាជន ១០នាក់នៅក្នុងភូមិបានស្លាប់ ដោយសារជីវភាពដ៏យ៉ាប់យ៉ឺន ។ សូម្បីនៅក្រោយឆ្នាំ១៩៧៩ហើយក្តី ក៏អ្នកភូមិនៅបន្តរងគ្រោះដោយសារសង្គ្រាមស៊ីវិលដែលអូសបន្លាយ និងអសន្តិសុខ ពីព្រោះមានកំលាំងខ្មែរក្រហមនៅក្នុងតំបន់ជិតខាងភូមិរហូតដល់ឆ្នាំ១៩៩៨ ។

*និន្នាការខាងប្រជាសាស្ត្រ*

ក្នុងទសវត្សរ៍១៩៦០ ភូមិដងក្តារមានប្រជាជនសរុប៧០គ្រួសារ។ នៅក្រោយសម័យខ្មែរក្រហមក្នុងទសវត្សរ៍១៩៨០ មានប្រហែល ១៥០គ្រួសារបានតាំងលំនៅក្នុងភូមិនេះ (តាមអ្នកភូមិចាំបាន) ហើយនៅឆ្នាំ២០០១ ប្រជាជនកើនដល់ ៣០៦គ្រួសារ ។ ដីស្រែធម្មតាមានតិចទេ តែដីព្រៃខ្លះត្រូវបានកាប់ឆ្ការសំរាប់ធ្វើកសិកម្មផ្លាស់ទី (សព្វថ្ងៃវិធីនេះគេជំរុញឱ្យបោះបង់ចោល) ។ ដូច្នេះ អ្នកភូមិកាន់តែពឹងផ្អែកខ្លាំងឡើងលើការប្រមូលផលព្រៃឈើ នៅក្នុងសម័យកាលមួយដែលមានការកាត់បន្ថយលទ្ធភាពប្រើប្រាស់ព្រៃឈើ ។

នៅឆ្នាំ១៩៨១ ប្រជាជនបានបែងចែកគ្នានូវដីស្រែដែលមានតិចតួច គឺមួយនាក់ទទួលបាន ០,០៧ហិកតា ដោយមិនគិតពីអាយុទេ ដូច្នេះគ្រួសារមួយមានសមាជិក ៥នាក់ ទទួលបានដីតែ ០,៣៥ហិកតាប៉ុណ្ណោះ ។ ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩៣ គ្មានការដាក់កំហិតអ្វីលើការធ្វើអាជីវកម្មលើព្រៃឈើទេ លើកលែងតែរឿងវត្តមានគ្រាប់មីនដែលអ្នកភូមិគេបានរៀនសូត្រ ចេះជៀសវាង ។ រហូតមកដល់ឆ្នាំ១៩៩១ ឈើហុបមានតំរូវការតិចតួច ពីព្រោះជំនួញនេះត្រូវហាមឃាត់ ។ ចាប់ពីឆ្នាំ១៩៩៤ នៅពេលមានសម្បទានិកព្រៃឈើ ២ក្រុមហ៊ុន (Colexim និង GAT) មកកាន់កាប់តំបន់នេះ លទ្ធភាពប្រើប្រាស់ព្រៃឈើរបស់អ្នកភូមិត្រូវបានរារាំង ។ ដោយសព្វថ្ងៃប្រជាជនមានចំនួន ៥ដង ច្រើនជាងកាលពីមុនសម័យសង្គ្រាម ហើយមូលដ្ឋានរកចិញ្ចឹមជីវិតក៏បានរួញតូច ដូច្នេះកំរិតជីវភាពក្នុងភូមិគ្មានកំណើនទេ ។

## *៥.២. សន្តិសុខស្បៀង និងការចិញ្ចឹមជីវិត*

*ការបង្កបង្កើនផល*

នៅភូមិដងក្តារ ការបង្កបង្កើនផលគឺជាប្រភពចំណូលដ៏សំខាន់ ទោះបីមិនមែនជាប្រភពចំបងគេក្តី ។ កសិករធ្វើស្រែផង និងធ្វើចំការផង ។ គេធ្វើស្រូវជាទៀងទាត់នៅលើផ្ទៃដី ១២៧ហិកតា ដែលកាន់កាប់ដោយ ២៨០គ្រួសារ ។ ដីមានគុណភាពអន់ និងផ្តល់ទិន្នផលជាមធ្យមតែប្រហែល ១,៤តោនក្នុងមួយហិកតា ដូច្នេះគឺដោះស្រាយបានតែ ១/៣ នៃតំរូវការស្រូវអង្ករក្នុងភូមិប៉ុណ្ណោះ ។ គេរាយការណ៍ថា មាន ១០គ្រួសារបានទិញដីពីអ្នកដទៃ និងផលិតស្រូវបានលើសតំរូវការសំរាប់លក់ចេញ, ១០គ្រួសារទៀតផលិតស្រូវបានត្រឹមម៉ាគ្រប់ហូបខ្លួនឯង, ហើយសល់ពីនេះត្រូវទិញស្រូវហូប ។ មានគ្រួសារតែ ៣០% ប៉ុណ្ណោះដែលមានលទ្ធភាពទិញដីគីមី ។ ការបង្កបង្កើនផលចំការរួមមាន ការដាំស្វាយចន្ទី និងចេកនៅលើដីរានព្រៃបាន ដែលមិនមែនជាកម្មសិទ្ធិរបស់អ្នកភូមិទេ ។ បច្ចុប្បន្ន ដីនេះស្ថិតក្រោមរបបសម្បទាន ប៉ុន្តែបើតាមសំដីរបស់អ្នកមូលដ្ឋាន វាបានស្ថិតនៅក្រោមការដាំដុះផ្លាស់ទី និង/ឬការធ្វើដំណាំចំការ ប្រហែល៥០ឆ្នាំហើយ ។ គេបានបើកចំហដីច្រើនទៀត ដើម្បីឆ្លើយតបនឹងកំណើនប្រជាជនយ៉ាងលឿន ។ សព្វថ្ងៃមាន ៥០គ្រួសារធ្វើកសិកម្មផ្លាស់ទី ធៀបនឹងតែ ២០គ្រួសារកាលពីពេលមុនសង្គ្រាម ។ សម្បទានិកបានខិតខំទប់ស្កាត់កំណើននេះ ប៉ុន្តែពុំបានជោគជ័យពេញលេញទេ។ ឥឡូវគេបានធ្វើការផ្សះផ្សារជាមួយអ្នកភូមិដោយអនុញ្ញាតឱ្យមានដីធំជាងមុនមួយសំរាប់អ្នកភូមិធ្វើកសិកម្មផ្លាស់ទី និងដោយដាក់លក្ខខណ្ឌថា កសិដ្ឋានត្រូវនៅឆ្ងាយពីផ្លូវ ៥០ម ដើម្បីឱ្យកំបាំងពីភ្នែកសាធារណជន ។ ក្នុងកសិកម្មផ្លាស់ទី ផលិតភាពទាបខ្លាំងណាស់ បើធៀបនឹងស្រែអចិន្ត្រៃយ៍ ហើយ ៥០គ្រួសារដែលធ្វើស្រូវផ្លាស់ទី គឺស្ថិតក្នុងចំណោមគ្រួសារក្រីក្របំផុត ។ ពួកគេមានដីស្រែអចិន្ត្រៃយ៍តែតិចតួច រឺក៏គ្មានសោះ ។ ការស៊ើបអង្កេតល្អិតល្អន់បង្ហាញថា កសិកម្មផ្លាស់ទី ផ្តល់ចំណូលតែប្រហែល ១.០០០រៀលក្នុងម្នាក់ក្នុងមួយថ្ងៃ គឺទាបជាងការងារគ្មានជំនាញ

ឯទៀតដែលជាទូទៅផ្ដល់ប្រាក់កំរៃប្រចាំថ្ងៃចំនួន ២.៥០០រៀល ។ កសិករធ្វើកសិកម្មផ្លាស់ទី ពីព្រោះគេមានគោលដៅធានាឱ្យមានស្រូវមួយចំនួនប៉ុណ្ណោះ ។

*ការកាប់ឈើ*

ការកាប់ឈើគឺជាប្រភពចំណូលចំបងគេនៅក្នុងភូមិ ។ អ្នកភូមិបានផលចំណេញយ៉ាងសន្ធឹកសន្ធាប់ពីសកម្មភាពកាប់ឈើអនាធិបតេយ្យពីឆ្នាំ១៩៩១-១៩៩៤ នៅពេលមានកំណើនតំរូវការភ្លាមៗ បន្ទាប់ពីការបើកចំហសេដ្ឋកិច្ច ។ នៅឆ្នាំ១៩៩២ មានតំឡើងរោងអារឈើ ១៣កន្លែងនៅក្នុងភូមិ សំរាប់កែច្នៃឈើ ។ ម្ចាស់រោងអារឈើជួលកម្មករជាច្រើន ឱ្យកាប់ឈើឱ្យខ្លួន ក្នុងតំលៃ ៣.០០០-៤.០០០រៀល/ម៣ ឈើមូល ។ គ្រួសារមួយចំនួនបានប្រើប្រាក់ចំនូលនេះដើម្បីសង់ផ្ទះ និង/ឬទិញម៉ូតូ និងសំភារៈប្រើប្រាស់ផ្សេងទៀត ។

នៅឆ្នាំ១៩៩៤ ព្រៃឈើមួយភាគធំត្រូវបានជួលទៅឱ្យក្រុមហ៊ុន Colexim ដែលជាក្រុមហ៊ុនដៃគូជាមួយរដ្ឋាភិបាល និងក្រុមហ៊ុនជប៉ុនមួយ ។ នៅឆ្នាំ១៩៩៥ព្រៃឈើមួយភាគទៀតត្រូវបានចុះកិច្ចសន្យាឱ្យទៅក្រុមហ៊ុន GAT International ។ ក្រោយមកមានក្រុមហ៊ុនមួយទៀតឈ្មោះ មៀង លីហេង បានទទួលសិទ្ធិសម្បទាន ។ នៅឆ្នាំ១៩៩៥ ឡានឯកជនដឹកឈើហ៊ុប/ឈើអារត្រូវបានហាមឃាត់ក្នុងតំបន់នោះ ហើយចំនួនរោងអារឈើបានថយចុះមកត្រឹម ២ ។ ប៉ុន្តែរហូតមកដល់ឆ្នាំ១៩៩៨ អ្នកមូលដ្ឋាននៅតែអាចបន្តកាប់ និងដឹកឈើហ៊ុប ដោយប្រើរទេះអូសដោយក្របីធំៗ ពីព្រោះឆ្មាំក្រុមហ៊ុនសម្បទានមិនអាចយាមល្បាតព្រៃទាំងមូលបាន ។ នៅពេលខ្មែរក្រហមបញ្ឈប់ការតស៊ូប្រឆាំងនៅក្នុងឆ្នាំ១៩៩៨ ក្រុមហ៊ុនសម្បទានបានពង្រឹងសន្តិសុខរបស់ខ្លួន ។ ចាប់ពីពេលនោះមក អ្នកភូមិបានជួបការលំបាកកាន់តែច្រើនក្នុងការ "លួច" ឈើ (តាមពាក្យរបស់អ្នកភូមិ) ។

មានគ្រួសារមួយចំនួននៅតែបន្តធ្វើការកាប់ឈើដោយខុសច្បាប់ ។ គេចំណាយពេលប្រហែលមួយសប្ដាហ៍ ដើម្បីធ្វើការងារ "ដុំ"មួយ ដែលរួមមានការស្វែងរកឈើមួយដើម រំលំឈើនោះ ត្រួសត្រាយផ្លូវទៅកាន់ឈើហ៊ុប និងដឹកជញ្ជូនឈើនោះ ។ ក្នុងការងារមួយគេបានចំណេញ ២០.០០០-៣០.០០០រៀល ។ គេធ្វើប្រតិបត្តិការរបៀបនេះ ២ដងក្នុងមួយខែ ។ គេអាចជួបគ្រោះថ្នាក់ដោយត្រូវក្រុមល្បាតរបស់ក្រុមហ៊ុនចាប់បាន ហើយក្នុងករណីនេះគេត្រូវបង់ពិន័យយ៉ាងខ្ពស់ ។ មិនមែនគ្រប់គ្រួសារសុទ្ធតែអាចកាប់ឈើដោយខុសច្បាប់បែបនេះបានទេ ។ គ្រួសារទាំងនេះត្រូវមានយ៉ាងហោចណាស់ក្របីធំៗមួយនឹម និងរទេះមួយ ដែលអាចដឹកឈើមួយហ៊ុបបាន (ប្រវែងពី ៣-៧ម ) ។ ក្របីមួយនឹមថ្លៃ ប្រហែល ៥០០ដុល្លារ ហើយរទេះមួយ ២៥០ដុល្លារ ។ មួយភាគបីនៃគ្រួសារក្នុងភូមិប៉ុណ្ណោះដែលមានទ្រព្យបែបនេះ ។

*ផលិតផលព្រៃឈើផ្សេងទៀត*

មានប្រហែល ២៥គ្រួសារនៅបន្តប្រកាសថា ខ្លួនគេមានដើមឈើយកជ័រ ។ អ្នកភូមិនិយាយថា ពួកគេកាន់កាប់ឈើទាំងនេះច្រើនជំណាមកហើយ ។ មុនពេលក្រុមហ៊ុនសម្បទានមកដល់នៅក្នុងឆ្នាំ១៩៩៥ គ្រួសារនីមួយៗមានឈើយកជ័រពី ៣០០-៧០០ដើម ដែលអាចនៅឆ្ងាយពីភូមិដល់ទៅ ២០-៣០គ.ម ។ សព្វថ្ងៃមានគ្រួសារតិចតួចមានឈើយកជ័រ ហើយគ្រួសារនីមួយៗមានមិនលើសពី ៥០ដើមទេ ។ ពីដំបូងក្រុមហ៊ុនសម្បទានចង់កាប់យកឈើទាំងនេះ ពីព្រោះវាស្ថិតក្នុងតំបន់សម្បទាន តែពួកអ្នកភូមិចង់រក្សាវាទុក ។ ក្នុងបទប្បញ្ញត្តិរបស់រដ្ឋាភិបាលមានមាត្រាមួយអាចបកស្រាយន័យថា ដើមឈើយកជ័រត្រូវរក្សាទុក ។ ចំពោះប្រជាជន គេយល់ព្រមទទួលយកប្រាក់ពី ៤.០០០-១០.០០០រៀលពីក្រុមហ៊ុនសម្បទាន សំរាប់យកឈើជ័រមួយដើម ដោយសារគេបារម្ភថាឈើទាំងនេះនឹងត្រូវកាប់ចៀសមិនរួច ។ ក្នុងពេលបច្ចុប្បន្ននេះ ឈើមួយដើមអាចផ្ដល់ជ័របានប្រហែល ២០.០០០រៀលក្នុងមួយឆ្នាំ ។ ដោយសារប្រជាជនមានឈើយកជ័រតិចដើមជាងមុន ដូច្នេះគេពឹងផ្អែកកាន់តែខ្លាំងលើការប្រមូលអនុផលព្រៃឈើឯទៀត និង/ ឬការកាប់ឈើខុសច្បាប់ ។

ការប្រមូលផ្ដៅ ឃើញមានជាទូទៅកាលពីពេលមុនៗ ។ ផ្ដៅអាចរកបានពេញៗមួយឆ្នាំ ។ មនុស្សទាំងប្រុសទាំងស្រីធ្វើ

ដំណើររួមគ្នាមាន ៤-៥គ្រួសារក្នុងមួយក្រុម។ ចូលជ្រៅទៅក្នុងព្រៃអស់រយៈ៥-១០ថ្ងៃ ទើបត្រឡប់មកផ្ទះវិញ ។ ក្នុងមួយជើង។ គ្រួសារមួយអាចប្រមូលផ្តៅដែលផ្តល់ចំណូលបានពី ២០.០០០-៥០.០០០រៀល ។ អ្នកភូមិជឿជាក់ថា ធនធាននេះនៅសំបូរ តែថ្លៃវាទាបពេក និងមានមនុស្សច្រើនពេកដែលកាត់យកចំណេញពីខ្សែបណ្តាញនៃជំនួញនេះ ។

គ្រួសារមួយចំនួន បានប្រកបរបរបរបាញ់សត្វ ប្រមូលមើមឈើ និងផ្លែឈើផ្សេងៗពីព្រៃ ។ គេប៉ាន់ថា មានមនុស្ស ប្រហែល ៤០នាក់ ប្រកបរបរដាក់អន្ទាក់ចាប់ឈ្លូសលក់ ។ ក្រុមបុរស។ ក្នុងមួយក្រុមមានគ្នា ៣-៥នាក់ និងឆ្កែ ១-២ក្បាល គេធ្វើដំណើរជ្រៅទៅក្នុងព្រៃ ដើម្បីចាប់សត្វ អណ្តើក និងសត្វផ្សេងទៀត ។ តាមសំដីអ្នកឆ្លើយសំភាសន៍ ចំនួនសត្វព្រៃបានធ្លាក់ចុះយ៉ាងខ្លាំង ឯចំនួនអ្នកស្វែងរកសត្វព្រៃបានកើនឡើង ។ សព្វថ្ងៃអ្នកបរបាញ់កាន់តែពិបាកគេចផុតពីការដាក់អនុវត្តន៍ច្បាប់ ។ ផលិតផលព្រៃឈើមួយចំនួនគេដាក់លក់នៅផ្សារក្បែរនោះ (២៥គ.មពីភូមិ) ។ ការថយចុះលទ្ធភាពអាចរកបានផលិតផលទាំងនេះក៏មានគេរាយការណ៍ដែរ ។ ប៉ុន្តែអ្នកដាក់អន្ទាក់នៅតែអាចរកបានដល់ទៅ ១៥.០០០រៀលក្នុងមួយថ្ងៃ ។

## ៦. កំពង់ត្នោត ៖ ភូមិពឹងផ្អែកលើកសិកម្ម និងការនេសាទតាមឆ្នេរសមុទ្រ

### *៦.១. លក្ខណៈភូមិសាស្ត្រ*

ភូមិកំពង់ត្នោត ដែលនៅឆ្ងាយពីទីរួមខេត្តកំពតប្រហែល ១០គ.ម ស្ថិតនៅក្នុងឃុំកូនសត្វ ស្រុកកំពត ខេត្តកំពត ។ តំបន់ឆ្នេរដែលមានស្រែអំបិលស្ថិតនៅចំងាយ ២គ.មពីភូមិ ។ ភូមិនេះមានប្រជាជន ៤០២គ្រួសារ ក្នុងនេះមាន ៥គ្រួសារជាអ្នកតាំងទីលំនៅថ្មី, ៣គ្រួសារទើបធ្វើមាតុភូមិនិវត្តន៍ថ្មី។, និង៩៣គ្រួសារដឹកនាំដោយស្ត្រីមេម៉ាយ ។ ប្រជាជនបានកើន ៣៥% ក្នុងទសវត្សរ៍ចុងក្រោយនេះ ។ ក្នុងរបបខ្មែរក្រហម គេបានជំលៀសប្រជាជនចេញ ដោយអ្នកភូមិមួយចំនួនត្រូវបានបញ្ជូនទៅខេត្តតាកែវ និងកោះកុង, ហើយអ្នកនៅរស់រានជីវិត បានត្រឡប់មកកំពង់ត្នោតវិញនៅក្រោយឆ្នាំ១៩៧៩ ។ ដីស្រែបានធ្វើការបែងចែកក្នុងទសវត្សរ៍១៩៨០ ប៉ុន្តែគ្រួសារនីមួយ។ទទួលបានដីជាមធ្យម ០,៥-០,៦ហិកតាប៉ុណ្ណោះ ។

អ្នកភូមិទ្រទ្រង់ជីវិតដោយការធ្វើស្រែវស្សាពឹងលើទឹកភ្លៀង ចំការ ការនេសាទតាមឆ្នេរសមុទ្រ ការធ្វើអំបិល ជំនួញតូចតាច និងពលកម្មយកប្រាក់កំរៃ ។ ដូចនៅកន្លែងឯទៀតដែរ ភាពគ្មានដីធ្លី ឥណទានមានតំលៃខ្ពស់ កង្វះខាតការងារ កង្វះខាតការថែទាំសុខភាព ភាពមេម៉ាយ បានរួមចំណែកបង្កអសន្តិសុខស្បៀង ។ ចំណុចសំខាន់មួយទៀត គឺការបែងចែកស្រទាប់សង្គមដែលផុសចេញពីគំលាតយ៉ាងធំនៃកិរិតធនធាននៅក្នុងភូមិ : មនុស្សមួយចំនួនតូចជាអ្នកមាន ឯអ្នកឯទៀតមិនបានដូច្នេះទេ ។ ធនធានកសិកម្មផ្សេងទៀតនៅក្នុងភូមិមានជាអាទិ៍ រោងម៉ាស៊ីនកិនស្រូវចំនួន៥, រោងបិទស្រា ៣កន្លែង, ទូកនេសាទ/ ចែវ ៩៧, ទូកម៉ាស៊ីន ៥៣, រ៉ឺម៉កម៉ូតូ ១៨គ្រឿង, ម៉ូតូ ៧៨គ្រឿង, រ៉ឺម៉កធាក់ ៥, និង តាក់ស៊ី ២គ្រឿង ។

### *៦.២. សន្តិសុខស្បៀង និងការរកចិញ្ចឹមជីវិត*

*ការធ្វើស្រែ*

ដីស្រែទាំងអស់មាន ១៥០ហិកតា ។ ភូមិកំពង់ត្នោតមិនស្ថិតក្នុងតំបន់មានគ្រោះធម្មជាតិទេ ហើយក៏មិនប្រឈមនឹងទឹកជំនន់ ឬការរាំងស្ងួតដែរ ។ ទិន្នផលស្រូវជាមធ្យមបានត្រឹម ៨០០-១.២០០គ.កក្នុងមួយហិកតា ពីព្រោះគេមិនប្រើធាតុចូលតិច, ស្រែមានទំហំតូច។, ហើយដីមួយចំនួនមានជាតិប្រៃ ។ ទោះបីមានកត្តាបែបនេះក្តី ក៏ភូមិកំពង់ត្នោត មានអតិរេកផលស្រូវមួយចំនួនតូចសំរាប់លក់ (សំរាប់ ៤-៥គ្រួសារ) ប៉ុន្តែមានគ្រួសារងាយរងគ្រោះជាច្រើនត្រូវជួបនឹងកង្វះស្រូវ ។ ថ្លៃស្រូវ (ប្រហែល ៥០០រៀល/គ.ក) មិនឡើងចុះខ្លាំងទេ បើធៀបនឹងតំបន់ឯទៀតក្នុងប្រទេស ។ ប្រជាជនទិញស្រូវពីខេត្តតាកែវមកបំពេញបន្ថែមលើផលិតផលរបស់ខ្លួន ។

*ចំការ*

គ្រួសារភាគច្រើនដាំបន្លែ និងដើមឈើហូបផ្លែ ហើយប្រមូលផលបានទាំងក្នុងរដូវប្រាំង និងរដូវវស្សា ។ ដូងខ្ចីលក់បាន ២០០រៀលក្នុងមួយផ្លែ, ដូច្នេះបើសិនគ្រួសារមួយមានដូង ២០-២៥ដើម គេអាចបានចំណូលយ៉ាងហោចណាស់ពី ៨០.០០០-១០០.០០០ក្នុងមួយឆ្នាំ ។ ដូងខ្ចីមួយផ្លែថ្លៃ ២០០រៀលនៅឯកសិដ្ឋាន ប៉ុន្តែនៅភ្នំពេញវាថ្លៃ ៨០០រៀល ។ តាមធម្មតា ឈ្មួញកណ្តាលតែងរកទិញផលិតផលដល់ៗភូមិ ។ មានដើមត្នោតជាច្រើននៅក្នុងភូមិ ប៉ុន្តែគ្មានអ្នកណាធ្វើស្ករត្នោតទេ ។ អ្នកភូមិច្រើននាក់រាយការណ៍ថា ដើមត្នោតផ្តល់ទឹកត្នោតតិច ដោយសារដីមានជាតិប្រៃច្រើន ។ កសិករមានដាំសណ្តែកដី ល្ហុង ឪឡឹក ពោត និងសណ្តែកសៀងផងដែរ ។ សកម្មភាពនេះជួយការពារពួកគេបានមួយចំណែកទប់ទល់នឹងកង្វះស្បៀងតាមរដូវ និងជួយផ្តល់ប្រាក់ចំណូលបន្ថែមមួយចំនួន ។ អ្នកភូមិខ្លះនិយាយថា កាលពីពេលមុនគេដាំដូងជាដំណាំ ហូបផ្លែសំរាប់តំរូវការក្នុងគ្រួសារ ប៉ុន្តែសព្វថ្ងៃ អ្នកភូមិបានដាំទាំងដំណាំជាច្រើនមុខផ្សេងទៀត ពីព្រោះចំនួនត្រីបានថយចុះយ៉ាងខ្លាំង ហើយប្រជាជនមិនអាចបន្តពឹងផ្អែកទាំងស្រុងលើការនេសាទទៀតទេ ។ ដើម្បីដាំដំណាំលក់យកប្រាក់ក្នុងផ្ទៃដីកន្លះហិចតា គេត្រូវការមានដើមទុនយ៉ាងហោចណាស់មួយសែនរៀលសំរាប់ទិញជី ពូជ ថ្នាំសំលាប់សត្វល្អិត និងការស្រោចស្រព ។ មានតែអ្នកមានប្រាក់កាសប៉ុណ្ណោះដែលអាចដាំដំណាំសំរាប់លក់យកប្រាក់ ។ គ្រួសារខ្លះទៅខ្ចីបុលពីអ្នកចងការប្រាក់ក្នុងអត្រាការប្រាក់ ១៥% ក្នុងមួយខែ ។ ក្នុងការវិយោគទុនមួយសែនរៀលដាំសណ្តែកដី កសិករអាចរកចំណូលបានប្រហែលពីរសែនរៀល ។ កសិករ ១៨គ្រួសារបានដាំដំណាំលក់យកប្រាក់ ឯគ្រួសារឯទៀតចូលចិត្តធ្វើនេសាទ ពីព្រោះវាផ្តល់ប្រាក់ចំណូល*ប្រចាំថ្ងៃ*និងហាក់ដូចជាមានហានិភ័យក៏រិតទាបជាង ។

*សត្វចិញ្ចឹម*

អ្នកភូមិមួយចំនួន ជាពិសេសអ្នកគ្មានដី គេចិញ្ចឹមសត្វផ្សេងៗដែលជាទូទៅ គឺមានគោ (សំរាប់ភ្ជួររាស់ព្រោះគ្មានត្រាក់ទ័រ) ជ្រូក ទា និងមាន់ ។ ទីក្រុងកំពត ផ្តល់ទីផ្សារសំរាប់សត្វចិញ្ចឹមទាំងនេះ ។ ពេលកូនជ្រូកមាំទាំគួរសម (អាយុប្រហែល ៦សប្តាហ៍) កសិករយកវាទៅផ្សារ ហើយលក់ឱ្យឈ្មួញក្នុងតំលៃ ២០.០០០-២៥.០០០រៀលក្នុងជ្រូកមួយ ។ ភូមិកំពង់ត្នោតមានអ្នកចិញ្ចឹមមេជ្រូកយកកូនលក់ ៩គ្រួសារ ។ ការចិញ្ចឹមជ្រូកមានបន្ទុកចំណាយមួយចំនួន ជាពិសេសជ្រូកល្អៗអាចលក់បានត្រូវផ្តល់ចំណីកន្ទក់លាយដើមចេកឱ្យវា ។ ការងារនេះមានហានិភ័យខ្លះដែរ ដូចជាជ្រូកអាចមានជំងឺ ឬស្លាប់ ។ ស្ទើរគ្រប់គ្រួសារមានចិញ្ចឹមមាន់ និងទា ។

*ការប្រមូលអុស*

ថ្វីបើធនធានធម្មជាតិបានធ្លាក់ចុះ ដោយសារកំណើនប្រជាជន និងការធ្វើអាជីវកម្មគ្មានចីរភាពក្តី ក៏គ្រួសារខ្លះនៅមានលទ្ធភាពប្រមូលអុសបានសំរាប់ការចំអិនអាហារក្នុងគ្រួសារ ។ ដើមកោងកាងងាប់នៅតាមឆ្នេរសមុទ្រ និងព្រៃឈើនៅជុំវិញភូមិគឺជាប្រភពដ៏សំខាន់ ។ ឈ្មួញអុសមកពីភូមិផ្សេង ក៏បានដឹកអុសតាមរទេះគោមកលក់នៅភូមិកំពង់ត្នោតដែរ ។

*ការនេសាទ*

សឹងគ្រប់គ្រួសារបានចូលរួមធ្វើការនេសាទតាមឆ្នេរសមុទ្រ ហើយសកម្មភាពនេះគឺជាប្រភពរកចិញ្ចឹមជីវិតសំខាន់ទី២ សំរាប់អ្នកភូមិ ។ តាមសំដីប្រធានភូមិជាងពាក់កណ្តាលនៃគ្រួសារក្នុងភូមិ ប្រកបរបរនេសាទពាណិជ្ជកម្មពេញៗមួយឆ្នាំ ។ អ្នកនេសាទសឹងគ្រប់គ្នាមានទូកចែវមួយ ឬទូកម៉ាស៊ីនតូចមួយ ។ ដោយសារគ្រោះថ្នាក់ខ្យល់ព្យុះ អ្នកមានទូកចែវនេសាទនៅក្បែរឆ្នេរ ដែលទឹកមានជំរៅពី ០,៨-១,០ម ។ គេប្រើបច្ចេកទេសនេសាទច្រើនបែបដូចជា ១. ជប់: សំណាញ់ចងភ្ជាប់ទៅនឹងស៊ុមឬស្សីមូល ដែលតាមធម្មតាគេប្រើសំរាប់ដងកូនត្រី និងបង្គា ២. លប: អន្ទាក់ទ្រុងធ្វើពីឬស្សី ឬដែកដែលគេច្រើនប្រើសំរាប់ចាប់ក្តាម ឬមឹក និង ៣. **អំពូលភ្លើងអាគុយ** ប្រើសំរាប់ចាប់បង្គាធំៗ ។ អ្នកនេសាទទាំងអស់សុទ្ធជាបុរស តាមធម្មតាគឺឪពុកមួយកូនមួយ បង្កើតបានក្រុមនេសាទមួយ ។ ពេលខ្លះ ពួកកុមារគេទៅនេសាទនៅពេលថ្ងៃ ដើម្បីចាប់ក្តាមតូចៗ និងងាវ ។ ពួកស្ត្រីៗនៅចាំផ្ទះ ដើម្បីធ្វើត្រី និងបកយកសាច់ក្តាមសំរាប់លក់ទៅទីផ្សារ ។ អ្នកភូមិទុកត្រីនិងក្តាមតូចៗសំរាប់ហូបក្នុងគ្រួសារ

ហើយយកត្រី និងក្តាមធំៗលក់ទៅទីផ្សារ ។ ឧបករណ៍នេសាទទាំងអស់អាចរកទិញបាននៅឯផ្សារក្រុងកំពត ។ ចំណាយប្រចាំឆ្នាំលើឧបករណ៍ នេសាទមានទំហំពី ៥០.០០០-៧០.០០០រៀល ។

បង្គារធំៗអាចលក់បាន ១០.០០០រៀលក្នុងមួយគ.ក. មឹក ៣.០០០រៀលក្នុងមួយគ.ក. ក្តាម ៧.០០០រៀល/គ.ក. ត្រីធម្មតា ៣.០០០រៀល/គ.ក និង ងាវ ៣.០០០រៀល/គ.ក ។ រាល់ផលិតផលទឹកប្រៃទាំងអស់ ត្រូវបញ្ជូនទៅផ្សារកំពត ហើយចុងបញ្ចប់ត្រូវលក់ចេញនៅឯក្រុងភ្នំពេញ ។ តាមធម្មតាក្នុងមួយយប់អ្នកនេសាទចាប់ត្រីតូចៗ ក្តាម និងបង្គារបាន ១-២គ.ក ។ ប្រាក់ចំណូលសុទ្ធជាមធ្យមគឺ ៣.៥០០-៥.០០០រៀលក្នុងមួយយប់ ។ អ្នកភូមិត្អូញត្អែរថា ផលិតកម្មបានធ្លាក់ចុះខ្លាំងណាស់ក្នុងរយៈ ៤-៥ឆ្នាំចុងក្រោយ ។ ម្យ៉ាងទៀតដោយមានមនុស្សមកពីកន្លែងផ្សេងជាច្រើននាក់ បានមកនេសាទនៅតំបន់នេះ, ព្រៃកោងកាងលិចទឹកក៏បានធ្លាក់ចុះគុណភាព ។

*ការផលិតអំបិល*

ស្រែអំបិលមានទាំងអស់ ១៥៥ហិកតា បែងចែកចេញជា ៨ម្ចាស់ដែលជាអ្នកមានៗជាងគេបំផុតនៅក្នុងភូមិ ។ ក្នុងឆ្នាំ ១៩៨៩ នៅពេលសេដ្ឋកិច្ចទីផ្សារត្រូវបានបើកឱ្យដំណើរការឡើងវិញ ស្រែអំបិលក៏ត្រូវបានធ្វើឯកជននីយកម្ម ។ អ្នកខ្លះ រួមទាំងអតីតមន្ត្រីរដ្ឋាភិបាលដែលមានជំនាញក្នុងការងារនេះ (គឺគេទទួលបាននៅពេលស្រែអំបិលជាកម្មសិទ្ធិរដ្ឋ ហើយពួកគេជាកម្មាភិបាលទទួលបន្ទុកស្រែអំបិលនេះ) ហើយជាអ្នកមានធនធានផង បានទិញយកកសិដ្ឋានស្រែអំបិល ។ ផ្ទុយទៅវិញ អតីតពលករជាច្រើននាក់ត្រូវបានកាត់បន្ថយ ហើយដោយសារគ្មានកម្មករណាម្នាក់មានប្រាក់សោធននិវត្តន៍ ឬក៏ត្រូវបានគេផ្តល់ដីកសិកម្មឱ្យដូច្នេះមួយចំនួនតូចបានក្លាយជាជនក្រីក្រ និងងាយរងគ្រោះ ។

ស្រែអំបិលនីមួយៗមានទំហំប្រមាណ ៥០ម$^{២}$ ព័ទ្ធជុំវិញទៅដោយភ្លឺដី ។ គេបូមទឹកប្រៃបញ្ចូលទៅក្នុងស្រែ ហើយគេប្រមូលយកអំបិល ក្រោយដែលទឹកបានហួតរីងដោយសារពន្លឺថ្ងៃ និងកំដៅ ។ ក្នុងរដូវប្រមូលផល កសិដ្ឋានស្រែអំបិលនីមួយៗជួលកម្មករយ៉ាងតិចក៏ ១៥នាក់ដែរដែលភាគច្រើនជាស្ត្រី ដើម្បីប្រមូល និងដឹកជញ្ជូនអំបិលទៅដាក់ក្នុងឃ្លាំងនៅក្បែរនោះ ។ តាមសំដីម្ចាស់ស្រែអំបិល ស្រែអំបិល១៥ហិកតា ផ្តល់អំបិលជាមធ្យមប្រមាណ ៧០០តោនក្នុងមួយឆ្នាំ ប៉ុន្តែក្នុងរយៈបីឆ្នាំចុងក្រោយ ថ្លៃអំបិលបានធ្លាក់ចុះ ដោយសាររដ្ឋាភិបាលបានអនុញ្ញាតការនាំចូលអំបិលពីប្រទេសចិន និងវៀតណាម ។ រឿងនេះបានប៉ះពាល់មិនល្អដល់ប្រាក់ចំណេញរបស់ផលិតករអំបិលកម្ពុជា ។

*ប្រាក់កំរៃពលកម្ម និងចំណាកស្រុក*

កំណើនចំនួនគ្រួសារគ្មានដីធ្លី គឺជាមូលហេតុមួយចំណែកនៃការបាក់បែកប្រព័ន្ធផ្លាស់ប្តូរពលកម្ម ។ គ្រួសារស្ត្រីដឹកនាំជាច្រើនទទួលប្រាក់កំរៃប្រចាំថ្ងៃ ដោយជីកប្រលាយបង្ហូរទឹកចេញពីស្រែអំបិល ស្ទូងស្រូវ ច្រូតស្រូវ និងជីក-ជញ្ជូនដី ។ កម្មករធ្វើការក្នុងស្រែអំបិលទទួលបានកំរៃពលកម្ម ៣.៥០០រៀលក្នុងមួយថ្ងៃសំរាប់ពេលធម្មតា និង ៧.០០០រៀលក្នុងមួយថ្ងៃសំរាប់រដូវប្រមូលផលដែលមានរយៈពេលតែមួយខែទេក្នុងមួយឆ្នាំ ។ ចំណាកស្រុកមិនសូវមានច្រើនទេ ក្រៅតែពីអ្នកខ្លះដែលមានសកម្មភាពអាជីវកម្មតូចតាចនៅក្រុងកំពត ។ មាន ៥គ្រួសារបានផ្លាស់ទីលំនៅទៅខេត្តកោះកុង ទៅធ្វើជាកម្មករចិញ្ចឹមត្រីនៅក្នុងកសិដ្ឋានចិញ្ចឹមត្រីពាណិជ្ជកម្ម ។ តាមសំដីរបស់ប្រធានភូមិ អ្នកទាំងនេះគេមានសាច់ញាតិនៅខេត្តកោះកុង ។

*ស្រូវ និងប្រាក់កំចី*

កសិករងាយរងគ្រោះខ្ពីលុយគេ នៅពេលមានតំរូវការចាំបាច់បំផុត ។ អ្នកចងការប្រាក់ឯកជនឆ្លៀតឱកាសនេះ ផ្តល់ប្រាក់កំចីតាមរដូវដោយមានការប្រាក់ដល់ទៅ ២០% ក្នុងមួយខែ ។ ប៉ុន្តែការប្រាក់វាប្រែប្រួលទៅតាមការទុកចិត្តគ្នាទៅវិញទៅមករវាងអ្នកឱ្យខ្ចី និងអ្នកសុំខ្ចី ។ តាមធម្មតា អ្នកផ្តល់ឥណទានទាមទារឱ្យមានដាក់ទ្រព្យប្រចាំគ្រួសារ ឬដីស្រែជាវត្ថុធានា ។ អ្នកក្រគ្មានដីធ្លី ឬគ្រួសារសឹងគ្មានដីសោះ តែងខ្ចីស្រូវពីគេ ។ ក្រុមអ្នកផ្តល់ស្រូវកំចីធុនតូចមួយចំនួនដែលមកពីក្រុងកំពត ហើយមាន

សាច់ញាតិនៅក្នុងភូមិ បានផ្តល់ស្រូវកំចីឱ្យអ្នកភូមិ ជាពិសេសនៅខែខ្វះខាត ។ ស្រូវកំចីមួយបាវ (ទំងន់ ៥០គ.ក ថ្លៃ ២០.០០០-២៥.០០០រៀល) ត្រូវសងគេវិញ ៣៥.០០០រៀលក្រោយរយៈពេល ២-៣ខែ ។ ACELEDA ជាគំរោងឥណទានស្ថាប័នតែមួយគត់នៅភូមិកំពង់ត្នោត ។ មកទល់ពេលនេះ មាន ៦០គ្រួសារបានខ្ចីប្រាក់ពី ACELEDA ក្នុងអត្រាការប្រាក់ ៤% ក្នុងមួយខែដោយមានវត្ថុធានា ។ អ្នកភូមិជាច្រើនត្អូញត្អែរថា ដើម្បីសុំខ្ចីពីស្ថាប័នឥណទាន គេត្រូវឆ្លងកាត់ដំណាក់កាលមួយចំនួន បំពេញក្រដាសស្នាមច្រើន និងត្រូវក្លាយទៅជាសមាជិកនៃក្រុមឥណទានមួយ ។ គ្រួសារធូរធារមួយចំនួនតូច បានខ្ចីប្រាក់ពី ACELEDA ហើយយកប្រាក់ឱ្យអ្នកក្រីក្រខ្ចីបន្តទៀត ។

# បញ្ជីឯកសារពិភាក្សារបស់ វបសអ

១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា: ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សាលេខ ១) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល: ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និង ពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ច្បាប់ដែលបានបោះពុម្ព ហើយផ្សព្វផ្សាយអស់ ។

៣. Kannan, K. P. (មករា ១៩៩៧) *ការកែទំរង់សេដ្ឋកិច្ច ការកែតម្រូវរចនាសម្ព័ន្ធ និងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ច្បាប់ដែលបានបោះពុម្ពផ្សាយ ហើយផ្សព្វផ្សាយអស់ ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៊ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឺលវី (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរតំលៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និងឡុង-វ៉ូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តំលៃ ៩.០០០រៀល ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨), *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរតំលៃ ៧.៥០០រៀល ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato ឡុង-វ៉ូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា: បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តំលៃ ៦.០០០រៀល ។

៩. តេង-យូតី ប៊ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនឌ្រូ (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១០. Gorman, Siobhan, ជាមួយ ប៊ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា: ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និងជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍: ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរតំលៃ ៤.៥០០រៀល ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរតំលៃ ៣.០០០រៀល ។

១៤. Toshiyasu-Kato Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា: លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តំលៃ ៣.០០០រៀល ។

១៥. Toshiyasu Kato, ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ: បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ។

១៦. ស៊ិក ប៊ូរ័ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា: ការពិនិត្យវិភាគដោយត្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរតំលៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តំលៃ ៧.០០០រៀល ។

១៨. Martin Godfrey សូ-សុវណ្ណារិទ្ធ ទេព-សាវ៉ាវី ប៊ុន-ដូរីណា Claude-Katz Sarthi-Acharya ស៊ីសុវត្ថិ-ឌួង-ចាន់តូ និង ហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា: ការកាត់បន្ថយភាព ក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ ១៨) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សាវ៉ាវី និង *Sarthi Acharya* (ខែធ្នូ ឆ្នាំ២០០១) *ការកាន់កាប់ដីនៅកម្ពុជា: ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២០. សូ សុវណ្ណារិទ្ធ រៀល សុភាព អ៊ុច ឧទេយ្យ ស៊ី វត្ថមុនី Brett Ballard និង Sarthi Acharya (ខែមីនា ឆ្នាំ២០០២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-ប៊ូរ័ក្ស Per Ronnås និង សុក-ហាច (ខែមីនា ឆ្នាំ២០០២) *ប្រទេសកម្ពុជា ឆ្នាំ១៩៩៩-២០០០: ការផ្តោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារ ពិភាក្សាលេខ ២១) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២២. ច័ន្ទ សុផល និង Sarthi Acharya (ខែកក្កដា ឆ្នាំ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា: ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តំលៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ តុលា (ខែកញ្ញា ឆ្នាំ២០០២) *ធនធានធម្មជាតិ និងជីវភាពនៅតាម ជនបទក្នុងប្រទេសកម្ពុជា: ការវាយតំលៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តំលៃ ១០.០០០រៀល ជាអង់គ្លេស ១០ដុល្លារ ។

# ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន

ឯកសារនេះគឺជាអត្ថបទទីពីរនៃការសិក្សាមានពីរផ្នែក ឧបត្ថម្ភដោយ DFID ដែលស្រាវជ្រាវពីការប្រែប្រួលក្នុងការរកចិញ្ចឹមជីវិត ការប្រើប្រាស់ដី និងលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិនៅក្នុងភូមិជនបទចំនួន ៦ភូមិ នៅកម្ពុជា ។ ផ្អែកលើលទ្ធផលនៃករណីសិក្សា ការស្រាវជ្រាវបានលាតត្រដាងពីស្ថានភាពដ៏លំបាកចំពោះសហគមន៍ជនបទជាច្រើនដែលក្នុងនោះ សន្តិសុខស្បៀងកាន់តែត្រូវការគំរាមកំហែងខ្លាំងឡើង ជាពិសេសកសិករមានដីតូចៗ និងពលករគ្មានដីធ្លី ។ ការសិក្សាបានរកឃើញថា កំណើនប្រជាជននៅតាមជនបទ វាលឿនហួសពីលទ្ធភាពនៃធនធានធម្មជាតិក្នុងការជួយទ្រទ្រង់ដល់ពួកគេ ហើយម្យ៉ាងទៀត ធនធានធម្មជាតិក៏កំពុងស្ថិតក្រោមសំពាធកាន់តែខ្លាំង វិសមភាពដីកំពុងកើនឡើង ដីស្រែមួយចំនួនកំពុងត្រូវពុះចែកតូចៗរហូតក៏រិតលែងមានចីរភាព ឯអត្ថប្រយោជន៍នៃការប្រើប្រាស់គ្រឿងយន្តក៏ពុំបានបែងចែកស្មើភាពដែរ ។ ការសិក្សាបានពិនិត្យពីទីផ្សារផលិតផលកសិកម្ម និងឥទ្ធិពលនៃកំលាំងខាងក្រៅមកលើក៏រិតថ្លៃ រួមទាំងថ្លៃអន្តរជាតិផង និងពីមូលហេតុដែលថ្លៃផលិតផលកសិកម្ម មិនបានផ្តល់អត្ថប្រយោជន៍គ្រប់គ្រាន់ដល់កសិករធុនតូច ។ នៅចំពោះមុខបញ្ហាចោទទាំងនេះ មានពលករកសិកម្មកាន់តែកើនឡើងត្រូវបង្ខំចិត្តធ្វើចំណាកស្រុកទាំងនៅកម្ពុជា និងឆ្លងដែន ដើម្បីដោះស្រាយជីវភាព ។

*ឯកសារពិភាក្សានេះ* បានរៃកញ្ញែកផងដែរពីជំរើសគោលនយោបាយផ្សេងៗដែលពាក់ព័ន្ធដល់រដ្ឋាភិបាលកម្ពុជា និងអង្គការអន្តរជាតិនានា ។ ជំរើសទាំងនេះរួមមានទំនើបភាវូបនីយកម្ម ចំរុះកម្មកសិកម្ម កំណែទំរង់ទូលំទូលាយនៃ ទីផ្សារផលិតផលកសិកម្ម សន្តិសុខ កម្មសិទ្ធិដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ កំណែទំរង់ទីផ្សារពលកម្ម និងការពង្រីកសកម្មភាពមិនមែនកសិកម្ម និងសកម្មភាពក្រៅកសិដ្ឋាន ។

---

លោក គឹម សេតារា និងលោក ច័ន្ទ សុផល ជាអ្នកស្រាវជ្រាវ, Sarthi Acharya ជានាយកស្រាវជ្រាវនៅ វិបសអ ។

៦.០០០រៀល

ផ្ទះលេខ៥៦ ផ្លូវលេខ៣១៥ ខ័ណ្ឌទួលគោក ភ្នំពេញ កម្ពុជា
អាសយដ្ឋានប្រៃសណីយ ប្រអប់សំបុត្រលេខ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១/៨៨១-៩១៦/៨៨៣-៦០៣ ទូរស័ព្ទ/ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល: cdri@camnet.com.kh website: http://www.cdri.org.kh